Volume 87 Number 857 March 2005

# INTERNATIONAL REVIEW of the Red Cross



ច្បាប់ទំនៀមទំលាប់អន្តរជាតិ

## Customary law

ICRC

INTERNATIONAL
REVIEW
of the Red Cross

## គោលបំណង និងវិសាលភាព (Aim and Scope)

ទស្សនាវដ្ដីសិក្សាស្រាវជ្រាវអន្តរជាតិរបស់កាកបាទក្រហម ត្រូវបានបោះពុម្ពផ្សាយជាទៀងទាត់ ដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ក្នុងគោលបំណងចូលរួមលើកកម្ពស់ការយល់ដឹងច្បាប់មនុស្សធម៌អន្តរជាតិ គោលនយោបាយ និងសកម្មភាពនានាក្នុងពេលមានជម្លោះប្រដាប់អាវុធ ព្រមទាំងស្ថានភាពដទៃទៀតនៃអំពើហិង្សាដោយប្រើប្រដាប់អាវុធ។ ទស្សនាវដ្ដីឯកទេសច្បាប់មនុស្សធម៌អន្តរជាតិនេះ ផ្ដល់នូវពុទ្ធិការវិភាគស៊ីជម្រៅលើការវិវត្តន៍ថ្មីៗនៃច្បាប់ និងចូលរួមដល់ការបង្កាដល់ការរំលោភច្បាប់ ដើម្បីកិច្ចការពារសិទ្ធិនិងតំលៃរបស់មនុស្សជាតិជាមូលដ្ឋាន។ ម្យ៉ាងទៀតទស្សនាវដ្ដីឯកទេសនេះ ផ្ដល់ឱ្យមានវេទិកាទូលំទូលាយមួយសំរាប់ការពិភាក្សាអំពីសកម្មភាព មនុស្សធម៌ក្នុងបច្ចុប្បន្នភាព ព្រមជាមួយការផ្ដល់ការវិភាគលើមូលហេតុ និងចរិតលក្ខណៈនៃជំលោះដើម្បីធ្វើឱ្យ មានភាពកាន់តែជាក់លាក់ក្នុងកិច្ចការដោះស្រាយបញ្ហាមនុស្សធម៌ឬបញ្ហាជម្លោះប្រដាប់អាវុធដែលបាន និងកំពុងកើតមានឡើង។ ជាចុងក្រោយទស្សនាវដ្ដីឯកទេសនេះ ជូនជាដំណឹងដល់អ្នកអាន នូវសំនួរទាក់ទងដល់កាកបាទក្រហមអន្តរជាតិ និងសកម្មភាពអឌ្ឍចន្ទក្រហមអន្តរជាតិ និងជាពិសេសផ្ដល់ពតិមានស្ដីពីសកម្មភាព និងគោលនយោបាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)។

---

## គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)

ICRC គឺជាអង្គការឯករាជ្យ អព្យាក្រិត្យមិនលំអៀងដែលបំពេញបេសកកម្មមនុស្សធម៌របស់ខ្លួន ដើម្បី ការពារជីវិត និងសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះពីសង្គ្រាម និងអំពើហិង្សាផ្ទៃក្នុង ព្រមទាំងផ្ដល់ជំនួយដល់ពួកគេ។ គណៈកម្មាធិការកាកបាទក្រហម ជាអ្នកដឹកនាំសម្របសម្រួល និងធ្វើសកម្មភាពសង្គ្រោះមនុស្សធម៌អន្តរជាតិនៅក្នុងស្ថានភាពមានជម្លោះ។ គណៈកម្មាធិការខិតខំផងដែរដើម្បីបង្ការការទទួលរងការឈឺចាប់តាមរយៈការលើកកម្ពស់ និងពង្រឹងការគោរពច្បាប់មនុស្សធម៌អន្តរជាតិព្រមទាំងគោលការណ៍មនុស្សធម៌ជាសាកល។ គណៈកម្មាធិការដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៦៣ មានប្រភពដើមមកពីចលនាអឌ្ឍចន្ទក្រហម និងកាកបាទក្រហម។

## សមាជិកភាពនៃគណៈកម្មាធិការកាកបាទក្រហម

**(Member of the Committee)**

President: Jakob Kellenberger
Vice-President: Anne Petitpierre
Permanent Vice-President: Jacques Forster

Jean Abt
Jean-Philippe Assal
Christine Beerli
Paolo Bernasconi
Ernst A. Brugger
Susy Bruschweiler
Jean de Courten
Paola Ghillani
Claude Le Coultre
Jacques Moreillon
Gabrielle Nanchen
Yves Sandoz
Daniel Thürer
Olivier Vodoz
André von Moos

## សមាជិកក្រុមប្រឹក្សាអ្នកនិពន្ធ

**(Editoral Board)**

**Editor-in-Chief**
Toni Pfanner
*ICRC*

**Editorial Board**
Ahmed Abou El-Wafa
*Cairo University, Egypt*

Daniel Bar-Tal
*Tel Aviv University, Israel*

Annette Becker
*Université Paris X, France*

Antônio Cançado Trindade
*University of Brasilia, Brazil*

Marika Fahlen
*Ministry for Foreign Affairs, Stockholm, Sweden*

Bernard Haykel
*New York University, USA*

V. S. Mani
*Gujarat Law University, Gandhinagar, Gujarat, India*

Herfried Münkler
*Humbold University, Berlin, Germany*

Mona Rishmawi
*Office of the United Nations High Commissioner for Human Rights, Geneva*

Elizabeth Salmón Gárate
*Pontificia Universidad Católica del Perú, Lima, Perú*

Marco Sassòli
*University of Geneva, Switzerland*

Michael N. Schmitt
*George C. Marshall European Center for Security Studies, Garmisch Partenkirchen, Germany*

Terence Taylor
*International Institute for Strategic Studies, London/Washington DC, UK/USA*

Bakhtiyar R. Tuzmukhamedov
*Diplomatic Academy, Moscow, Russian Federation*

Wen-qi Zhu
*Law School, Renmin University of China, Beijing, People's Republic of China*

Volume 87 Number 857 March 2005

INTERNATIONAL REVIEW of the Red Cross

# ច្បាប់ទំនៀមទំលាប់អន្តរជាតិ

## ការសិក្សាអំពីច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិ (ការចូលរួមវិភាគទានការយល់ដឹងនិង ការគោរពដល់វិធានច្បាប់ជម្លោះប្រដាប់អាវុធ)

**លោក ចនមារី ហានកែរ**

លោក ចនមារី ហានកែរ (Jean-Marie Henckaerts ) ជាទីប្រឹក្សាច្បាប់របស់គណៈកម្មាធិការ កាកបាទក្រហមអន្តរជាតិ (ICRC) និងជាប្រធានគម្រោងរបស់ ICRC ថ្មីៗនេះ បានធ្វើការសិក្សាស្រាវជ្រាវជាមួយ លោក លី្វ ដូសវាលប៉ែក (Louise Doswald-Beck) អំពីច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិ ហើយបានរៀបរៀងស្នាដៃនេះចេញជាពីរភាគ និងបានបោះពុម្ពផ្សព្វផ្សាយដោយសាកលវិទ្យាល័យ Cambridge ។

### ខ្លឹមសារសង្ខេប (Abstract)

( អត្ថបទសិក្សាស្រាវជ្រាវនេះ ពន្យល់ពីហេតុផលពីក្រោយការសិក្សាច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិដែលបានធ្វើឡើងនៅពេលថ្មីៗនេះដោយ ICRC តាមសំណើសន្និសីទអន្តរជាតិរបស់ ICRC និងអឌ្ឍចន្ទក្រហម ។ អត្ថបទនេះបរិយាយអំពីវិធានដែលបានប្រើប្រាស់ និងវិធីដែលការសិក្សានេះបានរៀបចំឡើង ហើយអត្ថបទបានសង្ខេបគំហើញសំខាន់ៗមួយចំនួន។ ទោះបីជាយ៉ាងនេះក្តី អត្ថបទសិក្សានេះមិនមានបំណងផ្តល់នូវទស្សនៈជារួមទាំងស្រុង ឬការវិភាគលើគំហើញណាមួយជាក់លាក់ណាមួយឡើយ )

### សេចក្តីផ្តើម (Introduction )

ក្នុងរយៈពេល៥០ឆ្នាំ ឬបើគិតចាប់តាំងពីការអនុម័តអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩មក មនុស្សលោក បានជួបប្រទះនូវជម្លោះប្រដាប់អាវុធជាច្រើនដ៏គួរឱ្យភ្ញាក់ផ្អើល ដែលកើតមាននៅស្ទើរគ្រប់ទ្វីបទាំងអស់។ ក្នុង អំឡុងពេលនេះ អនុសញ្ញាហ្សឺណែវទាំងបួន និងពិធីសារបន្ថែមឆ្នាំ១៩៧៧ បានផ្តល់ការការពារតាមផ្លូវច្បាប់ដល់ បុគ្គលដែលមិនចូលរួម ឬឈប់ចូលរួមដោយផ្ទាល់ក្នុងជម្លោះប្រដាប់អាវុធ (មានដូចជា ជនរងរបួស អ្នកជម្ងឺ ជនរងគ្រោះដោយសារកប៉ាល់ចំបាំងលិចមនុស្សដែលត្រូវបានដកហូតសិទ្ធិសេរីភាពដោយសារជាប់ទាក់ទងជាមួយជម្លោះប្រដាប់អាវុធនិងជនស៊ីវិល)។ ប៉ុន្តែអំពើរំលោភបំពានលើច្បាប់នេះនៅតែមានជាហូរហែរ និងបានបង្កឱ្យមានការឈឺចាប់និងស្លាប់ហើយបញ្ហានេះគេអាចបញ្ចៀសវាបាន បើសិនច្បាប់មនុស្សធម៌អន្តរជាតិត្រូវបានគោរពឱ្យប្រសើរ ។

យោបល់ទូទៅមួយបានលើកឡើងថា ការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ មិនមែនដោយសារមកពីខ្វះខាតនូវវិធានរបស់ច្បាប់នេះទេ។ ប៉ុន្តែការរំលោភគឺបណ្តាលមកពីភាពគ្មានឆន្ទៈក្នុងការគោរពវិធានច្បាប់មកពីខ្វះ មធ្យោបាយគ្រប់គ្រាន់ដើម្បីអនុវត្តនីវិធាន មកពីភាពមិនច្បាស់លាស់ក្នុងការអនុវត្តក្នុងកាលៈទេសៈមួយចំនួន និងមកពីខ្វះការយល់ដឹងរបស់អ្នកដឹកនាំនយោបាយ មេបញ្ជាការទាហានយោធិន និងសាធារណៈជនទូទៅ។

សន្និសីទអន្តរជាតិស្តីពីការការពារជនរងគ្រោះដោយសារសង្គ្រាមបានកោះប្រជុំនៅទីក្រុងហ្សឺណែវ នៅក្នុងចន្លោះ ខែសីហា កញ្ញា ឆ្នាំ១៩៩៣ បានពិភាក្សាឡើងវិញ ដើម្បីដោះស្រាយការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែសន្និសីទមិនបានស្នើឱ្យមានការអនុម័តសន្ធិសញ្ញាថ្មីឡើយ ។ ជំនួសមកវិញ ក្នុងសេចក្តីថ្លែងការណ៍ចុងក្រោយរបស់សន្និសីទដែលបានអនុម័តដោយការព្រមព្រៀងជាឯកឆន្ទ័ បានអះអាងជាថ្មីនូវភាពចាំបាច់ក្នុងការអនុវត្តច្បាប់ មនុស្សធម៌ឱ្យកាន់តែមានប្រសិទ្ធិភាពជាងនេះ ហើយបានអំពាវនាវដល់រដ្ឋាភិបាលស្វីស ឱ្យកោះប្រជុំក្រុមអ្នកជំនាញ អន្តររដ្ឋាភិបាល ដើម្បីសិក្សាអំពីមធ្យោបាយអនុវត្តនី ការលើកកំពស់ការគោរពដ៏ពេញលេញ និងការអនុវត្តតាមច្បាប់មនុស្សធម៌ព្រមទាំងដើម្បីរៀបចំរបាយការណ៍ដាក់ជូនរដ្ឋភាគី និងអង្គប្រជុំនៅពេលបន្ទាប់របស់សន្និសីទអន្តរជាតិរបស់កាកបាទក្រហមអន្តរជាតិ និងអឌ្ឍចន្ទក្រហម ។[១]

ក្រុមអ្នកជំនាញអន្តររដ្ឋាភិបាលសំរាប់ការការពារជនរងគ្រោះដោយសារសង្គ្រាមបានជួបប្រជុំគ្នានៅក្នុងទីក្រុងហ្សឺណែវក្នុងខែមករា ឆ្នាំ១៩៩៥ ហើយបានអនុម័តអនុសាសន៍ជាបន្តបន្ទាប់ជាច្រើន ក្នុងបំណងពង្រឹងការគោរពច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេសតាមរយៈវិធានការបង្ការដែលនឹងធានាឱ្យប្រាកដថាការយល់ដឹង និងការអនុវត្តច្បាប់មនុស្សធម៌ឱ្យបានកាន់តែប្រសើរជាងនេះ។ អនុសាសន៍ទី២ របស់ក្រុមអ្នកជំនាញអន្តររដ្ឋាភិបាលបានស្នើថាៈ អង្គការអន្តរជាតិ ICRC គួរត្រូវបានអញ្ជើញឱ្យរៀបចំធ្វើរបាយការណ៍ ស្តីពីវិធានអនុវត្តច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិសំរាប់ក្នុងជម្លោះប្រដាប់អាវុធក្នុងក្របខណ្ឌអន្តរជាតិ ឬមិនអន្តរជាតិ ព្រមទាំងស្នើឱ្យផ្សព្វផ្សាយរបាយការណ៍ដល់រដ្ឋភាគី និងស្ថាប័នអន្តរជាតិដែលមានសមត្ថកិច្ចដោយមានការចូលរួមសហការពីអ្នកជំនាញ ច្បាប់មនុស្សធម៌អន្តរជាតិតំណាងតំបន់ស្ថិតក្នុងភូមិសាស្ត្រខុសៗគ្នា និងប្រព័ន្ធច្បាប់ផ្សេងៗគ្នា ហើយដោយមានការពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញរបស់រដ្ឋាភិបាល និងអង្គការអន្តរជាតិនានា។[២]

ក្នុងខែធ្នូ ឆ្នាំ១៩៩៥ សន្និសីទអន្តរជាតិលើកទី២៦ របស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមបានផ្តល់ការព្រមព្រៀងលើអនុសាសន៍នេះ ហើយផ្តល់អំណាចជាផ្លូវការដល់ ICRC ឱ្យរៀបចំធ្វើរបាយការណ៍ស្តីពីវិធានអនុវត្តច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិក្នុងពេលមានជំម្លោះប្រដាប់អាវុធជាអន្តរជាតិ ឬ មិនមែនជាអន្តរជាតិ។[៣] ប្រហែលជា១០ឆ្នាំក្រោយមកគឺនៅក្នុងឆ្នាំ២០០៥ បន្ទាប់ពីមានការពិនិត្យសិក្សាស្រាវជ្រាវដ៏ស៊ីជំរៅនិងការពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយអ្នកជំនាញនានា ហើយដែលការសិក្សាអំពីច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិ ត្រូវបានបោះពុម្ពឡើងនៅក្នុងរបាយការណ៍នេះជាស្ថាពរ ។[៤]

1 International Conference for the Protection of War Victims, Geneva, 30 August-1 September 1993, Final Declaration, International Review of the Red Cross, No. 296, 1993, p. 381.

2 Meeting of the Intergovernmental Group of Experts for the Protection of War Crimes, Geneva, 23-27 January 1995, Recommendation II, International Review of the Red Cross, No. 310, 1996, p.84.

3 26th International Conference of the Red Cross and Red Crescent, Geneva, 3-7 December 1995, Resolution 1, International humanitarian law: From law to action; Report on the follow-up to the International Conference for the Protection of War Victims, International Review of the Red Cross, No. 310, 1996, p.58.

4 Jean-Marie Henckaerts and Louise Doswald-Beck, Customary International Humanitarian Law, 2 volumes, Volume I. Rules, Volume II. Practice (2 Parts), Cambridhe University Press, 2005.

## គោលបំណង (Purpose)

គោលបំណងនៃការសិក្សាអំពី ច្បាប់ទំនៀមទំលាប់មនុស្សធម៌អន្តរជាតិ គឺដើម្បីដោះស្រាយនូវបញ្ហាមួយចំនួនពាក់ព័ន្ធជាមួយនឹងការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិដែលមានចែងក្នុងសន្ធិសញ្ញា។ សន្ធិសញ្ញាត្រូវបានរៀបចំបានយ៉ាងល្អប្រសើរ និងគ្របដណ្តប់លើទិដ្ឋភាពជាច្រើននៃសង្គ្រាម ហើយផ្តល់ការការពារដល់បុគ្គលជាច្រើនប្រភេទនៅក្នុងពេលមានសង្គ្រាម ព្រមទាំងក៏រិតមធ្យោបាយអនុញ្ញាតនិងវិធីសាស្ត្រធ្វើសង្គ្រាម។ អនុសញ្ញាហ្សឺណែវ និងពិធីសារបន្ថែមរបស់វាផ្តល់នូវប្រព័ន្ធដ៏មានវិសាលភាព សំរាប់ការការពារបុគ្គលដែលមិនចូលរួម ឬ ឈប់ចូលរួមដោយផ្ទាល់នៅក្នុងជម្លោះ។ បទបញ្ញត្តិស្តីពីមធ្យោបាយ និងយុទ្ធវិធីធ្វើសង្គ្រាមដែលបានចែងនៅក្នុងសន្ធិសញ្ញា។

គឺមានប្រភពចេញមកពីសេចក្តីថ្លែងការណ៍ St. Petersburg ឆ្នាំ១៨៦៨ បទបញ្ញត្តិទីក្រុង Hague ឆ្នាំ ១៨៩៩ និង ១៩០៧ និងពិធីសារ Geneva Gas ឆ្នាំ១៩២៥ ហើយនៅពេលថ្មីៗនេះវាត្រូវបានចែងក្នុងសន្ធិសញ្ញាអាវុធជីវសាស្ត្រឆ្នាំ ១៩៧២ ពិធីសារបន្ថែមឆ្នាំ១៩៧៧ សន្ធិសញ្ញាឆ្នាំ១៩៨០ ស្តីពីអាវុធធម្មតាមួយចំនួន និងពិធីសារបន្ថែមទាំង៥របស់វាសន្ធិសញ្ញាស្តីពីអាវុធគីមីឆ្នាំ១៩៩៣ និងសន្ធិសញ្ញាអូតាវ៉ាឆ្នាំ១៩៩៧ ស្តីពីការហាមឃាត់មីនប្រឆាំងមនុស្ស ។ ការការពារទ្រព្យសម្បត្តិវប្បធម៌ក្នុងអំឡុងពេលមានសង្គ្រាមត្រូវបានចែងយ៉ាងលំអិតនៅក្នុងសន្ធិសញ្ញា Hague ឆ្នាំ១៩៥៤ និងពិធីសារបន្ថែមចំនួន២របស់វា។ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ១៩៩៨ បានចែងក្នុងចំណោមនោះនូវបញ្ជីឈ្មោះឧក្រិដ្ឋកម្មសង្គ្រាមដែលស្ថិតនៅក្រោមយុត្តាធិការតុលាការ។

ទោះបីជាយ៉ាងនេះក្តី មានឧបសគ្គធំពីរទាក់ទងការអនុវត្តតាមសន្ធិសញ្ញាទាំងនោះ នៅក្នុងជម្លោះប្រដាប់អាវុធថ្មីៗដែលបង្ហាញថាការសិក្សាអំពីច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិគឺមានភាពចាំបាច់ និងមានប្រយោជន៍។ ទីមួយសន្ធិសញ្ញាត្រូវបានអនុវត្តតែចំពោះរដ្ឋដែលបានផ្តល់សច្ចាប័នដល់វាប៉ុណ្ណោះ។ នេះមានន័យថា សន្ធិសញ្ញាផ្សេងៗគ្នានៃច្បាប់មនុស្សធម៌អន្តរជាតិដែលត្រូវអនុវត្តនៅក្នុងជម្លោះប្រដាប់អាវុធផ្សេងៗគ្នាគឺផ្អែកទៅតាមសន្ធិសញ្ញាដែល ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋដែលចូលរួមក្នុងសង្គ្រាម។ ដោយឡែកអនុសញ្ញាហ្សឺណែវទាំង៤ឆ្នាំ១៩៤៩ត្រូវបានផ្តល់សច្ចាប័នជាសាកលហើយវាមិនដូចគ្នានិងសន្ធិសញ្ញាដទៃទៀតស្តីពីច្បាប់មនុស្សធម៌អន្តរជាតិឡើយឧទាហរណ៍ពិធីសារបន្ថែម។ ទោះបីជាពិធីសារបន្ថែមទី I ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាង ១៦០ ក៏ប្រសិទ្ធភាពសព្វថ្ងៃរបស់វានៅមានក៏រិត ដោយសាររដ្ឋជាច្រើនដែលបានចូលរួមក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ មិនមែនជាភាគីរបស់ពិធីសារនេះ។ ស្រដៀងគ្នានេះដែរខណៈដែលមានរដ្ឋប្រហែល ១៦០ បានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមទី២ ក៏នៅមានរដ្ឋមួយចំនួនដែលមានជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិនៅមិនទាន់បានផ្តល់សច្ចាប័ននៅឡើយ។ ក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តជាតិទាំងនេះមាត្រាទី៣រួម (Common Article 3) នៃ អនុសញ្ញាហ្សឺណែវទាំងបួន ជាបទបញ្ញត្តិសន្ធិសញ្ញាមនុស្សធម៌តែមួយគត់ដែលអាចអនុវត្តន៏បាន។ ដូចនេះគោលបំណងទីមួយនៃការសិក្សានេះ គឺដើម្បីកំណត់វិធានណាមួយនៃច្បាប់មនុស្សធម៌អន្តរជាតិ (International Humanitarian Law) ដែលជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ (Customary International Law) ហើយដែលអាចអនុវត្តន៏បានចំពោះគ្រប់ភាគីក្នុងជម្លោះប្រដាប់អាវុធទាំងអស់ដោយមិនគិតអំពីថា តើពួកគេបានឬមិនបានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាដែលមានវិធានដូចគ្នា ឬស្រដៀងគ្នានោះទេ។

ទីពីរ សន្ធិសញ្ញាច្បាប់មនុស្សធម៌មិនបានចែងលំអិតគ្រប់គ្រាន់ដល់ផ្នែកភាគច្រើននៃជម្លោះប្រដាប់អាវុធ ក្នុងសម័យបច្ចុប្បន្ននោះ គឺជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិដោយសារជម្លោះទាំងនេះ ស្ថិតនៅក្រោមវិធានសន្ធិសញ្ញាមានចំនួន

តិចតួច បើធៀបជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ ។ មានសន្ធិសញ្ញាចំនួនតិចតួចប៉ុណ្ណោះ ដែលអនុវត្តនឹងចំពោះជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិឧទាហរណ៍ៈ សន្ធិសញ្ញាស្ដីពីអាវុធធម្មតាមួយចំនួនដូច ដែលត្រូវបានធ្វើវិសោធនកម្មលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសន្ធិសញ្ញាអូតាវ៉ា ស្ដីពីការហាមឃាត់គ្រាប់មីនប្រឆាំងមនុស្សសន្ធិសញ្ញាអាវុធគីមី សន្ធិសញ្ញា Hague សំរាប់ការការពារសម្បត្តិវប្បធម៌ និងពិធីសារបន្ថែមរបស់វាព្រមទាំងដូចដែលបានបញ្ជាក់ជូនរួមមកហើយពិធីសារបន្ថែមទី២ និងមាត្រាទី៣រួមរបស់អនុសញ្ញាហ្សឺណែវទាំងបួន ។ ខណៈដែលមាត្រារួមទី៣មានសារៈសំខាន់ជាចំបង ប៉ុន្តែវាត្រឹមតែផ្ដល់ក្របខណ្ឌមូលដ្ឋាននៃស្តង់ដារអប្បបរមា ។ ពិធីសារបន្ថែមទី II ជាធម្មតាបង្គ្រប់បន្ថែមមាត្រារួមទី៣ ក៏ប៉ុន្តែវានៅមិនទាន់លំអិតច្រើនដូចវិធាន គ្រប់គ្រងជម្លោះប្រដាប់អាវុធអន្តរជាតិចែងក្នុងអនុសញ្ញាហ្សឺណែវ និងពិធីសារបន្ថែមទី I ។

ពិធីសារបន្ថែមទី II រួមមានតែមាត្រាសំខាន់ចំនួន១៥ ប៉ុណ្ណោះ ចំណែកឯពិធីសារបន្ថែមទី១ មានជាង ៨០មាត្រា ។ ខណៈដែលចំនួនតែមួយមុខមិនអាចបង្ហាញពីរឿងរ៉ាវពេញលេញ ពួកគេបង្ហាញនូវភាពខុសគ្នាជាដុំកំភួននៃបទបញ្ញត្តិរបស់សន្ធិសញ្ញារវាងជម្លោះប្រដាប់អាវុធអន្តរជាតិនិងមិនមែនអន្តរជាតិជាពិសេសនៅពេលដែលវាមាននិយមន័យនិងវិធានដ៏លំអិត ។ ដូចនេះគោលបំណងទីពីរនៃការសិក្សានេះ គឺដើម្បីកំណត់ថា តើច្បាប់ទំនៀមទំលាប់អន្តរជាតិចែងអំពីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិលំអិតជាងអ្វីដែលសន្ធិសញ្ញាបានចែង ហើយប្រសិនបើមានដូច្នេះមែន តើវាលំអិតក៏រិតណា ?

## វិធីសាស្រ្តសិក្សា (Methodology)

លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិចែងថា " ច្បាប់ទំនៀមទំលាប់អន្តរជាតិ ជាការអនុវត្តជាទូទៅដែលត្រូវបានទទួលស្គាល់ថាជាច្បាប់" ។[៥] គេបានឯកភាពជាទូទៅថា អត្ថិភាពនៃច្បាប់ទំនៀមទំលាប់អន្តរជាតិតំរូវអោយមានធាតុផ្សំចំនួន២ : គឺការអនុវត្តរបស់រដ្ឋ និងជំនឿថាការអនុវត្តរបស់រដ្ឋនេះត្រូវបានអនុញ្ញាត ឬត្រូវបានហាមឃាត់ដោយផ្អែកតាមសារជាតិនៃវិធាន ហើយចាត់ទុកដូចជាច្បាប់ ។ ដូចដែលតុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់នៅក្នុងសាលក្រមក្នុងរឿងក្ដី Continental Shelf Case ថាៈ "វាជាការដ៏ច្បាស់លាស់ដែលថាអ្វីជា ច្បាប់ទំនៀមទំលាប់អន្តរជាតិនឹងត្រូវបានពិនិត្យមើលជាសំខាន់ក្នុងការអនុវត្តរបស់រដ្ឋ និងជំនឿរបស់រដ្ឋ (Opinio Juris of States)" ។[៦] អត្ថន័យ និងខ្លឹមសាររបស់ធាតុផ្សំទាំងពីរនេះជាប្រធានបទនៃការសិក្សាស្រាវជ្រាវជាច្រើន ។ វិធីសាស្រ្តដែលត្រូវប្រកាន់យកសំរាប់ធ្វើការសិក្សាស្រាវជ្រាវដើម្បីកំណត់ថា តើមានឬមិនមានវិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិ គឺជាវិធីសាស្រ្តបុរាណដែលកំណត់ដោយតុលាការយុត្តិធម៌អន្តរជាតិជាពិសេសនៅក្នុងរឿងក្ដីពាក់ព័ន្ធ North Sea Continental Shelf ។[៧]

## ការអនុវត្តរបស់រដ្ឋ (State Practice)

ការអនុវត្តរបស់រដ្ឋត្រូវបានពិនិត្យលើមូលដ្ឋានគ្រឹះសំខាន់ពីរ : ទីមួយ តើការអនុវត្តអ្វីដែលចូលរួមចំណែក អោយមានការ

5 Statute of the International Court of Justice, Article 38(1)(b).

6 International Court of Justice, Continental Shelf case (Libyan Arab Jamahiriya v. Malt), Judgment, 3 June 1985, ICJ Reports 1985, pp. 29-30, §27.

7 International Court of Justice, North Sea Continental Shelf cases, Judgment, 20 February 1969, ICJ Reports 1969, p.3.

បង្កើតច្បាប់ទំនៀមទំលាប់អន្តរជាតិ (ជំរើសអនុវត្តរបស់រដ្ឋ) ហើយទីពីរ ថាតើការអនុវត្តនេះបង្កើតជាវិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិដែរឬទេ (ការវាយតំលៃលើការអនុវត្តរបស់រដ្ឋ) ។

*ជំរើសការអនុវត្តរបស់រដ្ឋ* ***(Selection of State Practice)***

សកម្មភាពជាទង្វើក្តី ឬជាពាក្យសំដីក្តី របស់រដ្ឋនិមួយៗសុទ្ធតែជាការអនុវត្តជាក់ស្តែងដែលនាំមកនូវការបង្កើតច្បាប់ទំនៀមទំលាប់អន្តរជាតិ ។ សកម្មភាពស្តែងឃើញជាទង្វើរួមមានឧទាហរណ៍ការប្រព្រឹត្តនៅក្នុងសមរភូមិ ការប្រើប្រាស់អាវុធមួយចំនួនព្រមទាំងការប្រព្រឹត្តចំពោះប្រភេទមនុស្សផ្សេងៗ ។ សកម្មភាពជា ពាក្យសំដីរាប់បញ្ចូលក្បួនធ្វើសឹកច្បាប់ជាតិ សេចក្តីសំរេច ឬសាលក្រមរបស់តុលាការជាតិ សេចក្តីណែនាំដល់កងកំលាំងយោធាសន្តិសុខ ឯកសារទាក់ទងផ្នែកយោធាក្នុងកំឡុងពេលសង្គ្រាម កំណត់តវ៉ាធ្វើដោយអង្គទូត យោបល់របស់ទីប្រឹក្សាច្បាប់របស់រដ្ឋ បទអត្ថាធិប្បាយរបស់រដ្ឋាភិបាលលើសេចក្តីព្រាងសន្ធិសញ្ញាសេចក្តីសំរេច និង បទបញ្ញត្តិរដ្ឋបាលការធ្វើសក្ខីកម្មនៅចំពោះមុខតុលាការអន្តរជាតិ សេចក្តីថ្លែងការណ៏នៅឯវេទិកាអន្តរជាតិ និងឯកសាររបស់រដ្ឋាភិបាលស្តីពីជំហរចំពោះសេចក្តីសំរេចធ្វើឡើងដោយអង្គការអន្តរជាតិ ។ បញ្ជីរៀបរាប់ទាំងនេះ បង្ហាញថាការអនុវត្តរបស់អង្គនីតិប្រតិបត្តិនីតិបញ្ញត្តិ និងតុលាការដែលជាស្ថាប័នរបស់រដ្ឋអាចចូលរួមក្នុងការបង្កើតច្បាប់ទំនៀមទំលាប់អន្តរជាតិ ។

ការចរចារ និងអនុម័តនូវសេចក្តីសំរេចចិត្តដោយអង្គការអន្តរជាតិ ឬសន្និសីទរួមជាមួយនិងការពន្យល់អំពី ការបោះឆ្នោតគឺជាអំពើរបស់រដ្ឋដែលបានចូលរួម ។ មានករណីលើកលែងចំនួនតិចតួចដែលគេទទួលស្គាល់ថាសេចក្តី សំរេចជាធម្មតាមិនចងជាកាតព្វកិច្ចដល់រដ្ឋឡើយ ហើយដូចនេះ ការផ្តល់តំលៃដល់សេចក្តីសំរេចណាមួយនៅក្នុងការពិចារណានៃការបង្កើតច្បាប់ទំនៀមទំលាប់អន្តរជាតិគឺផ្អែកទៅតាមអ្វីដែលមាននៅក្នុងសេចក្តីសំរេចនោះឬក៏រិតនៃការទទួលយល់ព្រមនិងភាពស៊ីសង្វាក់នៃការអនុវត្តដែលពាក់ព័ន្ធរបស់រដ្ឋ ។[8] ការគាំទ្រលើសេចក្តីសំរេចកាន់តែច្រើន គឺវាសារៈសំខាន់កាន់ខ្លាំងក្នុងការទទួលស្គាល់លើសេចក្តីសំរេចនោះ ។

សេចក្តីសំរេចរបស់តុលាការអន្តរជាតិមិនបង្កើតអាចការអនុវត្តរបស់របស់រដ្ឋទេ ប៉ុន្តែសេចក្តីសំរេចនោះជាប្រភពបន្ទាប់បន្សំរបស់ច្បាប់អន្តរជាតិ ។[9] នេះដោយសារវាខុសពីតុលាការជាតិ តុលាការអន្តរជាតិមិនមែនជាស្ថាប័នរបស់រដ្ឋ ។ ទោះបីជាយ៉ាងនេះក្តី សេចក្តីសំរេចរបស់តុលាការអន្តរជាតិមានសារៈប្រយោជន៏ដោយសារការរក ឃើញដោយតុលាការថាវិធានច្បាប់ទំនៀមទំលាប់អន្តរជាតិកើតមាន វាជាភស្តុតាងដ៏មានសក្តានុពល ។ ជាបន្ថែមដោយសារតំលៃជាយុត្តិសាស្ត្ររបស់សេចក្តីសំរេចរបស់តុលាការអន្តរជាតិអាចរួមចំណែកផងដែរ ក្នុងការចាប់កើតមានវិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិតាមរយៈការនាំអោយមានការអនុវត្តជាបន្តបន្ទាប់គ្នារបស់រដ្ឋ និងអង្គការអន្តរជាតិ ។

ការអនុវត្តរបស់ក្រុមប្រដាប់អាវុធ មានដូចជាក្រមសីលធមិការប្តេជ្ញាចិត្តក្នុងការប្រតិបត្តិតាមវិធានមួយ ចំនួននៃច្បាប់មនុស្សធម៌អន្តរជាតិ និងសេចក្តីថ្លែងការណ៏ផ្សេងៗ មិនបង្កើតជាការអនុវត្តរបស់រដ្ឋទេ ។ ខណៈដែលការអនុវត្តទាំងនោះអាចបង្ហាញថាជាភស្តុតាងនៃការទទួលយកនូវវិធានមួយចំនួនក្នុងជំលោះប្រដាប់អាវុធមិនមែនអន្តរជាតិ តំលៃផ្លូវច្បាប់របស់វាមិនមានភាពជាក់លាក់ ហើយជាលទ្ធផលមិនត្រូវបានគេផ្អែកតាមក្នុងការបង្ហាញ នូវអត្ថិភាពនៃច្បាប់ទំនៀមទំលាប់

8 The importance of these conditions was stressed by the International Court of Justice, Legality of the Threat or Use of Nuclear Weapons, Advisory Opinion, 8 July 1996, ICJ Reports 1996, pp. 254-255, §§ 70-73.

9 Statute of the International Court of Justice, Article 38 (1) (d).

អន្តរជាតិ។ ឧទាហរណ៍នៃការអនុវត្តប្រភេទនោះត្រូវបានដាក់ក្រោមការពិភាក្សាអំពី "ការអនុវត្តផ្សេងទៀត" នៅក្នុងភាគទី ll នៃការសិក្សាស្រាវជ្រាវនេះ។

*ការវាយតំលៃលើការអនុវត្តរបស់រដ្ឋ* ***(Assessment of State Practice)***

ការអនុវត្តរបស់រដ្ឋត្រូវតែវាស់មើលដើម្បីកំណត់ថា តើការអនុវត្តមានច្រើនគ្រប់គ្រាន់សំរាប់បង្កើតវិធានច្បាប់ទំនៀមទំលាប់អន្តរជាតិឬទេ។ [១០] ការអនុវត្តត្រូវតែជាទូទៅស៊ីសង្វាក់ និងជាគំរូ (ក្នុងតំបន់នីមួយៗ) ដើម្បីជាហេតុបង្កើតជាវិធានច្បាប់ទំនៀមទំលាប់អន្តរជាតិ។[១១] សូមពិនិត្យមើលដោយហ្មត់ចត់នូវអ្វីដែលយើងចង់លើកមកនិយាយពាក់ព័ន្ធក្នុងចំនុចនេះ។

**ទីមួយ** ដើម្បីអោយការអនុវត្តរបស់រដ្ឋអាច នាំឱ្យបង្កើតវិធានទំនៀមទំលាប់អន្តរជាតិ ការអនុវត្តនោះត្រូវតែស៊ីសង្វាក់គ្នា។ រដ្ឋផ្សេងៗទៀតមិនត្រូវធ្វើនូវអំពើផ្ទុយពីការអនុវត្តនេះទេ។ យុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិបង្ហាញថា ការអនុវត្តផ្ទុយដែលមើលជាបឋមទៅវាហាក់ដូចជាបំផ្លាញភាពស៊ីសង្វាក់នៃការអនុវត្ត របស់រដ្ឋដែលពាក់ព័ន្ធគឺមិនបានបង្អាក់ដំណើរបង្កើតវិធានច្បាប់ទំនៀមទំលាប់អន្តរជាតិនោះឡើយ ប្រសិនបើការអនុវត្តផ្ទុយត្រូវបានរដ្ឋដទៃថ្កោលទោស ឬបដិសេធដោយរដ្ឋាភិបាលរបស់ខ្លួន (រដ្ឋអនុវត្តន៍ផ្ទុយ)។ ផ្ទុយទៅវិញ តាមរយៈការថ្កោលទោស ឬ បដិសេធនោះវិធានស្ថិតក្នុងការពិចារណា ត្រូវបានផ្តល់ន័យជាវិជ្ជមាន។[១២]

នេះជាពិសេសពាក់ព័ន្ធដល់វិធានមួយចំនួនរបស់ច្បាប់មនុស្សធម៌អន្តរជាតិដែលមានភស្តុតាងជាច្រើននៃការ អនុវត្តរបស់រដ្ឋគាំទ្រវិធានស្របពេលដែលមានភស្តុតាងដដែលនៃការរំលោភលើវិធាននោះ។ ការរំលោភបំពាន មិនមែនជាប្រភេទដែលជំទាស់ដល់អត្ថិភាពនៃវិធានស្ថិតក្នុងការពិចារណាឡើយ បើការរំលោភបំពានត្រូវបានភ្ជាប់ជាមួយនូវការដោះសារ ឬធ្វើយុត្តិកម្មដោយភាគីពាក់ព័ន្ធ ឬការថ្កោលទោសដោយរដ្ឋដទៃផ្សេងទៀត។ រដ្ឋណាដែលចង់កែវិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវតែធ្វើតាមរយៈការអនុវត្តជាផ្លូវការ និងមានការទាមទារដែលត្រូវបានសំដែងឡើងជាបន្តបន្ទាប់ ដើម្បីឱ្យមានភាពយុត្តិធម៌។

**ទីពីរ** ការអនុវត្តរបស់រដ្ឋត្រូវមានភាពទូទៅ និងជាគំរូដើម្បីអោយវិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិអាចកើតចេញជារូបរាង។ ទោះបីជាយ៉ាងនេះក្តីការអនុវត្តមិនចាំបាច់មានលក្ខណៈជាសាកលឡើយការអនុវត្តកើត មានជាទូទៅគឺជាការគ្រប់គ្រាន់ហើយ។[១៣] វាមិនមានការទាមទារនូវភាពជាក់លាក់ ឬភាគរយរបស់រដ្ឋឡើយ។ ហេតុផលមួយនៃការមិនអាចដាក់ចំនួនជាក់លាក់លើវិសាលភាពនៃការចូលរួមដែលត្រូវបានទាមទារ គឺថាលក្ខខណ្ឌវិនិច្ឆ័យ គឺផ្តោតលើគុណភាពជាជាងបរិមាណ។ នេះមានន័យថាវាមិនមែនគ្រាន់តែជាបញ្ហាថាតើមានចំនួនរដ្ឋប៉ុន្មាន ចូលរួមក្នុងការអនុវត្តប៉ុណ្ណោះទេ តែតើមានរដ្ឋណាខ្លះដែលពាក់ព័ន្ធផងដែរ។[១៤] ផ្អែកតាមយោបល់របស់តុលាការ យុត្តិធម៌អន្តរជាតិក្នុងក្តីរឿងក្តី North Sea Continental Shelf ការអនុវត្តត្រូវតែរាប់បញ្ចូលការអនុវត្តរបស់ រដ្ឋដែលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ជាពិសេស។[១៥]

10 The expression "dense" in this context comes from Sir Humphrey Waldock, "General Course on Public International Law", Collected Courses of the Hague Academy of International Law, Vol. 106, 1962, p. 44.

11 International Court of Justice, North Sea Continental Shelf cases, op. cit. (note 7), p. 43, § 74.

12 See International Court of Justice, Case concerning Military and Paramilitary Activities in and against Nicaragua (Nicaragua v. United States), Merits, Judgment, 27 June 1986, ICJ Reports 1986, p. 98, § 186.

13 International Law Association, Final Report of the Committee on the Formation of Customary (General) Internationl Law, Statement of Principles Applicable to the Formation of General Customary International Law, Report of the Sixty-Ninth Conference, London, 2000, Principle 14, p. 734 (hereinafter "ILA Report").

14 Ibid., commentary (d) and (e) to Principle 14, pp. 736-737.

15 International Court of Justice, North Sea Continental Shelf cases, op. cit. (note 7), p. 43, § 74.

ការអះអាងដូចនេះ គឺមានបញ្ហាពាក់ព័ន្ធចំនួនពីរ : **ទីមួយ** ប្រសិនបើគ្រប់រដ្ឋដែលប៉ះពាល់ជាពិសេសទាំងអស់ជារដ្ឋតំណាង វាមិនសំខាន់ទេក្នុងការទាមទារឱ្យរដ្ឋភាគច្រើនត្រូវចូលរួម ប៉ុន្តែរដ្ឋទាំងនោះត្រូវតែយ៉ាងហោចណាស់ទទួលយកដោយប្រយោលនូវការអនុវត្តរបស់រដ្ឋដែលត្រូវបានប៉ះពាល់ហើយ **ទី២** ប្រសិនបើរដ្ឋប៉ះពាល់ជាពិសេសមិនបានទទួលយកការអនុវត្តនោះការអនុវត្តនេះ មិនអាចមានភាពពេញលេញក្នុងការបង្កើតវិធាននៃច្បាប់ ទំនៀមទំលាប់អន្តរជាតិទេទោះបីជាមានការឯកភាពជាឯកឆន្ទត្រូវបានលើកមកសំអាងក៏ដោយ ។[16] អ្នកដែលត្រូវ បានប៉ះពាល់ជាពិសេសក្រោមច្បាប់មនុស្សធម៌អន្តរជាតិអាចមានច្រើនដោយផ្អែកទៅតាមកាលៈទេសៈនីមួយៗ ។ ឧទាហរណ៍ទាក់ទងដល់ភាពស្របច្បាប់នៃការប្រើអាវុធ Blinding Laser រដ្ឋប៉ះពាល់ជាពិសេសរួមមានរដ្ឋដែល ត្រូវបានកំណត់ថា ជារដ្ឋស្ថិតក្នុងដំណើរការអភិវឌ្ឍអាវុធប្រភេទនោះ ទោះបីជារដ្ឋផ្សេងទៀតអាចទទួលរងពីការប្រើប្រាស់អាវុធប្រភេទនោះក៏ដោយ ។ ស្រដៀងគ្នានេះដែររដ្ឋដែលប្រជាជនរបស់ខ្លួនត្រូវការជំនួយមនុស្សធម៌គឺ ជារដ្ឋរងការប៉ះពាល់ជាពិសេស ដូចគ្នានឹងរដ្ឋដែលជារឿយៗផ្តល់ជំនួយអោយដែរ ។ ទាក់ទងជាមួយវិធានណាមួយនៃច្បាប់មនុស្សធម៌អន្តរជាតិប្រទេសដែលបានចូលរួមក្នុងជម្លោះប្រដាប់អាវុធ គឺជារដ្ឋដែលប៉ះពាល់ជាពិសេសក្នុងខណៈដែលការអនុវត្តរបស់ពួកគេ ត្រូវបានពិនិត្យពាក់ព័ន្ធវិធានណាមួយវាទាក់ទងដល់ជម្លោះប្រដាប់អាវុធនោះ ។ ទោះបីជាអាចមានរដ្ឋដែលបានប៉ះពាល់ជាពិសេសច្រើនក្នុងវិស័យមួយចំនួននៃច្បាប់អន្តរជាតិវាជាការពិតផងដែរដែលរដ្ឋទាំងអស់ មានផលប្រយោជន៍ផ្លូវច្បាប់ក្នុងការទាមទារឱ្យមានការគោរពនូវច្បាប់មនុស្សធម៌អន្តរជាតិពីរដ្ឋដទៃទៀត ទោះបីពួកគេមិនមែនជាភាគីក្នុងជម្លោះក៏ដោយ ។[17] បន្ថែមពីលើនេះរដ្ឋទាំងអស់អាចទទួលផលប៉ះពាល់ពីមធ្យោបាយ ឬវិធីសាស្ត្រធ្វើចំបាំងធ្វើឡើងដោយរដ្ឋដទៃទៀត ។ ជាលទ្ធផលការអនុវត្តរបស់រដ្ឋទាំងអស់ត្រូវតែបានពិចារណាថាតើរដ្ឋនោះមិន ឬមិនមែនជារដ្ឋដែលប៉ះពាល់ជាពិសេសតាមន័យចង្អៀតរបស់វាក្យសព្ទនេះ ។

ការសិក្សានេះមិនបានផ្តល់ទស្សនៈស្តីពីថា តើវាអាចធ្វើទៅរួចទេតាមផ្លូវច្បាប់ចំពោះការជំទាស់ជាដដែលៗ (Persistent Objector) ទាក់ទងជាមួយវិធានដែលជាទំនៀមទំលាប់របស់ច្បាប់មនុស្សធម៌អន្តរជាតិនោះ ។ ស្របគ្នានេះមានអ្នកធ្វើអត្ថាធិប្បាយខ្លះជឿថា វាមិនអាចទៅរួចឡើយសំរាប់ការបដិសេធជាដដែលៗ ក្នុងករណីពាក់ព័ន្ធវិធានដែលមានតំលៃខ្ពស់ (Jus Cogens) ហើយមានអ្នកអត្ថាធិប្បាយដទៃទៀត នៅមានការសង្ស័យលើ សុពលភាពនៃអត្ថិភាពក្នុងទស្សនៈការបដិសេធជាដដែលៗ ។[18] ប្រសិនបើជនណាម្នាក់ទទួលថាវាធ្វើទៅបានតាមផ្លូវច្បាប់សំរាប់ការជំទាស់ជាដដែលៗ ហើយរដ្ឋដែលពាក់ព័ន្ធត្រូវតែធ្វើការជំទាស់ទៅនឹងការកកើតនៃវិធានថ្មីនោះ នៅក្នុងអំឡុងពេលនៃការបង្កើតវិធាននោះ និងបន្តជំទាស់ដដែលៗនៅពេលក្រោយមកទៀត ហើយការជំទាស់ទាំងឡាយណាដែលកើតមានក្រោយពីវិធានកើតចេញជារូបរាងរួចហើយ មិនអាចទទួលយកបានឡើយ ។[19]

នៅពេលខ្លះ ពេលវេលាបានរំលងទៅមុនពេលដែលវិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិកើតមាន គឺគ្មានពេលវេលាកំណត់ជាក់លាក់ឡើយ ។ វាគឺជាការបូករួមបញ្ចូលនៃការអនុវត្តដែលមានចំនួនច្រើនគ្រប់គ្រាន់ ដោយពិចារណាលើភាពស៊ីសង្វាក់គ្នាទូទៅ នឹងភាពជាតំណាងដែលនេះគឺជាកត្តាកំណត់ ។[20]

16 ILA Report, op. cit. (note 13), commentary (e) to Principle 14, p. 737.

17 See Customary International Humanitarian Law, op. cit. (note 4), Vol. I, commentary to Rule 144.

18 For an in-depth discussion of this issue, see Maurice H. Mendelson, “The Formation of Customary International Law”, Collected Courses of the Hague Acedemy of International Law, Vol. 272, 1998, pp. 227-244.

19 ILA Report, op. cit. (note 13), commentary (b) to Principle 15, p. 738.

20 Ibid., commentary (b) to Principle 12, p. 731.

## ជំនឿរបស់រដ្ឋថាជាច្បាប់ (Opinio Juris)

ល័ក្ខខណ្ឌទាមទារនូវ ជំនឿរបស់រដ្ឋថាជាច្បាប់ (Opinio Juris) ដើម្បីបង្កើតចេញជាវិធាននៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិសំដៅលើជំនឿផ្លូវច្បាប់ដែលការអនុវត្តជាក់លាក់ណាមួយត្រូវបានធ្វើឡើងថា ជាការត្រឹមត្រូវ (as of right) ។ ទម្រង់ដែលក្នុងនេះការអនុវត្ត និងជំនឿផ្លូវច្បាប់ (Legal Conviction) ដែលត្រូវបានបង្ហាញឡើងអាចខុសពីគ្នាដោយផ្អែកទៅតាមថា តើវិធានដែលពាក់ព័ន្ធមានចែងពីការហាមឃាត់កាតព្វកិច្ច ឬគ្រាន់តែជាសិទ្ធិដើម្បីប្រព្រឹត្តក្នុងលក្ខណៈជាក់លាក់ណាមួយ ។

ក្នុងអំឡុងពេលធ្វើការសិក្សានេះ វាមានការលំបាកជាខ្លាំង និងផ្អែកលើទ្រឹស្តីជាចំបងក្នុងការចាត់ដោយឡែកយ៉ាងហ្មត់ចត់នូវធាតុផ្សំនៃការអនុវត្ត និងជំនឿគិតថាជាច្បាប់ (Legal Conviction) ។ ជារឿយៗ អំពើដូចគ្នាឆ្លុះបង្ហាញទាំងការអនុវត្ត និងជំនឿចាត់ថាជាច្បាប់ ។ ដូចដែលសមាគមអ្នកច្បាប់អន្តរជាតិបានចង្អុលបង្ហាញថា : តុលាការយុត្តិធម៌អន្តរជាតិជាក់ស្តែងមិនបាននិយាយលំអិតដោយសារថា ធាតុផ្សំខុសគ្នានៅក្នុងច្បាប់ទំនៀមទំលាប់ ហើយទង្វើដូចគ្នាមិនសំដែងឱ្យឃើញធាតុផ្សំទាំងពីរឡើយ ។ ជារឿយៗ និងជាក់ស្តែងវាមានការលំបាក ឬសូម្បីមិនអាចទៅរួចក្នុងការបំបែកធាតុផ្សំទាំងពីរនេះ ។[២១] ជាពិសេសនេះដោយសារអំពើជាពាក្យសំដី (Verbal Acts) ដូចជាក្បួនធ្វើសឹករាប់ជាការអនុវត្តរបស់រដ្ឋ ហើយជារឿយៗវាឆ្លុះបញ្ចាំងនូវជំនឿចាត់ថាជាច្បាប់របស់រដ្ឋដែលជាប់ពាក់ព័ន្ធក្នុងពេលដូចគ្នា ។

នៅពេលដែលមានការអនុវត្តច្រើនគ្រប់គ្រាន់ ជំនឿចាត់ថាជាច្បាប់ជាទូទៅមាននៅក្នុងការអនុវត្តនោះ ហើយជាលទ្ធផល និងជាធម្មតាវាមិនចាំបាច់ទេក្នុងការបង្ហាញនូវអត្ថិភាពនៃជំនឿចាត់ថាជាច្បាប់ដាច់ដោយឡែក ។ ប៉ុន្តែក្នុងស្ថានភាពដែលការអនុវត្តមិនច្បាស់លាស់ ជំនឿចាត់ថាជាច្បាប់មានតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ថាតើការអនុវត្តរាប់ ឬមិនរាប់បញ្ចូលក្នុងការបង្កើតទំនៀមទំលាប់ ។ ជារឿយៗ នេះគឺជាករណីកើតមានចំពោះអំពើខកខាន (Omission) នៅពេលដែលរដ្ឋមិនបានប្រព្រឹត្ត ឬ គ្មានប្រតិកម្ម ប៉ុន្តែវាមិនច្បាស់ថាតើមកពីហេតុអ្វី ។ នៅក្នុងករណីនេះតុលាការយុត្តិធម៌អន្តរជាតិ (ICJ) និងតុលាការអចិន្ត្រៃយ៍សំរាប់យុត្តិធម៌អន្តរជាតិ (Permanent Court of International Justice) បានព្យាយាមបង្កើតអត្ថិភាពដាច់ដោយឡែកនៃជំនឿចាត់ថាជាច្បាប់ ដើម្បីកំណត់ថាតើករណីការអនុវត្តមិនច្បាស់ត្រូវបានរាប់បញ្ចូលក្នុងការបង្កើតច្បាប់ទំនៀមទំលាប់អន្តរជាតិឬទេ ។[២២]

នៅក្នុងវិស័យច្បាប់មនុស្សធម៌អន្តរជាតិ មានវិធានជាច្រើនដែលតម្រូវមិនឱ្យធ្វើនូវអំពើមួយចំនួនការខកខានបង្កជាបញ្ហាជាក់លាក់មួយនៅក្នុងការវាយតំលៃលើជំនឿចាត់ថាជាច្បាប់ដោយសារវាអាចត្រូវតែបង្ហាញថា ការមិនធ្វើមិនមែនជារឿងចៃដន្យ (Coincidence) ក៏ប៉ុន្តែបានផ្អែកលើសេចក្តីរំពឹងដ៏សមស្របមួយ ។ នៅពេលការទាមទារការមិនធ្វើនេះ ត្រូវបានចង្អុលបង្ហាញក្នុងលិខិតុបករណ៍អន្តរជាតិ និងសេចក្តីថ្លែងការណ៍ជាផ្លូវការអត្ថិភាពនៃតម្រូវការផ្លូវច្បាប់ ដើម្បីនាំអោយការនៅឆ្ងាយពីអំពើដែលនិយាយសំដៅដល់ជាធម្មតាត្រូវបានគេបង្ហាញ ។ បន្ថែមពីលើនេះការមិនធ្វើ (Abstention) នេះអាចកើត

21 Ibid., p. 718, § 10 (c). For an in-depth analysis of this question, see Peter Haggenmacher, “La doctrine des deux elements du droit coutumier dans la pratique de la Cour internationale”, Revue generale de droit international public, Vol. 90, 1986, p. 5.

22 See, e.g., Permanent Court of International Justice, Lotus case (France v. Turkey), Judgment, 7 September 1972, PCIJ Ser. A, No. 10, p.28 (tu-lakar)anrkeXIjfa rdæmin)andkxøÜnBIkarvinicä½yGMeBIekItenAkñúgk)a:l; eday sarrdæyl;eXIjfa RtUv)anhamXat;BIkareFVIdUecñH¦. International Court of Justice, North Sea Continental Shelf cases, op. cit. (note 7), pp. 43-44, §§ 76-77 (the Court found that States that had delimited their continental shelf on the basis of the equidisstance principle had not done so because they felt obliged to do); ILA Report, op. cit. (note 13), Principle 17 (iv) and commentary.

មានឡើងក្រោយពីការប្រព្រឹត្តដែលនិយាយសំដៅដល់បានបង្កើតនូវភាពខ្វែងយោបល់ជាក់លាក់មួយដែលជួយផងដែរ ដើម្បីបង្ហាញថាការមិនធ្វើមិនមែនជារឿងចៃដន្យ ទោះបីជានិច្ចកាលវាមិនមានការងាយស្រួលក្នុងការបង្ហាញថា ការមិនធ្វើបានកើតនៅក្រៅបរិបទកាតព្វកិច្ចផ្លូវច្បាប់ក៏ដោយ (Occurred Out of a Sense of Legal Obligation) ។

## ផលប៉ះពាល់នៃច្បាប់សន្ធិសញ្ញា (Impact of Treaty Law)

សន្ធិសញ្ញាជាប់ទាក់ទងផងដែរ ចំពោះការកំណត់អំពីអត្ថិភាពនៃច្បាប់ទំនៀមទំលាប់អន្តរជាតិដោយសារវាជួយបំភ្លឺថាតើរដ្ឋគិតថាវិធានមួយចំនួនរបស់ច្បាប់ទំនៀមទំលាប់អន្តរជាតិយ៉ាងដូចម្តេច ។ អាស្រ័យហេតុនេះការផ្តល់សច្ចាប័នការបកស្រាយ និងការប្រតិបត្តិតាមសន្ធិសញ្ញារាប់បញ្ចូលការចុះខរក្សា និងសេចក្តីថ្លែងការបកស្រាយដែលធ្វើឡើងក្រោយពេលផ្តល់សច្ចាប័នត្រូវបានរាប់បញ្ចូលក្នុងការសិក្សានេះ ។

ក្នុងរឿងក្តី North Sea Continental Shelf តុលាការយុត្តិធមិអន្តរជាតិបានពិចារណាយ៉ាងច្បាស់ថា កំរិតនៃការធ្វើសច្ចាប័ននៃសន្ធិសញ្ញាមួយគឺពាក់ព័ន្ធដល់ការពិចារណាជាច្បាប់ទំនៀមទំលាប់អន្តរជាតិ ។ ក្នុងក្តីក្តាំនេះ តុលាការបានថ្លែងថា: ចំនួននៃការផ្តល់សច្ចាប័ន និងការទទួលយកមកដល់ពេលនេះមានចំនួន (សាមសិបប្រាំបួន) បើពិចារណាអោយបានហ្មត់ចត់វាពិបាកចាត់ថាគ្រប់គ្រាន់ណាស់ ជាពិសេសក្នុងបរិបទដែលមានការអនុវត្តខាងក្រៅសន្ធិសញ្ញាមានភាពប្រទឹងប្រទើស ។[២៣] និយាយបញ្ច្រាសមកវិញនៅក្នុងរឿងក្តីនីការ៉ាហ្គ័រ តុលាការបានផ្តល់ទំងន់យ៉ាងខ្លាំងដោយផ្អែកលើអង្គហេតុថា ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិត្រូវបានផ្តល់សច្ចាប័នស្ទើរទូទាំងសកលលោកនៅពេលពិចារណាឋានៈជាទំនៀមទំលាប់របស់វិធានរារាំងការធ្វើការអន្តរាគមន៍ ។[២៤] វាអាចជាករណីដែលបទបញ្ញត្តិសន្ធិសញ្ញាឆ្លុះបញ្ចាំងច្បាប់ទំនៀមទំលាប់ ទោះបីជាសន្ធិសញ្ញានោះមិនទាន់ចូលជាធរមានក្តីអោយតែមានការអនុវត្តស្រដៀងគ្នា គឺមានភាពគ្រប់គ្រាន់ដោយរាប់បញ្ចូលជាពិសេសរដ្ឋប៉ះពាល់ ដើម្បីបង្ហាញថានៅមានកំរិតតិចតួចនៃការ ជំទាស់ដល់វិធានដែលកំពុងនិយាយយោងដល់ ។[២៥]

តាមការអនុវត្តការធ្វើសេចក្តីព្រាងវិធាននៃសន្ធិសញ្ញា ជួយផ្តោតទស្សនៈច្បាប់ជាសាកលព្រមទាំងការជះឥទ្ធិពលមិនអាចប្រកែកបានលើអាកប្បកិរិយាមានជាក្រោយ និងជំនឿចាត់ថាជាច្បាប់របស់រដ្ឋ ។ តុលាការយុត្តិធមិអន្តរជាតិបានទទួលស្គាល់ដូចនេះ ក្នុងសាលក្រមរបស់ខ្លួនក្នុងរឿងក្តី Continental Shelf ដែលនៅក្នុងនោះតុលាការបាននិយាយថា:សន្ធិសញ្ញាពហុភាគីអាចមានតួនាទីសំខាន់ក្នុងការចងក្រង និងផ្តល់ន័យដល់វិធានដែលទាញចេញពីទំនៀមទំលាប់ ឬជាក់ស្តែងក្នុងការអភិវឌ្ឍវិធាន ។[២៦] ផ្អែកតាមនេះ តុលាការបានបញ្ជាក់ថា សន្ធិសញ្ញាអាចចងក្រងច្បាប់ទំនៀមទំលាប់អន្តរជាតិដែលមានពីមុនមក ហើយក៏ផ្តល់ជាមូលដ្ឋានផងដែរសំរាប់ការបង្កើតទំនៀមទំលាប់ថ្មីផ្អែកទៅតាមវិធានដែលត្រូវបានចែងនៅក្នុងសន្ធិសញ្ញាទាំងនោះ ។ តុលាការថែមទាំងថ្លែងជាបន្ថែមទៀតថា: វាយអាចថា...ការចូលនីមួយៗដែលមានលក្ខណៈទូទៅ និងជាតំណាង(គ្រប់ទ្វីប) នៅក្នុងសន្ធិសញ្ញាអាចមានភាពគ្រប់គ្រាន់រួចហើយឱ្យតែការចូលរួមនោះបានរាប់បញ្ចូលការចូលរួមរបស់រដ្ឋដែលប្រយោជន៏របស់ខ្លួនត្រូវបានប៉ះពាល់ជាពិសេស ។[២៧]

23 International Court of Justice, North Sea Continental Shelf cases, op. cit. (note 7), p. 42, § 73.

24 International Court of Justice, Case concerning Military and Paramilitary Activities in and against Nicaragua , op. cit. (note 12), pp. 99-100, §188. Another important factor in the decision of the Court was that relevant UN General Assembly resolutions had been widely approved, in particular Resolution 1625 (XXV) on friendly relations between States, which was adopted without a vote.

25 International Court of Justice, Continental Shelf case, op. cit. (note 6), p. 33, § 34. (The Court considered that the concept of an exclusive economic zone had become part of customary international law, even though the United Nations Convention on the Law of the Sea had not yet entered into force, because the number of claims to an exclusive economic zone had arisen to 56, which included sveral specially affected States.)

26 International Court of Justice, Continental Shelf case, op. cit. (note 6), pp. 29-30, § 27.

27 International Court of Justice, North Sea Continental Shelf cases, op. cit. (note 7), p. 42, § 73; see also ILA Report, op. cit. (note 13), Principles 20-21, 24, 26 and 27, pp. 754-765.

ការសិក្សានេះបានប្រកាន់យកផ្លូវដើរដ៏ប្រយ័ត្នប្រយែងថា ការផ្តល់សច្ចាប័នជាទូទៅជាសញ្ញាណតែមួយប៉ុណ្ណោះ ហើយត្រូវតែបានពិចារណាទាក់ទងដល់ធាតុផ្សំដទៃទៀតនៃការអនុវត្ត ជាពិសេសការអនុវត្តរបស់រដ្ឋមិនមែនជាភាគីសន្ធិសញ្ញាដែលកំពុងនិយាយយោងដល់។ ការអនុវត្តដ៏ស៊ីសង្វាក់ (ដូចគ្នា) របស់រដ្ឋមិនមែនជាភាគីត្រូវបានពិចារណា ថាជាភស្តុតាងវិជ្ជមាន និងមានសារសំខាន់។ ក៏ប៉ុន្តែការអនុវត្តខុសគ្នារបស់រដ្ឋមិនមែនជាភាគី ក៏ត្រូវបានចាត់ទុកជាភស្តុតាងអវិជ្ជមានដ៏សំខាន់ផងដែរ។ ការអនុវត្តរបស់រដ្ឋជាភាគីរបស់សន្ធិសញ្ញា ក្នុងទំនាក់ទំនងជាមួយរដ្ឋមិនមែនជាភាគីមានភាពទាក់ទងជាសំខាន់ផងដែរ។

ដូច្នេះការសិក្សានេះ មិនបានកំរិតចំពោះតែរដ្ឋមិនមែនជាភាគីរបស់សន្ធិសញ្ញាស្តីពីច្បាប់មនុស្សធម៌អន្តរជាតិឡើយ។ការកំរិតការសិក្សាដល់ការពិចារណាការអនុវត្តនៃរដ្ឋ៣០តែប៉ុណ្ណោះ ដែលមិនបានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែម (ឧទាហរណ៍) នឹងមិនស្របតាមការទាមទារដែលថាច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវផ្អែកតាមការអនុវត្តជាគំរូ និងទូទៅឡើយ។ ដូចនេះការពិចារណាអត្ថិភាពនៃច្បាប់ទំនៀមទំលាប់ដែលត្រូវតែបានគិតថានៅពេលដែលការសិក្សានេះត្រូវបានបោះពុម្ព ពិធីសារបន្ថែមទី I ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋចំនួន ១៦២ ហើយពិធីសារបន្ថែមទី II មានរដ្ឋចំនួន ១៥៧ ផ្តល់សច្ចាប័ន។

គេគួរសង្កត់ធ្ងន់ថាការសិក្សានេះ មិនបានស្វះស្វែងដើម្បីកំណត់នូវចរិតលក្ខណៈប្រភេទជាទំនៀមទំលាប់នៃវិធានចែងក្នុងសន្ធិសញ្ញាស្តីពីច្បាប់មនុស្សធម៌អន្តរជាតិឡើយ ហើយជាលទ្ធផលវាមិនចាំបាច់ធ្វើតាមទំរង់នៃសន្ធិសញ្ញាដែលមានស្រាប់ទេ។ ជំនួសមកវិញការសិក្សានេះនឹងវិភាគបញ្ហាដើម្បីបង្ហាញថាវិធានអ្វីនៃច្បាប់ទំនៀមទំលាប់អន្តរជាតិអាចត្រូវបានរកឃើញផ្អែកតាមការអនុវត្តរបស់រដ្ឋដែលពាក់ពន្ធ័ដល់បញ្ហាទាំងនោះ។ ដោយសារវិធីសាស្ត្រដែលត្រូវបានជ្រើសរើស មិនបានវិភាគលើបទបញ្ញត្តិសន្ធិសញ្ញានីមួយៗ ក្នុងគោលបំណងកំណត់ថាតើវាជា ឬមិនមែនជាទំនៀមទំលាប់គេមិនអាចសន្និដ្ឋានថាវិធានក្នុងសន្ធិសញ្ញាជាក់លាក់ណាមួយមិនមែនជាទំនៀមទំលាប់ ដោយគ្រាន់តែដោយសារវាមិនបានឃើញមាននៅក្នុងការសិក្សានេះឡើយ ។

## ការរៀបចំដំណើរការសិក្សា (Organization of the Study)

ដើម្បីធ្វើការសិក្សាឱ្យបានល្អបំផុតក្នុងការបំពេញកិច្ចការឱ្យ ICRC អ្នកនិពន្ធបានពិភាក្សាជាមួយក្រុមអ្នក ជំនាញខាងសិក្សា និងស្រាវជ្រាវច្បាប់មនុស្សធម៌អន្តរជាតិ ដែលស្ថិតនៅក្នុងគណៈកម្មាធិការដឹកនាំការសិក្សានេះ។[២៨] គណៈកម្មាធិការនេះបានអនុម័តផែនការសកម្មភាពក្នុងខែមិថុនា ១៩៩៦ ហើយការស្រាវជ្រាវបានចាប់ ផ្តើមនៅខែតុលាបន្ទាប់។ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើប្រាស់ទាំងប្រភពជាតិ និងអន្តរជាតិដែល បង្ហាញពីការអនុវត្តរបស់រដ្ឋ ហើយត្រូវបានផ្តោតលើចំនុចចំនួន៦ ដែលត្រូវបានកំណត់ក្នុងផែនការសកម្មភាព:

- គោលការណ៍បែងចែកដាច់ដោយឡែក
- កិច្ចការពារជាពិសេសចំពោះប្រភេទមនុស្ស និងវត្ថុ
- វិធីសាស្ត្រជាក់លាក់ក្នុងការធ្វើសង្គ្រាម
- សព្វាវុធ –អាវុធយុទ្ធភណ្ឌ
- ការប្រព្រឹត្តលើជនស៊ីវិល និងបុគ្គលដែលទំលាក់អាវុធ (hors de combat)
- ការប្រតិបត្តិ

28 The Steering Committee consisted of Professors Georges Abi-Saab, Salah El-Din Amer, Ove Bring, Eric David, John Dugard, Florenito Feliciano Fischer, Francoise Hampson, Theodor Meron, Djamchid Momtaz, Milan Sahovic and Raul Emilio Vinuesa.

## ការស្រាវជ្រាវពីប្រភពជាតិ (Research in National Sources)

ត្បិតដោយសារប្រភពធនធានជាតិអាចរកបានយ៉ាងងាយស្រួលពីក្នុងប្រទេស ការសិក្សានេះត្រូវបានសំរេចសុំកិច្ចសការពីអ្នកស្រាវជ្រាវក្នុងស្រុក/ជាតិជាច្រើន។ ដើម្បីសំរេចបំណងនេះអ្នកស្រាវជ្រាវម្នាក់ ឬក្រុមអ្នកស្រាវជ្រាវត្រូវបានជ្រើសរើសក្នុងរដ្ឋចំនួនប្រហែល៥០ (៩រដ្ឋក្នុងទ្វីបអាហ្វ្រិច ១១ក្នុងទ្វីបអាមេរិក ១៥ក្នុងទ្វីបអាស៊ី ១ក្នុងទ្វីបអូស្ត្រាលី និង ១១ក្នុងទ្វីបអឺរ៉ុប) ហើយត្រូវបានស្នើឱ្យបង្កើតនូវរបាយការណ៍ស្តីពីការអនុវត្តរបស់រដ្ឋរបស់ពួកគេដោយឡែក១ពីគ្នា។[២៩] ប្រទេសត្រូវបានជ្រើសរើស ផ្អែកទៅតាមតំណាងតាមភូមិសាស្ត្រព្រមទាំងការពើបប្រទះថ្មី១នៃប្រភេទខុសគ្នានៃជម្លោះប្រដាប់អាវុធដែលនៅក្នុងនោះវិធីសាស្ត្រធ្វើសង្គ្រាមដែលបានប្រើប្រាស់។

ក្បួនសឹកសង្គ្រាម ព្រមទាំងច្បាប់ជាតិនៃប្រទេស ដែលមិនបានលើកបង្ហាញក្នុងរបាយការណ៍ត្រូវបានស្រាវជ្រាវ និងប្រមូលចងក្រងបន្ថែមផងដែរ។ ការងារនេះត្រូវបានសម្រួលតាមរយៈបណ្តាញរបស់គណៈប្រតិភូ ICRC នៅពាសពេញពិភពលោក ហើយការប្រមូលផ្តុំសន្និកសន្ទាប់នៃច្បាប់ជាតិ គឺប្រមូលដោយសេវាកម្មប្រឹក្សាយោបល់ ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិរបស់ ICRC ។

## ការស្រាវជ្រាវពីប្រភពអន្តរជាតិ (Research in International Sources)

ការអនុវត្តរបស់រដ្ឋទាញចេញពីប្រភពអន្តរជាតិ ត្រូវបានប្រមូលដោយក្រុមចំនួន ៦។ ក្រុមនីមួយ១ ផ្តោតលើកម្មវត្ថុទាំង៦ដែលបានលើកឡើងក្នុងការសិក្សានេះ។[៣០] ក្រុមទាំងនេះបានស្រាវជ្រាវការអនុវត្តក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀតរាប់បញ្ចូលទាំងសហព័ន្ធអាហ្វ្រិច ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ ក្រុមប្រឹក្សាអឺរ៉ុប សហភាពអឺរ៉ុប សហព័ន្ធប្រទេសអារ៉ាប់ អង្គការរដ្ឋអាមេរិក អង្គការនៃជំនួបប្រជុំរដ្ឋអ៊ីស្លាម Organization of the Islamic Conference និងអង្គការដើម្បីសន្តិសុខ និងសហប្រតិបត្តិការក្នុងអឺរ៉ុប។ យុត្តិសាស្ត្រអន្តរជាតិក៏ត្រូវបានប្រមូលចងក្រងអោយតែវាបានផ្តល់ជាភស្តុតាងនៃអត្ថិភាពវិធាន ច្បាប់ទំនៀមទំលាប់អន្តរជាតិ។

## ការស្រាវជ្រាវពីឯកសាររបស់ ICRC

ដើម្បីបំពេញបន្ថែមលើការស្រាវជ្រាវធ្វើឡើងក្នុងប្រភពជាតិ និងអន្តរជាតិ ICRC បានពិនិត្យមើលកំរងឯកសាររបស់ខ្លួន

29 Africa: Algeria, Angola, Botswana, Egypt, Ethiopia, Nigeria, Rwanda, South Africa and Zimbabwe; Americas: Argentina, Brazil, Canada, Chile, Colombia, Cuba, El Salvador, Nicaragua, Peru, United States of America and Uruguay; Asia: China, India, Indonesia, Iran, Iraq, Israel, Japan, Jordan, Republic of Korea, Kuwait, Lebanon, malaysia, Pakistan, Philippines and Syria; Australasia: Australia; Europe: Belgium, Bosnia and Herzegovina, Croatia, France, Germany, Italy, Netherlands, Russian Federation, Spain, United Kingdom and Yugoslavia.

30 Principle of distintion: Professor Georges Abi-Saab (rapporteur) and Jean-Francois Quwguiner (researcher); Specifically protected persons and objects : Professor Horst Fischer (rapporteur) and Gregor Schotten and Heike Spieker (researcher); Specific methods of warfare: Professor Theodor Meron (rapporttteur) and Richard Desgagne (researcher); Weapons: Professor Ove Bring (rapporteur) and Gustaf Lind (researcher); Treatment of civilians and persons hors de combat: Francoise Hampson (rapporteur) and Camille Giffard (researcher); Implementation: Eric David (rapporteur) and Richard desgagne (researcher).

ទាក់ទងដល់ជម្លោះប្រដាប់អាវុធថ្មីៗចំនួនជិត៤០ (២១ក្នុងទ្វីបអាហ្វ្រិច, ២ក្នុងទ្វីបអាមេរិក, ៨ក្នុង ទ្វីបអាស៊ី និង៨ក្នុងទ្វីបអឺរ៉ុប)។[៣១] ជាទូទៅជម្លោះទាំងនេះត្រូវបានជ្រើសរើសពីប្រទេសទាំងនោះ និងជម្លោះដែល មិនត្រូវបានធ្វើឡើងតាមរយៈរបាយការណ៍ស្តីពីការអនុវត្តរបស់រដ្ឋត្រូវបានយកមកពិនិត្យសិក្សាផងដែរ។

ជាលទ្ធផលនៃវិធីសាស្ត្រទាំងបីមុខព្រួញនេះ ការស្រាវជ្រាវពីប្រភពជាតិ ប្រភពអន្តរជាតិ និងពីប្រភពរបស់ ICRC មានន័យថា ការអនុវត្តពីគ្រប់ផ្នែកនៃពិភពលោកត្រូវបានដកស្រង់មកពិនិត្យសិក្សា។ ក៏ប៉ុន្តែកិច្ចការសិក្សាស្រាវជ្រាវនេះមិនអាចអះអាងថាពេញលេញឡើយ គឺនៅមានចន្លោះប្រហោង។ ការសិក្សាបានផ្តោតជាពិសេស លើការអនុវត្តទាញចេញពីរយៈពេល៣០ឆ្នាំចុងក្រោយ ដើម្បីធ្វើឱ្យប្រាកដថាលទ្ធផលរបស់វា គឺជាការអះអាងឡើងវិញនៃច្បាប់ទំនៀមទំលាប់ទាន់សម័យមួយហើយការអនុវត្តតាំងពីយូរមកហើយក៏ត្រូវបានស្រង់ផងដែរ។

## ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ (Expert Consultations)

ក្នុងជុំទីមួយនៃកិច្ចពិគ្រោះយោបល់ ICRC បានអញ្ជើញក្រុមអ្នកស្រាវជ្រាវច្បាប់អន្តរជាតិឱ្យធ្វើសេចក្តី បង្ហាញសង្ខេបរួមបញ្ចូលការពិចារណាជាបឋមនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលមានឋានៈជាច្បាប់ទំនៀមទំលាប់ដោយផ្អែកលើការអនុវត្តដែលត្រូវបានប្រមូល។ សេចក្តីបង្ហាញសង្ខេបទាំងនេះ ត្រូវបានពិភាក្សាជាមួយគណៈកម្មាធិការដឹកនាំនៅឯកិច្ចប្រជុំចំនួន៣ធ្វើនៅហ្សឺណែវក្នុងឆ្នាំ១៩៩៨។ សេចក្តីបង្ហាញសង្ខេបត្រូវបានកែសំរួលយ៉ាងហ្មត់ចត់ ហើយក្នុងអំឡុងពេលការជុំទី២នៃកិច្ចពិគ្រោះយោបល់ ត្រូវបានដាក់ជូនដល់ក្រុមជំនាញការរបស់រដ្ឋាភិបាល និងស្រាវជ្រាវមកពីគ្រប់ទ្វីបទាំងអស់របស់ពិភពលោក។ អ្នកជំនាញការទាំងនេះ ត្រូវបានអញ្ជើញក្នុងនាមជាបុគ្គលផ្ទាល់ខ្លួនដោយ ICRC ឱ្យចូលរួមកិច្ចប្រជុំចំនួនពីរជាមួយគណៈកម្មាធិការដឹកនាំនៅក្រុងហ្សឺណែវក្នុងឆ្នាំ១៩៩៩ ដែលនៅក្នុងពេលនោះពួកគេបានជួយវាយតំលៃលើការអនុវត្តដែលប្រមូលបាន ព្រមទាំងចង្អុលបង្ហាញការអនុវត្តជាពិសេសដែលត្រូវបានមើលរំលងនៅក្នុងការសិក្សាស្រាវជ្រាវនេះ។ [៣២]

## ការសរសេររបាយការណ៍ (Writing of the Report)

ការពិចារណាវាយតំលៃដោយគណៈកម្មាធិការនារាយក ក៏ដូចជាបានពិនិត្យសិក្សាជាថ្មីឡើងវិញដោយក្រុមអ្នកជំនាញ

31 Africa: Angola, Burundi, Chad, Chad-Lybia, Democratic Republic of the Congo, Djibouti, Eritrea-Yemen, Ethiopia (1973-1994); Liberia, Mozambique, Namibia, Nigeria-Cameroon, Rwanda, Senegal, Senegal-Mauritania, Sierra Leone, Somalia, Somalia-Ethiopia, Sudan, Uganda and Western Sahara; Americas: Guatemala and Mexico; Asia: Afganistan, Cambodia, India (Jammu and Kashir), Papua New Guinea, Sri Lanka, Takijistan, Yemen and Yemen-Eritrea (also under Africa); Europe: Armenia-Azerbaijan (Nagorno-Karabakh), Cyprus, Former Yugoslavia (conflict in Yugoslavia (1991-1992), conflict in Bosnia and Herzegovina (1992-1996), conflict in Croatia (Krajina) (1992-1995)), Georgia (Abkhazia), Russian Federation (Chechnya) and Turkey.

32 The following academic and governmental experts participated in their personal capacity in this consultation: Abdallah Ad-Douri (Iraq), Paul Berman (United Kingdom), Sadi Caycy (Turkey), Michael Cowling (South Africa), Edward Cummings (United States of America), Antonio de Icaza (Mexico), Yoram Dinstein (Israel), Jean-Michael Favre (France), William Fenrick (Canada), Dieter Fleck (Germany), Juan Carlos Gomez Ramirez (Colombia), Jamshed A. Hamid (Pakistan), Arturo Hernandez- Basave (Mexico), Ibrahim Idriss (Ethiopia), Hassan Kassem Jouni (Lebanon), Kenneth Keith (New Zealand), Githu Muigai (Kenya), Rein Mullerson (Estonia), Bara Niang (Senegal), Mohamed Olwan (Jordan), Raul C. Pangalangan (Philippines), Stelios Perrakis (Greece), Paulo Sergio Pinheiro (Brazil), Arpad Prandler (Hungary), Pemmaraju Sreenivasa Rao (India), Camilo Reyes Rodriguez (Colombia), Itse E. Sagay (Nigeria), Harold Sandoval (Colombia), Somboon Sangianbut (Thailand), Marat A. Sarsembayev (Kazakhstan), Muhammad Aziz Shukri (Syria), Parlaungan Sihombing (Indonesia), Geoffrey James Skillen (Australia), Guoshun Sun (China), Bakhtyar Tuzmukhamedov (Russia) and Karol Wolfke (Poland).

ការរដ្ឋាភិបាល និងក្រុមអ្នកសិក្សាស្រាវជ្រាវ គឺជាមូលដ្ឋានសំរាប់ការសរសេររបាយការណ៍ចុងក្រោយ។ អ្នកនិពន្ធនៃការសិក្សានេះបានពិនិត្យឡើងវិញនូវការអនុវត្តការពិចារណាវាយតំលៃ (assess) ជាថ្មីនូវអត្ថិភាពនៃទំនៀមទំលាប់ពិនិត្យជាថ្មីឡើងវិញនូវទំរង់ និងលំដាប់លំដោយនៃវិធានព្រមទាំងបានធ្វើពង្រាងសេចក្តីអធិប្បាយ។ អត្ថបទសេចក្តីព្រាងទាំងនេះត្រូវបានដាក់ជូនដល់គណៈកម្មាធិការនាយកអ្នកជំនាញការរដ្ឋាភិបាល និងក្រុមអ្នកសិក្សាស្រាវជ្រាវក្រុមអ្នកច្បាប់របស់ ICRC ដើម្បីផ្តល់យោបល់។ អត្ថបទត្រូវបានកែសំរួលបន្ថែម និងធ្វើបញ្ចប់ដោយពិចារណាយ៉ាងម៉ត់ចត់លើយោបល់ដែលទទួលបាន។

## សេចក្តីសង្ខេបស្តីពីគំហើញនៃការសិក្សា (Summary of Findings)

ចំនួនដ៏លើសលុបរបស់បទបញ្ញត្តិនៃអនុសញ្ញាហ្សឺណែវ រាប់បញ្ចូលមាត្រារួមទី៣ ត្រូវបានចាត់ថា ជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ។[៣៣] បច្ចុប្បន្ននេះ មានរដ្ឋចំនួន១៩២ ដែលចូលជាភាគីនៃអនុសញ្ញាហ្សឺណែវ ហើយអនុសញ្ញាទាំងនេះបានចងកាតព្វកិច្ចដល់រដ្ឋស្ទើរទាំងអស់ក្នុងនាមជារដ្ឋភាគី។ ដូចនេះចរិតជាទំនៀមទំលាប់នៃបទបញ្ញត្តិនៃអនុសញ្ញាទាំងនេះមិនស្ថិតនៅក្រោមការសិក្សានេះទេ។ ប៉ុន្តែការសិក្សាផ្តោតលើបញ្ហាដែលបាន ចែងដោយសន្ធិសញ្ញាហើយមិនត្រូវបានផ្តល់សច្ចាប័នជាសាកលជាពិសេសនេះ គឺពិធីសារបន្ថែមសន្ធិសញ្ញា Hague សំរាប់ការការពារសម្បត្តិវប្បធម៌ និងសន្ធិសញ្ញាមួយចំនួនផ្សេងទៀតដែលពាក់ពន្ធ័អំពីការប្រើប្រាស់សព្វាវុធ។

សេចក្តីបរិយាយខាងក្រោមពីវិធានច្បាប់ទំនៀមទំលាប់អន្តរជាតិ មិនធ្វើការបកស្រាយហេតុអ្វីវិធានទាំងនេះត្រូវបានរកឃើញថាជាទំនៀមទំលាប់ឡើយ ហើយក៏មិនបកស្រាយលើការអនុវត្តដែលបានរកឃើញនៅក្នុងសេចក្តីសន្និដ្ឋាននេះដែរ។ ការពន្យល់អំពីហេតុអ្វីវិធានមួយណាត្រូវបានពិចារណាជាទំនៀមទំលាប់អាចត្រូវបានឃើញមានក្នុងភាគទី១ នៃការសិក្សានេះ ចំណែកឯការអនុវត្តដែលពាក់ព័ន្ធអាចឃើញមាននៅក្នុងភាគទី ២។

## ជំម្លោះប្រដាប់អាវុធអន្តរជាតិ (International Armed Conflicts)

ពិធីសារបន្ថែមទីមួយ បានចងក្រងនូវវិធានច្បាប់ទំនៀមទំលាប់អន្តរជាតិ ដែលមានពីមុនៗមកហើយវាក៏នៅបន្តធ្វើជាមូលដ្ឋានសំរាប់បង្កើតវិធានទំនៀមទំលាប់ថ្មីផងដែរ។ ការអនុវត្តដែលប្រមូលបានមកក្នុងក្របខ័ណ្ឌនៃការសិក្សានេះ បង្ហាញឱ្យឃើញនូវឥទ្ធិពលដ៏ស៊ីជំរៅនៃពិធីសារបន្ថែមទី១ លើការអនុវត្តរបស់រដ្ឋ (សូមមើលខាងក្រោម)។ មួយវិញទៀត ការសិក្សានេះ បានរកឃើញថាគោលការណ៍ចំបងនៃពិធីសារបន្ថែមទី I ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយជាងការផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមទី១ ដែលគេបានរំពឹងទៅទៀត។

ទោះបីជាការសិក្សានេះមិនបានកំណត់ចរិតជាទំនៀមទំលាប់នៃបទបញ្ញាត្តិសន្ធិសញ្ញាជាក់លាក់ចុងបញ្ចប់ នៃការសិក្សាបានបង្ហាញជាក់លាក់ថា មានវិធានជាទំនៀមទំលាប់ជាច្រើនដែលដូចគ្នា ឬស្រដៀងគ្នាជាមួយវិធានរកឃើញមាននៅក្នុងច្បាប់ចែងក្នុងសន្ធិសញ្ញា។ ឧទាហរណ៍នៃវិធានដែលរកឃើញថាជាទំនៀមទំលាប់ ហើយដែលមានបទបញ្ញត្តិពាក់ព័ន្ធនៅក្នុង

33 International Court of Justice, Legality of the Threat or Use of Nuclear Weapons, op. cit. (note 8), pp. 257-258, §§ 79 and 82 (with respect to the Geneva Convention) and Case concerning Military and Paramilitary Activities in and Against Nicaragua, op. cit. (note 12), p. 144, § 218 (with respect to common Article 3).

ពិធីសារបន្ថែមទីI រួមមាន : គោលការណ៍បែងចែងដាក់ដោយឡែករវាងជនស៊ីវិល និងកំលាំងប្រយុទ្ធរវាងវត្ថុបំរើប្រយោជន៍ជនស៊ីវិល និងទិសដៅរបស់ទាហាន[៣៤] ការហាមឃាត់ ការវាយប្រហារមិនរើសអើង[៣៥] គោលការណ៍សមមាត្រក្នុងការវាយប្រហារ[៣៦] កាតព្វកិច្ចចាត់វិធានការដើម្បីប្រយ័តប្រយែងដែលអាចធ្វើបានក្នុងការវាយប្រហារ[៣៧] កាតព្វកិច្ចគោរព និងការពារបុគ្គលិកពេទ្យនិងសាសនាអង្គភាពពេទ្យនិងដឹកជញ្ជូន[៣៨] បុគ្គលិកសង្គ្រោះមនុស្សធម៌និងសំភារៈ[៣៩] និងអ្នកសារព័ត៌មាន[៤០] កាតព្វកិច្ចការពារការងារពេទ្យ (Obligation to Protect Medical Duties) [៤១] ការហាមឃាត់ការវាយប្រហារលើទីតាំងគ្មានការការពារ និងតំបន់លែងមានប្រតិបត្តិការសឹក[៤២] កាតព្វកិច្ចផ្តល់អាហារ និងការពារសត្រូវដែលលែងមានសមត្ថភាពប្រយុទ្ធ (Enemy Hors DeCombat)[៤៣] ការហាមការបង្អត់អាហារ[៤៤] ការហាមឃាត់ការវាយប្រហារលើសំភារៈដែលចាំបាច់សំរាប់ការរស់រានមានជីវិតរបស់ប្រជាពលរដ្ឋស៊ីវិល[៤៥] ការហាមឃាត់ការប្រើប្រាស់មិនសមស្របផ្លាកសញ្ញា និងការបំភាន់[៤៦] កាតព្វកិច្ចគោរពការធានាជាមូលដ្ឋានដល់ប្រជាជនស៊ីវិល និងបុគ្គលិកដែលលែងមានសមត្ថភាពប្រយុទ្ធ (civilians and persons hors de combat) [៤៧] កាតព្វកិច្ចក្នុងការពន្យល់ការបាត់ខ្លួនមនុស្ស[៤៨] និងការការពារជាពិសេសផ្តល់ដល់ស្ត្រី និងកុមារ ។[៤៩]

## ជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (Non-International Armed Conflicts)

ក្នុងរយៈពេលជាងពីរ ឬបីទសវត្សចុងក្រោយនេះ មានចំនួនការអនុវត្តគួរអោយពិចារណាដែលទទូច អោយមានការការពារច្បាប់មនុស្សធម៌អន្តរជាតិក្នុងជម្លោះប្រដាប់អាវុធប្រភេទនេះ។ ការអនុវត្តនេះ បានជះឥទ្ធិពលជាខ្លាំងដល់ការបង្កើតច្បាប់ទំនៀមទំលាប់អនុវត្តន៏ក្នុងជម្លោះប្រដាប់អាវុធដែលមិនមែនជាអន្តរជាតិ។ ដូចគ្នានឹងពិធីសារបន្ថែមទី១ ពិធីសារបន្ថែមទី២មានឥទ្ធិពលដ៏ទូលំទូលាយលើការអនុវត្ត ហើយជាលទ្ធផលឥឡូវនេះបទប្បញ្ញត្តជាច្រើនត្រូវបានក្លាយជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ។ ឧទាហរណ៏នៃវិធានដែលត្រូវបានរកឃើញថាជាទំនៀមទំលាប់ហើយដែលមានបទប្បញ្ញត្តិទាក់ទងក្នុងពិធីសារបន្ថែមទី២រួមមាន:ការហាមឃាត់ការវាយប្រហារលើប្រជាពលរដ្ឋស៊ីវិល[៥០] កាតព្វកិច្ចគោរពនិងការពារបុគ្គលិកសាសនា និងពេទ្យអង្គភាពពេទ្យ និងការដឹកជញ្ជូន[៥១] កាតព្វកិច្ចការពារកិច្ចការងារពេទ្យ[៥២] ការហាមឃាត់ការ

34 See Customary International Humanitarian Law, op. cit. (note 4), Vol. I, Rules 1 and 7.

35 Ibid., Rules 11-13.

36 Ibid., Rule 14.

37 Ibid., Rules 15-24.

38 Ibid., Rules 25 and 27-30.

39 Ibid., Rules 31-32.

40 Ibid., Rule 34.

41 Ibid., Rule 26.

42 Ibid., Rules 36-37.

43 Ibid., Rules 46-48.

44 Ibid., Rule 53.

45 Ibid., Rule 54.

46 Ibid., Rules 57-65..

47 Ibid., Rules 87-105.

48 Ibid., Rule 117.

49 Ibid., Rules 134-137.

50 Ibid., Rule 1.

51 Ibid., Rules 25 and 27-30.

52 Ibid., Rule 26.

INTERNATIONAL REVIEW of the Red Cross

បង្អត់អាហារ[៥៣] ការហាមឃាត់ការវាយប្រហារលើសំភារៈដែលចាំបាច់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋស៊ីវិល[៥៤] កាតព្វកិច្ចគោរពការធានាជាមូលដ្ឋានដល់ប្រជាជនស៊ីវិល និងបុគ្គលដែលលែងមានសមត្ថភាពប្រយុទ្ធ[៥៥] កាតព្វកិច្ចស្រាវជ្រាវរកការពារ និងគោរពបុគ្គលិករងរបួសឈឺរងគ្រោះដោយសារកប៉ាល់លេច[៥៦] កាតព្វកិច្ចស្រាវជ្រាវរកនិងការពារអ្នកស្លាប់[៥៧] កាតព្វកិច្ចការពារមនុស្សដែលត្រូវបានគេដកហូតសិទ្ធិសេរីភាព[៥៨] ការហាមឃាត់ការបង្ខំអោយប្តូរកន្លែងនៃជនស៊ីវិល[៥៩] និងការការពារជាពិសេសផ្តល់ជូនដល់ស្ត្រី និងកុមារ ។ [៦០]

ទោះបីជាយ៉ាងនេះក្តី ការរួមចំណែកដ៏មានប្រយោជន៍បំផុតនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ ដល់ការកាត់បន្ថយនូវជម្លោះប្រដាប់អាវុធផ្ទៃក្នុង គឺថាវាបានលាតសន្ធឹងហួសពីបទបញ្ញត្តិរបស់ពិធីសារបន្ថែមទី២ ។ ជាការពិតការអនុវត្តបានបង្កើតនូវចំនួនដ៏ច្រើននៃវិធានជាទំនៀមទំលាប់ដែលមានលក្ខណៈលំអិតជាងបទបញ្ញត្តិមានស្រាប់នៅក្នុងពិធីសារបន្ថែមទី២ ហើយបានបំពេញនូវចន្លោះប្រហោងសំខាន់ៗក្នុងបទបញ្ញត្តិស្តីពីជំលោះក្នុងស្រុក ។

ជាឧទាហរណ៍ពិធីសារបន្ថែមលើកទី២ មានចែងតែបទបញ្ញត្តិចំបងៗ នៃការធ្វើសង្គ្រាម ។ មាត្រាទី១៣ បានចែងថាៈ ប្រជាជនស៊ីវិល ព្រមទាំងបុគ្គលស៊ីវិលមិនត្រូវជាកម្មវត្ថុនៃការវាយប្រហារ...ទាល់តែ ហើយសំរាប់អំឡុងពេលនោះពួកគេចូលរួមដោយផ្ទាល់ក្នុងអំពើអរិភាព ។ ខុសពីពិធីសារបន្ថែមទី១ ពិធីសារបន្ថែមទី២ មិនមានវិធានជាក់លាក់ និងនិយមន័យពាក់ព័ន្ធគោលការណ៏បែងចែកដាច់ដោយឡែក និងសមមាត្រឡើយ ។

ទោះបីជាយ៉ាងនេះក្តី ចន្លោះប្រហោងនៅក្នុងបទបញ្ញត្តិនៃការប្រព្រឹត្តទៅនៃអរិភាពនៅក្នុងពិធីសារបន្ថែមទី២ ត្រូវបានបំពេញបន្ថែមតាមរយៈការអនុវត្តរបស់រដ្ឋ ដែលនាំអោយមានការបង្កើតវិធានស្រដៀងគ្នាដូចវិធានដែលមាននៅក្នុងពិធីសារបន្ថែមទី១ ប៉ុន្តែជាច្បាប់ទំនៀមទំលាប់ដែលអនុវត្តន៏បានចំពោះជម្លោះប្រដាប់អាវុធ មិនមែនអន្តរជាតិ ។នេះរួមមានគោលការណ៏ចំបងស្តីពីការប្រព្រឹត្តអរិភាព និងរាប់បញ្ចូលវិធានស្តីពីសំភារៈ និង បុគ្គលដែលត្រូវបានការពារជាពិសេស និងវិធីសាស្ត្រជាក់លាក់នៃការធ្វើសិកសង្គ្រាម ។ [៦១]

ស្រដៀងគ្នានេះពិធីសារបន្ថែមទី២ មានចែងតែអំពីបទបញ្ញត្តិទូទៅស្តីពីកិច្ចសង្គ្រោះជាមនុស្សធម៌សំរាប់ប្រជាជនស៊ីវិលដែលត្រូវការ ។ បទបញ្ញត្តិទី១៨ កឋាខ័ណ្ឌទី២ ចែងថាៈ ប្រសិនបើប្រជាជនស៊ីវិលទទួលរងនូវភាព លំបាកធ្ងន់ធ្ងរដោយសារខ្វះការផ្តល់នូវអ្វីដែលចាំបាច់សំរាប់ការបន្តរស់រាន...កិច្ចសង្គ្រោះសំរាប់ប្រជាជនស៊ីវិល ដែលមានចរិតជាមនុស្សធម៌ និងមិនលំអៀងទាំងស្រុងហើយដែលទង្វើធ្វើនេះដោយគ្មានការបែងចែក នឹងត្រូវបានប្រកាន់យក ។ មិនដូចជាពិធីសារបន្ថែមទី១ ពិធីសារបន្ថែមទី២ មានសរសេរបញ្ចូលនូវបទបញ្ញត្តិជាក់លាក់ទាមទារឱ្យមានការគោរព និងការពារដល់បុគ្គលិក និងសំភារៈជំនួយមនុស្សធម៌ និងបង្ខំឱ្យភាគីក្នុងជំលោះអនុញ្ញាត និងសម្រួលការឆ្លងកាត់ឱ្យបានឆាប់ និងគ្មានការបង្អាក់នៃកិច្ចជួយ

53 Ibid., Rule 53.

54 Ibid., Rule 54.

55 Ibid., Rules 87-105.

56 Ibid., Rules 109-111.

57 Ibid., Rules 112-113.

58 Ibid., Rules 118-119, 121 and 125.

59 Ibid., Rule 129.

60 Ibid., Rules 134-137.

61 See, e.g., ibid., Rules 7-10 (distinction between civilian objects and military objectives), Rules 11-13 ( indiscriminate attacks), Rule 14 ( proportionality in attack), Rules 15-21 (precaution in attack); Rules 22-24 (precaution against the effects of attack); Rules 31-32 (humanitarian relief personnel and objects); Rule 34 ( civilian journalists); Rules 35-37 (protected zones); Rules 46-48 (denial of quarter); Rules 55-56 (access to humanitarian relief) and Rules 57-65 (deception).

សង្គ្រោះមនុស្សធម៌សំរាប់ប្រជាជនដែលត្រូវការ ហើយដើម្បីធានាឱ្យប្រាកដថាសេរីភាពធ្វើដំណើររបស់បុគ្គលិកសង្គ្រោះត្រូវបានអនុញ្ញាត ។ ទោះបីជាយ៉ាងនេះក្តី គេអាចអះអាងថា ការទាមទារដូចនេះមានចែងដោយប្រយោលក្នុងមាត្រា ១៨ (2) នៃពិធីសារ ។ ក៏ប៉ុន្តែការទាមទារទាំងនេះ ត្រូវបានធ្វើឱ្យក្លាយជាច្បាប់ទំនៀមទំលាប់អន្តរជាតិ អនុវត្តន៍ទាំងនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ជាលទ្ធផលនៃការអនុវត្តដូចៗគ្នាជាតំណាងនិងជាទូទៅ ។

ទាក់ទងជាមួយចំនុចនេះ គេបានកត់សំគាល់ថាខណៈដែលពិធីសារទាំងពីរទាមទារឱ្យមានការយល់ព្រមរបស់ភាគីពាក់ព័ន្ធលើសកម្មភាពសង្គ្រោះឱ្យកើតមានឡើង ។[៦២] ការអនុវត្តជាច្រើនបានមកពីការប្រមូលមិនបានចង្អុលបង្ហាញអំពីការទាមទារនេះទេ ។ ទោះបីជាយ៉ាងនេះក្តី វាមានភាពច្បាស់លាស់ថាអង្គការមនុស្សធម៌មិនអាច ធ្វើកិច្ចការបានដោយគ្មានការយល់ព្រមពីភាគីដែលពាក់ព័ន្ធបានឡើយ ។ ក៏ប៉ុន្តែការយល់ព្រមនោះ មិនត្រូវបានបដិសេធដោយផ្អែកលើមូលដ្ឋានមិនត្រឹមត្រូវឡើយ ។ ភាគីមួយត្រូវមានកាតព្វកិច្ចផ្តល់ការយល់ព្រមប្រសិនបើរកឃើញថាប្រជាជនស៊ីវិលត្រូវបានគេគំរាម បង្អត់អាហារដោយអង្គការមនុស្សធម៌ដែលផ្តល់ជំនួយសង្គ្រោះមិនលំអៀង និងមិនរើសអើងអាចកែប្រែស្ថានភាពបាន ។[៦៣] ខណៈដែលការព្រមព្រៀងអាចមិនត្រូវបានដកដោយ គ្មានមូលហេតុសមស្របការអនុវត្តទទួលស្គាល់ភាគីដែលពាក់ព័ន្ធអាចប្រើអំណាចគ្រប់គ្រងលើសកម្មភាពជួយសង្គ្រោះ ហើយបុគ្គលិកជួយសង្គ្រោះត្រូវគោរពច្បាប់ក្នុងស្រុកពាក់ព័ន្ធការចូលទៅក្នុងដែនដី និងការទាមទារផ្អែកសន្តិសុខ ដែលនៅជាធរមាន ។

## បញ្ហាមួយចំនួនតម្រូវឱ្យមានការបំភ្លឺបន្ថែម (Issues Requiring Further Clarification)

ការសិក្សានេះបានបង្ហាញផងដែរនូវបរិបទជាច្រើនដែល ការអនុវត្តមិនបានមានភាពច្បាស់លាស់ ។ ឧទាហរណ៍ខណៈដែលពាក្យ "អ្នកប្រយុទ្ធ" និង "ជនស៊ីវិល" ត្រូវបានផ្តល់ន័យយ៉ាងជាក់លាក់នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ[៦៤] នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ការអនុវត្តមិនមានភាពប្រាកដប្រជាទាក់ទិនទៅនឹងបញ្ហាថា តើសំរាប់បំណងនៃការបង្ករអរិភាពសមាជិកនៃក្រុមប្រដាប់អាវុធប្រឆាំង ត្រូវបានរាប់ជាកងកំលាំងទ័ពឬជនស៊ីវិល ។ ជាពិសេសវាមិនច្បាស់លាស់ថា តើសមាជិកក្រុមប្រដាប់អាវុធប្រឆាំងគឺជាជនស៊ីវិលដែលបាត់បង់ការការពារពីការវាយប្រហារនៅពេលដែលចូលរួមដោយផ្ទាល់នៅក្នុងអរិភាព ឬ ថាតើសមាជិកនៃក្រុមនោះទទួលខុសត្រូវលើការវាយប្រហារយ៉ាងដូចម្តេច ។ ភាពមិនច្បាស់លាស់នេះ ត្រូវបានឆ្លុះបញ្ចាំងផងដែរក្នុងច្បាប់ចែងក្នុងសន្ធិសញ្ញា ។ ពិធីសារបន្ថែមទី២ ជាឧទាហរណ៍មិនបានចែងអំពីន័យរបស់ពាក្យ "ជនស៊ីវិល" ឬ ន័យរបស់ប្រជាជនស៊ីវិលទោះបីពាក្យទាំងនេះត្រូវបានប្រើនៅក្នុងបទបញ្ញត្តិជាច្រើន ។[៦៥] សន្ធិសញ្ញាធ្វើឡើងនៅពេលបន្ទាប់មក ដែលអនុវត្តចំពោះជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ គឺស្រដៀងគ្នានឹងការប្រើប្រាស់ពាក្យ "ជនស៊ីវិល" និង "ប្រជាជនស៊ីវិល" ដោយមិនបានវែកញែកនូវនិយមន័យពាក្យទាំងពីរនៅឡើយ ។[៦៦]

62 See Additional Protocol I, Article 70 (1) and Additional Protocol II, Article 18 (2).

63 See Yves Sandoz, Christophe Swinarski, Bruno Zimmermann (eds.), Commentary on the Additional Protocols, ICRC, Geneva, 1987, §4885; see also §2805.

64 See Customary International Humanitarian Law, op. cit. (note 4), Vol. I, Rule 3 (combatants), Rule 4 (armed forces) and Rule 5 (civilains and civilian population).

65 Additional Protocol II, Articles 13-15 and 17-18.

66 See, e.g., Amended Protocol II to the Convention on Certain Conventional Weapons, Articles 3(7)- (11); Protocol III to the Convention on Certain Conventional Weapons, Article 2; Ottawa Convention on the Prohibition of Anti-personnel Mines, preambles; Statute of the International Criminal Court, Article 8(2)(e)(i), (iii) and (viii).

ម៉្យាងទៀតដោយសារតែគ្មានការបញ្ជាក់ច្បាស់លាស់អំពីនិយមន័យនៃពាក្យ "ចូលរួមដោយផ្ទាល់ក្នុងជម្លោះ" នោះមានការលំបាកក្នុងការដាក់កំរិតទៅលើជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនមែនអន្តរជាតិ។ ការបាត់បង់ការការពារទល់នឹងការវាយប្រហារវាច្បាស់លាស់ ហើយមិនអាចតវ៉ាបាននៅពេលដែលជនស៊ីវិលប្រើប្រាស់កាំភ្លើង ឬ មធ្យោបាយដទៃទៀតដើម្បីប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស ឬសំភារៈរបស់កំលាំងសត្រូវ។ ទោះបីជាយ៉ាងនេះក្តីមានការអនុវត្តជាច្រើនផងដែរដែលមិនសូវបានផ្តល់ការណែនាំចំពោះការបកស្រាយទៅលើពាក្យ "ការចូលរួមដោយផ្ទាល់" ឧទាហរណ៍ដែលចែងថាការវាយតំលៃអាចត្រូវបានធ្វើឡើងតាមករណីនីមួយៗ ឬដោយគ្រាន់តែចែងជាដដែលៗ យ៉ាងសាមញ្ញនូវវិធានទូទៅដែលការចូលរួមដោយផ្ទាល់ក្នុងជម្លោះ ជាកត្តាដែលបង្កឱ្យជនស៊ីវិលបាត់បង់ការការពារទប់នឹងការវាយប្រហារ។ សំនួរពាក់ព័ន្ធបញ្ហានេះគឺថា តើត្រូវចាត់ប្រភេទបុគ្គលិកណាមួយយ៉ាងដូចម្តេចនៅពេលមានមន្ទិលសង្ស័យ។ ICRC កំពុងធ្វើការបញ្ជាក់នូវសញ្ញាណនៃពាក្យ ការចូលរួមដោយផ្ទាល់ តាមរយៈ អង្គប្រជុំជាច្រើនរបស់អ្នកជំនាញការដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០៣ ត្បិតមានភាពមិនច្បាស់លាស់នេះ។[៦៧]

បញ្ហាមួយផ្សេងទៀត ដែលបង្ករឱ្យមានជាសំនួរគឺវិសាលភាព និងការអនុវត្តជាក់លាក់របស់គោលការណ៍សមមាត្រនៅពេលវាយប្រហារ។ ខណៈដែលការសិក្សានេះរកឃើញនូវការគាំទ្រជាទូទៅលើគោលការណ៍នេះ វាមិនបានផ្តល់ការបំភ្លឺជាបន្ថែមជាងអ្វីដែលមានចែងនៅក្នុងសន្ធិសញ្ញាទាក់ទងដល់របៀប ឬវិធីថ្លឹងថ្លែងរវាងប្រយោជន៍ខាងយោធា និងការខាតបង់ផ្នែកស៊ីវិលដែលកើតមានឡើង។

## បញ្ហាដែលត្រូវបានជ្រើសរើសពាក់ព័ន្ធការធ្វើសង្គ្រាម (Selected Issues on the Conduct of Hostilities )

ពិធីសារបន្ថែមទី I និងទី II បានបង្ហាញនូវវិធានថ្មី ដែលហាមឃាត់ការវាយប្រហារលើកន្លែងការងារ និងកន្លែងដែលទុកដាក់សំភារៈគ្រោះថ្នាក់ សូម្បីនៅទីកន្លែងដែលវត្ថុទាំងនេះបំរើគោលដៅទាហាន ប្រសិនបើការវាយប្រហារអាចបង្ករនូវការបញ្ចេញសំភារៈគ្រោះថ្នាក់ ដែលបណ្តាលឱ្យមានការបាត់បង់ជីវិតជនស៊ីវិល។[៦៨] ក្នុងដំណាក់កាលដែលមិនច្បាស់លាស់ថាបទបញ្ញត្តិជាក់លាក់ទាំងនេះ បានក្លាយជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់ ឬក៏អត់តាមការអនុវត្តជាក់ស្តែងកន្លងមកបង្ហាញថាភាគីជំលោះនីមួយៗ បានដឹងជាមុនហើយ នូវទំហំនៃការបាត់បង់ខូចខាតដែលជាលទ្ធផលនៃការប្រយុទ្ធគ្នាប្រឆាំងទៅនឹងទីតាំងនានានិងសមិទ្ធិផលនានានៅពេលដែលគេកំណត់ថា ជាគោលដៅយោធាដែលត្រូវតែធ្វើការវាយប្រហារ។ ដូចនេះរដ្ឋបានទទួលស្គាល់ថា ក្នុងជំលោះប្រដាប់អាវុធណាមួយ ការប្រុងប្រយ័ត្នជាពិសេសត្រូវបានប្រកាន់យក ក្នុងករណីមានការវាយប្រហារដើម្បីបញ្ចៀសនូវការបញ្ចេញសំភារៈគ្រោះថ្នាក់ និងការបាត់បង់ធ្ងន់ធ្ងរកើតមានជា បន្ទាប់ក្នុងចំណោមប្រជាជនស៊ីវិល ហើយការទាមទារនេះត្រូវបានរកឃើញថា ជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិអនុវត្តនៅក្នុងជំលោះប្រដាប់អាវុធទាំងអស់។

វិធានថ្មីមួយទៀតត្រូវបានបង្ហាញនៅក្នុងពិធីសារបន្ថែមទី I គឺថាការហាមឃាត់ការប្រើប្រាស់នៃវិធីសាស្ត្រ ឬមធ្យោបាយដែលមានបំណង ឬអាចត្រូវបានរំពឹងបង្ករឱ្យមានការខូចខាតធ្ងន់ធ្ងរយូរអង្វែង និងជាទូទៅដល់បរិស្ថានធម្មជាតិ។ ចាប់តាំង

67 See, e.g., Direct Participation in Hostilities under the International Humanitarian Law: Report prepared by the International Committee of the Red Cross, Geneva, September 2003, available on www.icrc.org.

68 Additional Protocol I, Article 56 (1) (followed, however, by exceptions in paragraph 2) and Additional Protocol II, Article 15 (with no exceptions).

ពីការអនុម័តពិធីសារបន្ថែមទី។ ការហាមឃាត់នេះទទួលបានការគាំទ្រដ៏ច្រើនក្នុងការអនុវត្តរបស់រដ្ឋ ដែលបានក្លាយជាច្បាប់ទំនៀមទំលាប់ ទោះបីជារដ្ឋខ្លះបានអះអាងជាដដែល១ថា វិធាននេះមិនបានអនុវត្តចំពោះអាវុធនុក្លេអ៊ែរ និងថាពួកគេមិនត្រូវបានចងជាកាតព្វកិច្ចទាក់ទងអាវុធនុយក្លេអ៊ែរ។[៦៩] ហួសពីវិធាន នេះការសិក្សាបានរកឃើញថាបរិស្ថានធម្មជាតិត្រូវបានចាត់ទុកថាជាវត្ថុស៊ីវិល ហើយដូច្នេះវាត្រូវបានការពារដោយគោលការណ៍និងវិធានដូចគ្នានៅក្នុងកិច្ចការពារវត្ថុស៊ីវិល(Civilian Objects) ជាពិសេសគោលការណ៏បែងចែក និងសមមាត្រព្រមទាំងសេចក្តីទាមទារអោយមានការប្រយ័ត្នប្រយែងក្នុងការវាយប្រហារ។ នេះមានន័យថាមិនមានផ្នែកណាមួយនៃបរិស្ថានធម្មជាតិអាចជាកម្មវត្ថុនៃការវាយប្រហារលុះត្រាវាជាគោលដៅទាហាន ហើយការវាយប្រហារលើគោលដៅទាហាន ដែលត្រូវគេរំពឹងថានាំឱ្យមានការខូចខាតកើតមានឡើងដល់បរិស្ថានដែលហួសឆ្ងាយបើធៀប និងប្រយោជន៏ផ្នែកយោធាដោយផ្ទាល់ និងជាក់លាក់ដែលត្រូវបានហាមឃាត់។ នៅក្នុងយោបល់ប្រឹក្សាក្នុងរឿងក្តី The Nuclear Weapon ជាឧទាហរណ៏តុលាការយុត្តិធមិអន្តរជាតិបានថ្លែងថាៈ រដ្ឋត្រូវពិចារណាដល់បរិស្ថាននៅពេលវាយតំលៃលើអ្វីដែលចាំបាច់ និងសមមាត្រក្នុងការសំរេចគោលដៅយោធាដ៏ត្រឹមត្រូវ។[៧០] បន្ថែមពីលើនេះភាគីក្នុងជម្លោះត្រូវបានតំរូវឱ្យប្រកាន់យកការប្រុងប្រយ័ត្នដែលអាចធ្វើបានទាំងអស់ ក្នុងការធ្វើសង្គ្រាមដើម្បីជៀសវៀងហើយធ្វើអោយមានជាអប្បបរមានូវការខូចខាតដែលកើតមានឡើងដល់បរិស្ថាន។ ការខ្វះខាតនូវភាពច្បាស់លាស់នៃវិទ្យាសាស្រ្តទាក់ទងដល់ផលប៉ះពាល់លើបរិស្ថាននៃប្រតិបត្តិការយោធា ខ្លះមិនបានបណ្តោយឱ្យភាគីជម្លោះរួចខ្លួនពីការប្រកាន់យកភាពប្រុងប្រយ័ត្នឡើយ។[៧១]

មានបញ្ហាមួយចំនួនទៀតផងដែរ ដែលមិនត្រូវបានបំភ្លឺយ៉ាងដូច្នេះនៅក្នុងពិធីសារបន្ថែម។ ឧទាហរណ៏ពិធីសារបន្ថែមមិនចែងនូវបញ្ញត្តិជាក់លាក់ទាក់ទងការការពារបុគ្គលិក និងសំភារៈចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពឡើយ។ ទោះបីជាយ៉ាងនេះក្តីជាក់ស្តែងបុគ្គលិក និង សំភារៈទាំងនេះត្រូវបានការពារទល់នឹងការវាយប្រហារស្រដៀងគ្នានិងការការពារវត្ថុស៊ីវិល និងប្រជាជនស៊ីវិល។ ជាលទ្ធផលវិធានហាមឃាត់ការវាយប្រហារលើបុគ្គលិក និងវត្ថុចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាព ប្រព្រឹត្តឡើងតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានអភិវឌ្ឍក្នុងការអនុវត្តរបស់រដ្ឋ ព្រមទាំងត្រូវបានបញ្ចូលនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអោយ តែពួកគេមានសិទ្ធិទទួលបាន នឹងការការពារដែលត្រូវបានផ្តល់ជូនដល់បុគ្គលិក និងវត្ថុក្រោមច្បាប់មនុស្សធមិអន្តរជាតិ។ ឥឡូវនេះវាជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិអនុវត្តនៅក្នុងប្រភេទជម្លោះប្រដាប់អាវុធណាមួយ។[៧២]

បញ្ហាមួយចំនួនទាក់ទិនដល់ការធ្វើសង្គ្រាមត្រូវបានចាត់ចែងដោយបទបញ្ញត្តិ Hague (Hague Regulations)។ បទបញ្ញត្តិនេះ ជាយូរយារណាស់មកហើយត្រូវបានចាត់ថាជាទំនៀមទំលាប់ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ។[៧៣] វិធានមួយចំនួននៃវិធានទាំងនេះ ទោះបីជាយ៉ាងនេះក្តីត្រូវបានទទួលថាជាទំនៀមទំលាប់នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនជាអន្តរជាតិ។ ឧទាហរណ៏ វិធាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិយូរយារមកហើយដែលហាមឃាត់ ①ការបំផ្លាញ ឬ រឹបអូសយកទ្រព្យសម្បត្តិរបស់សត្រូវ លុះត្រាទាមទារដោយភាពចាំបាច់នៃប្រតិបត្តិការយោធា និង ②ការលួចប្លន់ដែលអនុវត្តបានដូចគ្នាចំពោះជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ។ ការលួចប្លន់ (Pillage) គឺជាការយកដោយបង្ខំនូវទ្រព្យសម្បត្តិឯកជនរបស់សត្រូវ

69 See Customary International Humanitarian Law, op. cit. (note 4), Vol. I, Rule 45.

70 International Court of Justice, Legality of the Threat or Use of Nuclear Weapons, op. cit. (note 8), §30.

71 See Customary International Humanitarian Law, op. cit. (note 4), Vol. I, Rule 44.

72 Ibid., Rule 33.

73 See, e.g., International Military Tribunal at Nuremberg, Case of the Major War Criminals, Judgement, 1 October 1946, Official Documents, Vol. I, pp. 253-254.

ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ឬជាឯកជន ។[៧៤] ការហាមឃាត់ទាំងនេះមិនបានប៉ះពាល់ដល់ការអនុវត្តជាទំនៀមទំលាប់នៃការរឹបអូសយកទ្រព្យសម្បត្តិ ដែលជា សំភារៈសង្រ្គាមជាកម្មសិទ្ធិរបស់ភាគីគូរសត្រូវ ។

ក្រោមច្បាប់ទំនៀមទំលាប់អន្តរជាតិ មេបញ្ហាការអាចធ្វើទំនាក់ទំនងមិនមានអរិភាពតាមរយៈមធ្យោបាយទំនាក់ទំនងណាមួយក៏ប៉ុន្តែទំនាក់ទំនងនោះត្រូវធ្វើឡើងដោយសុទ្ធចិត្ត ។ ការអនុវត្តបង្ហាញថាទំនាក់ទំនងអាចត្រូវបានធ្វើតាមរយៈជនទីបី ដូចជាសមាជិកសភា (Parlementaire) ក៏ប៉ុន្តែតាមរយៈមធ្យោបាយជាច្រើនទៀតដូចជាទូរស័ព្ទ និងវិទ្យុ ។ សមាជិកសភាគឺជាបុគ្គលរបស់ភាគីជម្លោះ ហើយដែលត្រូវបានអនុញ្ញាតឱ្យធ្វើទំនាក់ទំនងជាមួយភាគីជម្លោះដទៃទៀត ហើយដូចនេះជាបុគ្គលដែលគេមិនអាចប៉ះពាល់បាន ។ វិធីសាស្រ្តបែបបុរាណធ្វើឱ្យគេស្គាល់ថាជាសមាជិកសភា ដោយការពាក់ទង់ពណ៌សនៅតែមានសុពលភាព ។ បន្ថែមពីលើនេះវាជាការអនុវត្តដែលត្រូវបានទទួលស្គាល់ថាភាគីអាចស្នើដល់ភាគីទី៣ ឱ្យជួយសំរួលនូវការធ្វើទំនាក់ទំនង ឧទាហរណ៍ប្រទេសដែលជាអ្នកការពារ ឬអង្គការមនុស្សធម៌អព្យាក្រឹត្យ និងមិនលំអៀងដែលដើរតួជំនួសជាពិសេស ICRC ឬអង្គការអន្តរជាតិ ឬកងកំលាំងថែរក្សាសន្តិភាព ។ ការអនុវត្តដែលប្រមូលបានបង្ហាញថាអង្គការនិងស្ថាប័នជាច្រើនបានដើរតួជាភាគីទី៣ ក្នុងការចរចារទាំងក្នុងជម្លោះប្រដាប់អាវុធជាអន្តរជាតិ និងមិនអន្តរជាតិព្រមទាំងបង្ហាញថាវាជាការទទួលយកជាទូទៅ ។ វិធានគ្រប់គ្រងសមាជិកសភាមានតាំងពីនៅក្នុងបទបញ្ញត្តិ Hague ហើយត្រូវបានគេចាត់ទុកជាយូរមកហើយជាទំនៀមទំលាប់ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ផ្អែកតាមការអនុវត្តក្នុងអំឡុងពេលប្រហែល ៥០ឆ្នាំក្រោយនេះវិធានទាំងនោះបានក្លាយជាទំនៀមទំលាប់ក្នុងជម្លោះប្រដាប់អាវុធមិនអន្តរជាតិ ។[៧៥]

ការអនុវត្តបង្ហាញពីប្រភពពីរនៃច្បាប់ដែលការពារសម្បត្តិវប្បធម៌ ។ ប្រភពទីមួយ មានចាប់តាំងពីរ Hague Regulations ហើយទាមទារថា ការថែរក្សាជាពិសេសត្រូវតែប្រកាន់យកក្នុងប្រតិបត្តិការយោធាដើម្បីបញ្ចៀស ការខូចខាតដល់អាគារសំរាប់សាសនា សិល្បៈ វិទ្យាសាស្រ្តការអប់រំ ឬ គោលបំណងមនុស្សធម៌ និងវិមានប្រវត្តិសាស្រ្ត លុះត្រាតែការប្រតិបត្តិការនោះមានគោលដៅទាហាន ។ វាបានហាមឃាត់ផងដែរ ការរឹបអូស ឬបំផ្លាញ ឬការធ្វើឱ្យខូចខាតដោយចេតនាដល់អាគារនិងវិមានទាំងនេះ ។ ខណៈដែលវិធានទាំងនេះត្រូវបានចាត់ជាយូរមក ហើយជាទំនៀមទំលាប់ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ពួកគេឥឡូវត្រូវបានទទួលយកផងដែរថាជាទំនៀមទំលាប់ក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ។

ប្រភពទី២ គឺផ្អែកលើបទបញ្ញត្តិជាក់លាក់នៃសន្ធិសញ្ញា Hague ឆ្នាំ១៩៥៤ សំរាប់ការការពារសម្បត្តិវប្បធម៌ដែលការពារចាប់ពីសម្បត្តិដែលមានសារៈសំខាន់ខ្លាំងដល់មរតកវប្បធម៌របស់ប្រជាជនគ្រប់រូប និង បង្ហាញនូវអត្តសញ្ញាណដោយឡែកដើម្បីកំណត់នូវសម្បត្តិនេះ ។ ក្នុងពេលបច្ចុប្បន្ននេះ ច្បាប់ទំនៀមទំលាប់ទាមទារថា វត្ថុទាំងនេះមិនត្រូវបានវាយប្រហារ និងមិនត្រូវបានប្រើប្រាស់សំរាប់គោលបំណងដែលទំនងជានាំអោយខូចខាតដល់វត្ថុ លុះត្រាត្រូវបានតំរូវជាដាច់ខាតដោយភាពចាំបាច់ខាងយោធា ។ វាបានឃាមឃាត់ផងដែរនូវទំរង់លួចប្លន់ការរឹបអូសមិនសមស្រប និងទង្វើណាមួយនៃការឆក់ប្លន់ប្រឆាំងនឹងទ្រព្យសម្បត្តិនោះ ។ ការហាមឃាត់ទាំងនេះដូចគ្នា និងបទបញ្ញត្តិកំណត់ក្នុង Hague Convention និងជាភស្តុតាងនៃឥទ្ធិពល ដែលសន្ធិសញ្ញាមានចំពោះការអនុវត្តរបស់រដ្ឋទាក់ទង នឹងការការពារទ្រព្យសម្បត្តិវប្បធម៌សំខាន់ៗ ។

74 See, Elements of Crimes for the International Criminal Court, Pillage as a war crime (Article 8(2)(b)(xvi) and (e)(v) of the Statute of the International Criminal Court).

75 See Customary International Humanitarian Law, op. cit. (note 4), Vol. I, Rules 67-69.

**អាវុធ (Weapons)**

គោលការណ៍ទូទៅ ហាមឃាត់ការប្រើប្រាស់អាវុធ ដែលនាំអោយមានរបួសជាបន្ថែម ឬ ការឈឺចាប់ដែល មិនចាំបាច់ និងអាវុធដែលជាប្រភេទមិនរើសអើងត្រូវបានរកឃើញជាទំនៀមទំលាប់ក្នុងជម្លោះប្រដាប់អាវុធបន្ថែមពីលើនេះ ហើយ ផ្អែកជាចំបងទៅលើគោលការណ៍ទាំងនេះ ការអនុវត្តរបស់រដ្ឋបានហាមឃាត់ការប្រើ ( ឬប្រភេទ មួយចំនួននៃការប្រើប្រាស់) នៃអាវុធជាក់លាក់មួយចំនួនតាមច្បាប់ទំនៀមទំលាប់អន្តរជាតិ : ជាតិពុល អាវុធមាន ជាតិពុល អាវុធជីវសាស្ត្រ អាវុធគីមី សំភារៈប្រឆាំងកុបកម្មថាជាវិធីសាស្ត្រមួយនៃការធ្វើចំបាំង Herbicides ថាជាវិធីសាស្ត្រធ្វើចំបាំង[៧៦] ក្បាលគ្រាប់ដែលយក មកធ្វើការកែឆ្នៃ ដើម្បីឱ្យផ្ទុះបែកធំឬក៏ងាយស្រួលចូលជ្រៅនៅក្នុងរាងកាយមនុស្ស ការប្រើប្រាស់គ្រាប់ប្រឆាំងមនុស្សដែល ផ្ទុះក្នុងរូបរាងកាយមនុស្ស អាវុធដែលផលប៉ះពាល់ចំបងគឺការបង្ករបួសស្នាមតាមរយៈ កំទេចបន្សល់ទុកពីគ្រាប់ផ្ទុះ ដែល មិនអាចរកមើលឃើញដោយពន្លឺកាំរស្មី X ក្នុងរូបរាងកាយមនុស្សអន្ទាក់ដែលភ្ជាប់ជាមួយ ឬរួមជាមួយវត្ថុឬបុគ្គលមានសិទ្ធិ ទទួលបានការការពារជាពិសេស ក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ឬវត្ថុដែលទំនងជាទាញអារម្មណ៍ប្រជាពលរដ្ឋស៊ីវិល និងអាវុធឡេស៊ែដែលត្រូវបានបង្កើតឡើងជាពិសេស ដែលបំរើគោលបំណងមួយគឺសំរាប់ជាការវាយប្រហារដើម្បីបង្ករឱ្យ ងងឹតភ្នែកជាអចិន្ត្រៃយ៍ដល់ការមើលដែលមិនអាចធ្វើឱ្យប្រសើរឡើងវិញ ។

អាវុធខ្លះដែលមិនត្រូវបានហាមឃាត់ដូច្នេះ ដោយច្បាប់ទំនៀមទំលាប់អន្តរជាតិទោះបីជាយ៉ាងនេះក្តីត្រូវបានដាក់នៅ ក្រោមការកំរិតនៃការប្រើប្រាស់ ។ នេះជាករណីឧទាហរណ៍សំរាប់មីន និងអាវុធជាតិផ្ទុះ (Incendiary) ។ ការប្រុងប្រយ័ត្ន ជាពិសេសត្រូវតែបានប្រកាន់យកដើម្បីបន្ថយបានជាអប្បបរមានូវផលប៉ះពាល់ដោយគ្មាន រើសអើងបែងចែកនៃគ្រាប់មីន ។ ឧទាហរណ៍ នេះរាប់បញ្ចូលគោលការណ៍ដែលភាគីជម្លោះប្រើប្រាស់មីនត្រូវកត់ត្រាកន្លែងដាក់តាមការដែលអាចធ្វើទៅ បាន ។ ដូចគ្នាផងដែរនៅពេលបញ្ចប់ជម្លោះ ភាគីជម្លោះដែលបានប្រើប្រាស់គ្រាប់មីនត្រូវដក ឬក្រៅពីនេះធ្វើអោយគ្រាប់មីន លែងមានគ្រោះថ្នាក់ដល់ប្រជាជនស៊ីវិល ឬជួយសំរួលការដកមីនចេញ ។

មានជាង១៤០ប្រទេសបានផ្តល់សច្ចាប័នដល់កតិកាសញ្ញាអូតាវ៉ា ព្រមទាំងការផ្តល់សច្ចាប័នផ្សេងទៀតដែរកំពុងត្រូវ បានរៀបចំ រដ្ឋភាគច្រើនមានកាតព្វកិច្ចឈប់ប្រើប្រាស់បង្កើតស្តុក ឬផ្ទេរគ្រាប់មីនប្រឆាំងនឹងមនុស្ស ។ ការហាមឃាត់នេះ ឥឡូវនេះមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ ដោយសារមានការអនុវត្តផ្ទុយជាច្រើនរបស់រដ្ឋដែលមិន មែនជាភាគីនៃសន្ធិសញ្ញា រដ្ឋស្ទើរតែទាំងអស់រាប់បញ្ចូលរដ្ឋដែលមិនមែនជាភាគី សន្ធិសញ្ញាអូតាវ៉ា ហើយដែលមិនចង់ឱ្យមាន ការហាមឃាត់ភ្លាម បានទទួលស្គាល់នូវសេចក្តីត្រូវការក្នុងការធ្វើការងារឆ្ពោះទៅរកការលប់បំបាត់ចោលជាស្ថាពរនៃមីន ប្រឆាំងមនុស្ស ។

ការប្រើប្រាស់អាវុធជាតិផ្ទុះប្រឆាំងមនុស្សត្រូវបានហាមឃាត់លុះត្រាតែវាមិនអាចធ្វើទៅរួច ក្នុងការប្រើអាវុធបង្កផល វិបាកតិចតួច ដើម្បីធ្វើអោយបុគ្គលលែងមានសមត្ថភាពប្រយុទ្ធ ។ ជាបន្ថែមប្រសិនបើអាវុធទាំងនោះ ត្រូវបានប្រើការ

76 វិធាននេះបញ្ចូលនូវការយោងដល់វិធានដទៃមួយចំនួនទៀត នៃច្បាប់ទំនៀមទំលាប់អន្តរជាតិដូចជាការហាមប្រាមអាវុធ ជីវសាស្ត្រ និងគីមី ការហាមឃាត់ការវាយប្រហារទៅលើដំណាំដែលមិនមែនជាគោលដៅយោធាការហាមឃាត់ការវាយប្រហារ ដែលអាចនាំឱ្យមានការបាត់ បង់ជីវិតមនុស្សរបួសដល់ជនស៊ីវិលការខូចខាតដល់វត្ថុស៊ីវិល ឬការខូចខាចសរុបទាំងអស់ដែលបានរំពឹងទុក ហួសឆ្ងាយពីប្រយោជន៍យោធា ផ្ទាល់ និងជាក់ស្តែងដែលរំពឹងទុក និងការហាមឃាត់ការបង្ករឱ្យមានការខូចខាតធ្ងន់ធ្ងរយូរអង្វែង និងទូទៅដល់បរិស្ថានធម្មជាតិ ។
See ibid., Rule 76.

ប្រយ័ត្នប្រយែងជាពិសេសត្រូវបានប្រកាន់យកដើម្បីបញ្ចៀស ហើយដើម្បីកាត់បន្ថយជាអប្បបរមានូវការបាត់បង់ជីវិតប្រជាជនស៊ីវិលដែលកើតមានឡើងការបង្ករបួសស្នាមដល់ប្រជាជនស៊ីវិល និងការខូចខាតដល់សំភារៈបំរើប្រយោជន៍ស៊ីវិល ។

វិធានជាច្រើននៃវិធានទាំងនេះ ស្រដៀងគ្នាទៅនឹងបទបញ្ញត្តសន្ធិសញ្ញាដែលអនុវត្តន៏ពីដំបូងមកសំរាប់តែជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ប៉ុន្តែមកដល់ពេលនេះគឺមិនដូចពីមុនទេ ឧទាហរណ៏តាមរយៈការធ្វើវិសោធនកម្មពិធីសារបន្ថែមទី៤ ភ្ជាប់សន្ធិសញ្ញាស្តីពីអាវុធធម្មតាមួយចំនួនក្នុងឆ្នាំ១៩៩៦ ដែលអនុវត្តន៏ផងដែរ ចំពោះជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ហើយថ្មីៗនេះ តាមរយៈការធ្វើវិសោធនកម្មលើសន្ធិសញ្ញាស្តីពីអាវុធធម្មតា មួយចំនួនក្នុងឆ្នាំ២០០១ ដើម្បីពង្រីកវិសាលភាពអនុវត្តនៃពធីសារបន្ថែមទី១ ដល់ទី៤ក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ។ ការហាមឃាត់ និងការក៏រិតជាទំនៀមទំលាប់ គឺសំដៅដល់ការអនុវត្តចំពោះជម្លោះប្រដាប់អាវុធណាមួយក៏បាន ។

នៅពេល ICRC បានទទួលនូវតួនាទីក្នុងការសិក្សាអំពីច្បាប់មនុស្សធម៌អន្តរជាតិ ដែលមានឋានៈជាទំនៀមទំលាប់តុលាការយុត្តិធម៌អន្តរជាតិ កំពុងពិចារណាលើគតិយុត្តិភាពនៃការគំរាមកំហែង ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ បន្ទាប់ពីមានសំណើសុំយោបល់ប្រឹក្សាលើបញ្ហានេះពីមហាសន្និបាតអង្គការសហប្រជាជាតិ ។ ដូច្នេះ ICRC បាន សំរេចមិនធ្វើការវិភាគដោយខ្លួនឯងនូវបញ្ហានេះទេ ។ នៅក្នុងយោបល់ប្រឹក្សាតុលាការយុត្តិធម៌អន្តរជាតិបានថ្លែងជាឯកឆន្ទថា : ការគំរាម ឬការប្រើប្រាស់អាវុធនុក្លេអ៊ែរគួតែស្របជាមួយការទាមទាររបស់ច្បាប់អន្តរជាតិ ដែលអនុវត្តន៏នៅក្នុងជម្លោះប្រដាប់អាវុធ ជាពិសេសការទាមទាររបស់គោលការណ៏និងវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ។[៧៧] ការរកឃើញនេះមានអត្ថន័យដោយពិចារណាឃើញថារដ្ឋមួយចំនួនបានធ្វើការចរចារពិធីសារបន្ថែមទី ក ស្តីពីការយល់ដឹងថា ពិធីសារមិនគួរអនុវត្តន៏ចំពោះការប្រើប្រាស់អាវុធនុយក្លេអ៊ែរទេ ។ ទោះបីជាយ៉ាងនេះក្តី យោបល់របស់តុលាការមានន័យថា វិធានស្តីពីការប្រព្រឹត្តទៅនៃជម្លោះ[៧៨] និងគោលការណ៏ទូទៅស្តីពីការប្រើប្រាស់ អាវុធអនុវត្តន៏ចំពោះការប្រើប្រាស់អាវុធនុយក្លេអ៊ែរ ។ ក្នុងការអនុវត្តគោលការណ៏ និងវិធានទាំងនេះ តុលាការបានសន្និដ្ឋានថា " ការគំរាម ឬ ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ ជាទូទៅនឹងផ្ទុយនឹងវិធាននៃច្បាប់អន្តរជាតិដែលអនុវត្តន៏ក្នុងជម្លោះប្រដាប់អាវុធ ហើយជាពិសេសគោលការណ៏ និងវិធាននៃច្បាប់មនុស្សធម៌ ។

## ការធានាជាមូលដ្ឋាន (Fundamental Guarrantees)

ការធានាជាមូលដ្ឋានអនុវត្តន៏ចំពោះគ្រប់ប្រជាជនស៊ីវិលទាំងអស់ នៅក្នុងអំណាចរបស់ភាគីជម្លោះ និង អ្នកដែលមិនចូលរួម ឬឈប់ចូលរួមដោយផ្ទាល់ក្នុងជម្លោះ ព្រមទាំងបុគ្គលទាំងអស់ដែលលែងមានសមត្ថភាពប្រយុទ្ធ ។ ដោយសារការធានាជាមូលដ្ឋានទាំងអស់នេះជាវិធានទូលំទូលាយ (Overarching) ដែលអនុវត្តន៏ចំពោះមនុស្សទាំងអស់វិធានទាំងនេះមិនត្រូវបានចាត់ក្នុងផ្នែកបន្ទាប់ក្នុងការសិក្សានេះចូលទៅក្នុងវិធានជាក់លាក់ទាក់ទងជាមួយនឹងប្រភេទបុគ្គលផ្សេងៗទេ ។

ការធានាជាមូលដ្ឋានទាំងអស់នេះ មានមូលដ្ឋានគ្រឹះយ៉ាងរឹងមាំនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ដែលអនុវត្តន៏ទាំងនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនអន្តរជាតិ ។ នៅក្នុងការសិក្សានេះភាគច្រើននៃវិធានទាក់ទងដល់ការធានាជាមូលដ្ឋានត្រូវបានសំដែង (Couched) ក្នុងភាសាច្បាប់មនុស្សធម៌អន្តរជាតិសម័យបុរាណដោយសារវាឆ្លុះបញ្ចាំងដ៏ប្រសើរនូវ

77 International Court of Justice, Legality of the Threat or Use of Nuclear Weapons, op. cit. (note 8), p. 226.

78 Ibid., see also United Nations General Assembly, 51st Session, First Committee, Statement by the International Committee of the Red Cross, UN Doc. A/C.1/51/PV.8, 18 October 1996, p. 10, reproduced in International Review of the Red Cross, No. 316, 1997, pp. 118-119 ("the ICRC finds it difficult to envisage how a use of nuclear weapons could be compatible with the rules of international law").

សារធាតុនៃវិធានទំនៀមទំលាប់ដែលពាក់ព័ន្ធ (Substance of the Corresponding Customary Rule)[៧៩] ។ ទោះបីជាយ៉ាងនេះក្តី វិធានមួយចំនួនត្រូវបានពព្រាងដើម្បីក្តោបយក នូវន័យរបស់បទបញ្ញត្តិមួយចំនួនទាក់ទងដល់ប្រធានបទជាក់លាក់ជាពិសេសវិធានហាមឃាត់ការងាដោយបង្ខំ ឬ មិនត្រូវបានផ្តល់កំរៃជូនការបាត់ខ្លួនដោយបន្ទាន់បង្ខំ និងការឃុំខ្លួនដោយបំពារបំពាន ព្រមទាំងវិធានដែលទាមទារការគោរពជីវិតគ្រួសារ ។[៨០]

នៅពេលមានការពាក់ព័ន្ធ ការអនុវត្តក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិត្រូវបានរាប់បញ្ចូលក្នុងការសិក្សានេះ ហើយជាពិសេសនៅក្នុងជំពូកនិយាយពីការធានាជាមូលដ្ឋាន។ នោះត្រូវបានធ្វើដោយសារច្បាប់សិទ្ធិមនុស្សអន្តរជាតិបន្តអនុវត្តក្នុងពេលជម្លោះប្រដាប់អាវុធ ដូចដែលបានចែងយ៉ាងច្បាស់ក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សទាំងនោះស្រាប់ បើទោះបីជាបទបញ្ញត្តិមួយចំនួនអាចស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួនអាចត្រូវបានផ្អាកនៅពេលមានគ្រោះអាសន្នជាសាធារណៈ។ ជាច្រើនលើកច្រើនសារសុពលភាពនៃច្បាប់សិទ្ធិមនុស្សក្នុងពេលជម្លោះប្រដាប់អាវុធ ត្រូវបានបញ្ជាក់តាមរយៈការអនុវត្តជាក់ស្តែងនៃរដ្ឋនិមួយៗ និងតាមរយៈគណៈកម្មាធិការសិទ្ធិមនុស្ស និងតុលាការយុត្តិធម៌អន្តរជាតិ ។[៨១] ក្នុងពេលថ្មីៗបំផុតនេះ ក្នុងយោបល់ប្រឹក្សាស្តីពីផលវិបាកផ្លូវច្បាប់នៃការកសាងរបងក្នុងតំបន់ដែនដីគ្រប់គ្រងដោយពួក ប៉ាឡេស្ទីនបានបញ្ជាក់ថា ការការពារផ្តល់ដោយសន្ធិសញ្ញាសិទ្ធិមនុស្សមិនបានបញ្ឈប់ទេ ក្នុងករណីមានជម្លោះប្រដាប់អាវុធ ហើយបញ្ជាក់ថាខណៈដែលមានសិទ្ធិខ្លះដែលចែងដាច់ដោយឡែករបស់ច្បាប់មនុស្សធម៌អន្តរជាតិ ឬច្បាប់សិទ្ធិមនុស្សមានបញ្ហាដទៃផ្សេងទៀតដែលអាចជាបញ្ហាចែងដោយច្បាប់ទាំងពីរប្រភេទនេះ ។[៨២] ក៏ប៉ុន្តែការសិក្សា នេះមិនមានបំណងផ្តល់ការវាយតំលៃអំពីច្បាប់សិទ្ធិមនុស្សដែលមានឋានៈជាទំនៀមទំលាប់ឡើយ ។ ផ្ទុយទៅវិញការអនុវត្តក្រោមច្បាប់សិទ្ធិមនុស្សត្រូវបានរាប់បញ្ចូលដើម្បីគាំទ្រពង្រឹង និងបំភ្លឺគោលការណ៍ស្រដៀងគ្នានៃច្បាប់មនុស្សធម៌អន្តរជាតិ ។

## ការប្រតិបត្តិ (Implementation)

វិធានមួយចំនួនស្តីពីការប្រតិបត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ បានក្លាយជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ។ ជាពិសេសភាគីជម្លោះនីមួយៗត្រូវតែគោរព ហើយធានាការគោរពច្បាប់មនុស្សធម៌អន្តរជាតិឱ្យបានដោយកងកំលាំងប្រដាប់អាវុធរបស់ខ្លួនហើយមនុស្សដទៃ ឬក្រុមដែលជាក់ស្តែងធ្វើការផ្អែកតាមទ្រឹស្តី ឬក្រោមការដឹកនាំ ឬគ្រប់គ្រងរបស់ខ្លួន ។ ជាលទ្ធផលភាគីជម្លោះនីមួយៗ រាប់បញ្ចូលក្រុមប្រដាប់អាវុធបដិបក្ខត្រូវផ្តល់ការណែនាំមានក្នុងច្បាប់មនុស្សធម៌អន្តរជាតិ

79 វិធាននេះបញ្ចូលនូវការធានាជាមូលដ្ឋានដែលជនស៊ីវិល និងបុគ្គលដែលលែងមានសមត្ថភាពប្រយុទ្ធត្រូវបានគេប្រព្រឹត្តមនុស្សធម៌ និងដោយគ្មានការបែងចែកការហាមឃាត់ការសំលាប់ការហាមឃាត់អំពើ ទារុណកម្មអំពើអមនុស្សធម៌ និងបន្ទាបបន្ថោកលើសេចក្តីថ្លៃថ្នូរ ជាពិសេសការប្រព្រឹត្តអមនុស្សធម៌ និងការបន្ទាបបន្ថោក ការហាមឃាត់ទណ្ឌកម្មវាយដំ ការហាមឃាត់ការកាត់សរីរាង្គ និង ពិសោធន៏វិទ្យាសាស្ត្រ ការហាមឃាត់អំពើ រំលោភសេពសន្ថវៈ និង ទំរង់ដទៃទៀត នៃហិង្សាផ្លូវភេទ ការហាមឃាត់ទាសភាព និងជំនួញទាសករក្នុងគ្រប់រូបភាពទាំងអស់ ការហាមឃាត់ចំណាប់ខ្មាំង ការហាមឃាត់ការប្រើមនុស្សជារបាំងធានាសេចក្តីវិន្និច្ឆ័យដោយយុត្តិធម៌ ការហាមឃាត់ការដាក់ទណ្ឌកម្មជារួមសេចក្តីទាមទារឱ្យ គោរពការប្រតិបត្តិការតាមសាសនារបស់ជនស៊ីវិល និងបុគ្គលដែលលែងមានសមត្ថភាពប្រយុទ្ធ។ See Customary International Humanitarian Law, supra note 4, Vol. I, Rules 87-94, 96-97 and 100-104.

80 Ibid., Rules 95, 98-99 and 105.

81 See Ibid., Introduction to Chapter 32, Fundamental Guarantees.

82 International Court of Justice, Legal Consequences of the Construction of a Wall in the Occupied Palestinian Territory, Advisory Opinion, 9 July 2004, § 106.

ដល់កងកំលាំងប្រដាប់អាវុធរបស់ខ្លួន។ ក្រៅពីកាតព្វកិច្ចទូទៅទាំងនេះ វាមិនមានភាពច្បាស់លាស់ទាំងស្រុងទាក់ទងដល់វិសាលភាពដែលយន្តការអនុវត្តជាក់លាក់ដទៃទៀតដែលបានចងជាកាតព្វកិច្ចដល់រដ្ឋ ហើយដែលបានចងជាកាតព្វផងដែរដល់កងកំលាំងប្រដាប់អាវុធបដិបក្ខ។ ឧទាហរណ៍ កាតព្វកិច្ចចេញបទបញ្ជា និងការណែនាំដល់កងកំលាំងប្រដាប់អាវុធដែលធ្វើអោយប្រាកដប្រជាថា ការការពារច្បាប់មនុស្សធម៌អន្តរជាតិត្រូវបានកំណត់ចែងយ៉ាងច្បាស់លាស់ក្នុងច្បាប់អន្តរជាតិសំរាប់រដ្ឋ មិនដូច្នេះសំរាប់កងកំលាំងប្រដាប់អាវុធបដិបក្ខឡើយ។ ស្រដៀងគ្នានេះដែរមានកាតព្វកិច្ចផងដែរសំរាប់រដ្ឋផ្តល់ទីប្រឹក្សាច្បាប់នៅពេលចាំបាច់ ផ្តល់យោបល់ដល់មេបញ្ជាការកងទ័ពនៅកំរិតសមស្របស្តីពីការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែមិនចងជាកាតព្វកិច្ចដល់កងកំលាំងប្រដាប់អាវុធបដិបក្ខ។

បន្ថែមពីលើនេះ រដ្ឋនិមួយៗទទួលខុសត្រូវចំពោះការរំលោភច្បាប់មនុស្សធម៌អន្តរជាតិបង្ករដោយខ្លួន (Attrib- utable to It) និងត្រូវបានទាមទារឱ្យធ្វើការសងទាំងស្រុងសំរាប់ការបាត់បង់ ឬរបួសស្នាមបង្ករដោយការរំលោភទាំងនោះ។ វាមិនច្បាស់ថាតើ កងកំលាំងប្រដាប់អាវុធបដិបក្ខទទួលខុសត្រូវស្រដៀងនេះសំរាប់ការរំលោភប្រព្រឹត្ត ដោយសមាជិករបស់ពួកគេ ហើយអ្វីទៅជាផលវិបាកនៃការទទួលខុសត្រូវដែលអាចកើតមាន។ ដូចបាននិយាយនៅខាងលើកងកំលាំងប្រដាប់អាវុធបដិបក្ខ ត្រូវតែគោរពច្បាប់មនុស្សធម៌អន្តរជាតិដោយពួកគេត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំដែលមានការទទួលខុសត្រូវ។[៨៣] ដូចនេះគេអាចអះអាងបានថាកងកំលាំងប្រដាប់អាវុធមានការទទួលខុសត្រូវចំពោះអំពើដែលត្រូវបានប្រព្រឹត្តដោយបុគ្គលដែលជាផ្នែកនៃក្រុម/កងកំលាំងនេះ។ ផលវិបាកនៃការទទួលខុសត្រូវមានភាពមិនច្បាស់លាស់ឡើយទោះបីយ៉ាងនេះក្តី។ ជាពិសេសវាមិនមានភាពច្បាស់លាស់ទាក់ទិន ដល់កំរិតដែលកងកំលាំងប្រដាប់អាវុធមានកាតព្វកិច្ចក្នុងការផ្តល់នូវសំណងពេញលេញទោះបីជានៅក្នុងប្រទេសជាច្រើន ជនរងគ្រោះអាចប្តឹងទាមទារសំណងលើការខូចខាតប្រឆាំងនឹងអ្នកប្រព្រឹត្តល្មើសក៏ដោយ។

ពេលដែលនិយាយអំពីការទទួលខុសត្រូវរបស់បុគ្គល ច្បាប់មនុស្សធម៌អន្តរជាតិជាទំនៀមទំលាប់ដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបុគ្គលទាំងអស់ដែលប្រព្រឹត្ត អ្នកបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ឬ អ្នកដែលក្រៅពីនេះទទួលខុសត្រូវក្នុងនាមជាមេបញ្ជាការ ឬ ចៅហ្វាយនាយចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ ការអនុវត្តរបបឧក្រិដ្ឋកម្មសង្គ្រាមនោះគឺការស៊ើបអង្កេតលើឧក្រិដ្ឋកម្មសង្គ្រាម និងការកាត់ទោសជនសង្ស័យ គឺជា កាតព្វកិច្ចចងចំពោះរដ្ឋ។ រដ្ឋអាចបំពេញតាមកាតព្វកិច្ចនេះ ដោយការបង្កើតតុលាការកូនកាត់ ឬ តុលាការអន្តរជាតិដើម្បីបំពេញកិច្ចទទួលខុសត្រូវដែលទាមទារនោះ។

## សន្និដ្ឋាន (Conclusion)

ការសិក្សានេះ មិនបានព្យាយាមកំណត់ចរិតជាទំនៀមទំលាប់នៃវិធានចែងក្នុងសន្ធិសញ្ញានីមួយៗ ពាក់ព័ន្ធដល់ច្បាប់មនុស្សធម៌អន្តរជាតិឡើយ ក៏ប៉ុន្តែវាបានធ្វើការវិភាគលើបញ្ហាដើម្បីបង្ហាញថាវិធានអ្វីនៃច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវបានរកឃើញផ្អែកតាមការអនុវត្តរបស់រដ្ឋទាក់ទងដល់បញ្ហាទាំងនេះ។ ប៉ុន្តែការពិនិត្យមើលជាទូទៅ និងសង្ខេបលើគំហើញមួយចំនួននៃការសិក្សាបង្ហាញថា គោលការណ៍ និងវិធានមាននៅក្នុងសន្ធិសញ្ញាទទួលបានការទទួលស្គាល់ជាទូទៅក្នុងការអនុវត្ត និងបានផ្តល់ឥទ្ធិពលយ៉ាងខ្លាំងដល់ការបង្កើតច្បាប់ទំនៀមទំលាប់អន្តរជាតិ។ គោលការណ៍ និងវិធានជាច្រើនឥឡូវនេះ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ។ ដូច្នេះវិធានទាំងនោះចងជាកាតព្វកិច្ចរដ្ឋ រដ្ឋទាំងអស់ទោះបីមិនបាន

83 Additional Protocol II, Article 1(1).

ផ្តល់សច្ចាប័នដល់សន្ធិសញ្ញា ហើយចងជាកាតព្វកិច្ចដល់ក្រុមប្រដាប់អាវុធផងដែរ ក្នុងករណីមានវិធានអនុវត្តបានចំពោះគ្រប់ភាគីទាំងអស់នៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ។

ការសិក្សានេះចង្អុលបង្ហាញផងដែរថាវិធានជាច្រើននៃច្បាប់ទំនៀមទំលាប់អន្តរជាតិអនុវត្តទាំងក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនអន្តរជាតិ និងបង្ហាញពីវិសាលភាពដែលការអនុវត្តរដ្ឋបានដើរឆ្ងាយហួសពីអ្វីដែល មាននៅក្នុងសន្ធិសញ្ញានិងបានពង្រីកវិធានអនុវត្តចំពោះជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ។ ដូចនេះបទប្បញ្ញត្តិ នៃការប្រព្រឹត្តទៅនៃជម្លោះព្រមទាំងការប្រព្រឹត្តលើមនុស្សក្នុងជម្លោះផ្ទៃក្នុងមានចំណុចលំអិត និងពេញលេញជាងអ្វីដែលមានក្នុងសន្ធិសញ្ញា ។ វានៅមានអ្វីដែលត្រូវបន្តស្រាវជ្រាវទាក់ទិនដល់វិសាលភាពនៃការយល់ឃើញរបស់ក្រុមយោធា ឬក្រុមមនុស្សធម៌ថាបទបញ្ញត្តិពេញលេញ និងលំអិតនេះវាគ្រប់គ្រាន់ ឬថាតើការអភិវឌ្ឍជាបន្ថែមក្នុងច្បាប់ត្រូវបានទាមទារឬទេ ។

ដូចជាករណីសំរាប់សន្ធិសញ្ញា ការអនុវត្តដ៏មានប្រសិទ្ធភាពនៃវិធានរបស់ច្បាប់មនុស្សធម៌អន្តរជាតិជាទំនៀមទំលាប់ត្រូវបានទាមទារតាមរយៈការផ្សព្វផ្សាយការបណ្តុះបណ្តាល និងការប្រតិបត្តិ ។ វិធានទាំងនេះគួរត្រូវបានបញ្ចូលទៅក្នុងក្បួនសឹក និងច្បាប់របស់ជាតិប្រសិនបើមិនទាន់មានវិធានទាំងនោះទេ ។

ការសិក្សានេះបានរកឃើញផងដែរនូវបរិបទមួយចំនួន ដែលច្បាប់មិនមានភាពច្បាស់លាស់ និងចង្អុលបង្ហាញនូវបញ្ហាដែលទាមទារការបំភ្លឺជាបន្ថែមដូចជានិយមន័យនៃប្រជាជនស៊ីវិលក្នុងជម្លោះប្រដាប់អាវុធ មិនមែន អន្តរជាតិនិងទស្សនាទាននៃការចូលរួមដោយផ្ទាល់ក្នុងជម្លោះ និងវិសាលភាពព្រមទាំងការអនុវត្តនៃគោលការណ៍សមមាត្រ ។

បើគិតអំពីសមិទ្ធិផលមកដល់ពេលនេះ ហើយនិងការងារដែលនៅមានសំរាប់បំពេញការសិក្សានេះមិនគួរណា ត្រូវបានយល់ឃើញថាជាការងារចុងក្រោយឡើយ ក៏ប៉ុន្តែគួរចាត់ទុកថាជាការងារចាប់ផ្តើមនៃដំណើរការថ្មីធ្វើឡើងដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីការយល់ដឹងស្តីពីគោលការណ៍ និងវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ។ ក្នុងដំណើរការនេះការសិក្សានេះអាចបង្កើតជាមូលដ្ឋាននៃការពិភាក្សាដ៏ផុសផុល និងការពិភាក្សាស្តីពីការអនុវត្តការបំភ្លឺ និងការអភិវឌ្ឍដែលអាចកើតមាននៅក្នុងវិស័យច្បាប់ ។

## ឧបសម្ព័ន្ធ

### បញ្ជីវិធានដែលមានឋានៈជាទំនៀមទម្លាប់របស់ច្បាប់មនុស្សធម៌អន្តរជាតិ

**(List of Customary Rules of International Humanitarian Law)**

(បញ្ជីនេះគឺផ្អែកទៅតាមសេចក្តីសន្និដ្ឋានដែលបង្ហាញនៅក្នុងភាគទី Ι នៃការសិក្សាស្តីពីច្បាប់មនុស្សធម៌ អន្តរជាតិដែលមានឋានៈជាទំនៀមទំលាប់ ។ ដោយសារការសិក្សានេះមិនមានបំណងកំណត់នូវចរិតជាទំនៀមទម្លាប់ នៃវិធាននីមួយៗ ក្នុងសន្ធិសញ្ញានៃច្បាប់មនុស្សធម៌អន្តរជាតិ ពេលខ្លះវាក៏មិនបានដើរតាមលំនាំទំរង់នៃសន្ធិសញ្ញាដែលនៅមានជាធរមានទេ ។

វិសាលភាពនៃការអនុវត្តវិធានត្រូវបានចង្អុលបង្ហាញក្នុងវង្វង់ក្រចក ។ អក្សរកាត់នៃពាក្យ IAC សំដៅដល់វិធានជាទំនៀមទម្លាប់អនុវត្តបានក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ហើយ NIAC សំដៅដល់វិធានជា ទំនៀមទម្លាប់អនុវត្តនីក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ។ ក្នុងករណីចុងក្រោយនេះ វិធានមួយចំនួនត្រូវ បានគេចង្អុលបង្ហាញថាអាចអនុវត្តនីបានដោយសារជាទូទៅការអនុវត្តបានចង្អុលបង្ហាញនៅក្នុងលំនាំនោះក៏ប៉ុន្តែ
វាមិនបានច្បាស់លាស់ដូចជាវិធានផ្សេងទៀត ។)

## ជំពូកទី១. គោលការណ៍នៃការបែងចែក (The Principle of Distinction)

### ១. ការបែងចែករវាងជនស៊ីវិល និងអ្នកប្រយុទ្ធ (Distinction between Civilians and Combatants)

**វិធាន១.-**

ភាគីជម្លោះគ្រប់ពេលវេលាត្រូវបែងចែករវាងជនស៊ីវិល និងអ្នកប្រយុទ្ធ។ ការវាយប្រហារអាចត្រូវបានធ្វើឡើងប្រឆាំងតែនឹងអ្នកប្រយុទ្ធតែប៉ុណ្ណោះ។ ការវាយប្រហារមិនត្រូវធ្វើប្រឆាំងនឹងជនស៊ីវិលទេ [IAC/NIAC] ។

**វិធាន២.-**

អំពើហិង្សា ឬ ការគំរាមកំហែងប្រើអំពើហិង្សាដែលបំណងចំបងរបស់វាគឺ ដើម្បីធ្វើឱ្យមានការភ័យរន្ធត់រីករាលដាលក្នុងចំណោមប្រជាជនស៊ីវិល ត្រូវបានហាមឃាត់ជាដាច់ខាត់ [IAC/NIAC] ។

**វិធាន៣.-**

សមាជិកទាំងអស់នៃកងកំលាំងប្រដាប់អាវុធរបស់ភាគីជម្លោះគឺជាអ្នកប្រយុទ្ធលើកលែងក្រុមបុគ្គលិកសាសនានិងក្រុមពេទ្យ [IAC] ។

**វិធាន៤.-**

កងកំលាំងប្រដាប់អាវុធនៃភាគីជម្លោះមានន័យសំដៅទៅលើកងកំលាំងទ័ពទាំងអស់ដែលត្រូវបានចូលរួម ក្នុងការវាយប្រហារក្រុមនិងអង្គភាពដែលស្ថិតក្រោមបញ្ជាការទទួលខុសត្រូវរបស់ភាគី ចំពោះការប្រព្រឹត្តរបស់អ្នកក្រោមបង្គាប់របស់ខ្លួន [IAC] ។

**វិធាន៥.-**

ជនស៊ីវិលគឺជាបុគ្គលដែលមិនមែនជាសមាជិកនៃកងកំលាំងប្រដាប់អាវុធ។ ប្រជាជនស៊ីវិលគឺបុគ្គលទាំងអស់ដែលជាជនស៊ីវិល [IAC/NIAC] ។

**វិធាន៦.-**

ជនស៊ីវិលត្រូវបានការពារទប់ទល់នឹងការវាយប្រហារប្រសិនបើ និងក្នុងពេលនោះពួកគេមិនបានចូលរួមដោយផ្ទាល់ក្នុងជំលោះ [IAC/NIAC] ។

### ២. ការបែងចែករវាងវត្ថុ/សំភារៈស៊ីវិលនិងគោលដៅយោធា

**(Distinction between Civilian Objects and Military Objectives)**

**វិធាន៧.-**

ភាគីជម្លោះ នៅគ្រប់ពេលទាំងអស់ត្រូវបែងចែកដាច់ដោយឡែករវាងវត្ថុស៊ីវិល និងគោលដៅយោធា។ ការវាយប្រហារអាចត្រូវបានធ្វើប្រឆាំងនឹងគោលដៅយោធាតែប៉ុណ្ណោះ។ ការវាយប្រហារមិនត្រូវធ្វើឡើងសំដៅលើវត្ថុស៊ីវិលទេ[IAC/NIAC] ។

**វិធាន៨.-**

ចំពោះវត្ថុគោលដៅយោធាត្រូវបានកំរិតចំពោះវត្ថុទាំងឡាយណាដែលដោយសារចរិតទីតាំងគោលបំណង និងការប្រើប្រាស់របស់វា ធ្វើអោយមានការរួមចំណែកមានប្រសិទ្ធភាពដល់សកម្មភាពយោធា ហើយដែលការបំផ្លាញទាំងស្រុង ឬដោយ

អន្លើការរឹបយក ការធ្វើឱ្យនៅអព្យាក្រឹតក្នុងកាលៈទេសៈមាននៅពេលនោះ ផ្តល់នូវប្រយោជន៍ផ្នែកយោធាជាក់លាក់បាន [IAC/NIAC] ។

**វិធាន៩,-**

វត្ថុស៊ីវិលគឺជាវត្ថុដែលមិនមែនជាគោលដៅយោធា [IAC/NIAC] ។

**វិធាន១០,-**

វត្ថុស៊ីវិលត្រូវបានការពារប្រឆាំងទល់នឹងការវាយប្រហារលើកលែងតែ ហើយនៅក្នុងពេលនេះពួកគេជា គោលដៅផ្នែកយោធា [IAC/NIAC] ។

## ៣. ការវាយប្រហារមិនរើសអើង (Indiscriminate Attacks)

**វិធាន១១,-**

ការវាយប្រហារមិនរើសមុខត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន១២,-**

ការវាយប្រហារមិនរើសអើងមានដូចជាការវាយប្រហារ :

(ក) ដែលមិនសំដៅចំពោះគោលដៅយោធាជាក់លាក់ណាមួយ ។

(ខ) ដែលប្រើប្រាស់វិធីឬមធ្យោបាយប្រយុទ្ធដែលមិនអាចសំដៅគោលដៅយោធាជាក់លាក់ណាមួយ ។

(គ) ដែលប្រើប្រាស់វិធី ឬមធ្យោយបាយប្រយុទ្ធដែលផលប៉ះពាល់របស់វា មិនអាចបន្ទួរបន្ថយបានឱ្យស្រប់ទៅតាមការទាមទារនៃច្បាប់មនុស្សធមិអន្តរជាតិ ហើយជាផលវិបាកក្នុងករណីនីមួយៗ មានចរិតជាការវាយប្រហារគោលដៅយោធា និងជនស៊ីវិល ឬវត្ថុស៊ីវិលដោយគ្មានបែងចែក [IAC/NIAC] ។

**វិធាន១៣,-**

ការវាយប្រហារដោយទំលាក់គ្រាប់បែកតាមមធ្យោបាយ ឬ វិធីណាមួយដែលចាត់ទុកថាជាគោលដៅយោធាតែមួយនូវគោលដៅយោធាដោយឡែក និងជាក់លាក់មួយចំនួនមានទីតាំងនៅក្នុងក្រុងភូមិ ឬកន្លែងដទៃទៀតដែលមានការប្រមូលផ្តុំជនស៊ីវិល ឬវត្ថុស៊ីវិលត្រូវបានហាមឃាត់ [IAC/NIAC] ។

## ៤. ភាពសមមាត្រក្នុងការវាយប្រហារ (Proportionality in Attack)

**វិធាន១៤,-**

ការផ្តើមវាយប្រហារដែលអាចត្រូវបានរំពឹងទុកនាំអោយមានការបាត់បង់ជីវិតជនស៊ីវិល កើតមានរបួសស្នាមដល់ជនស៊ីវិលការខូចខាតដល់វត្ថុស៊ីវិល ឬ ការរួមបញ្ចូលទាំងអស់ដែលវាលើសហួស បើធៀបជាមួយប្រយោជន៍យោធាជាក់លាក់ និងដោយផ្ទាល់ដែលត្រូវបានរំពឹងទុកត្រូវហាមឃាត់ [IAC/NIAC] ។

## ៥. ការប្រយ័ត្នប្រយែងក្នុងការវាយប្រហារ (Precaution in Attack)

**វិធាន១៥,-**

ក្នុងការធ្វើប្រតិបត្តិការយោធាការប្រយ័ត្នប្រយែងជានិច្ចត្រូវតែប្រកាន់យក ដើម្បីថែរក្សាប្រជាជនស៊ីវិលជនស៊ីវិល និងវត្ថុស៊ីវិល ។ ការប្រយ័ត្នប្រយែងដែលអាចធ្វើបានទាំងអស់ត្រូវប្រកាន់យកដើម្បីបញ្ចៀសនិងដើម្បីកាត់បន្ថយជាអប្បបរមាការបាត់បង់កើតមានចំពោះអាយុជីវិតជនស៊ីវិលរបួសស្នាមដល់ជនស៊ីវិល នឹងមានការខូចខាតដល់វត្ថុស៊ីវិល [IAC/NIAC] ។

**វិធាន១៦,-**

ភាគីក្នុងជម្លោះនីមួយៗ ត្រូវធ្វើគ្រប់កិច្ចការដែលអាចធ្វើបាន ដើម្បីធ្វើឱ្យប្រាកដថាគោលដៅវាយប្រហារ គឺជាគោលដៅយោធា (IAC/NIAC] ។

**វិធាន១៧,-**

ភាគីក្នុងជម្លោះនីមួយៗ ត្រូវប្រកាន់យកការប្រុងប្រយ័ត្នដែលអាចធ្វើបានទាំងអស់ក្នុងជំរើសនៃមធ្យោបាយ និងវិធីធ្វើសង្គ្រាម ដើម្បីបញ្ចៀស និងកាត់បន្ថយជាអប្បបរមានូវការបាត់បង់ដែលកើតមានឡើងដល់ជីវិតជនស៊ីវិលរបួសស្នាមដល់ជនស៊ីវិល ការខូចខាតវត្ថុស៊ីវិល [IAC/NIAC] ។

**វិធាន១៨,-**

ភាគីក្នុងជម្លោះនីមួយៗ ត្រូវធ្វើកិច្ចការដែលអាចធ្វើបានដើម្បីប៉ាន់ប្រមាណថា តើការវាយប្រហារដែលរំពឹងទុកនឹងបង្ករការបាត់បង់ដែលកើតមានឡើងដល់ជីវិតជនស៊ីវិលរបួសស្នាមដល់ជនស៊ីវិលការខូចខាតដល់វត្ថុស៊ីវិល ឬ ការរួមបញ្ចូលការខូចខាតទាំងអស់ ដែលអាចលើសពីប្រយោជន៍ផ្នែកយោធាផ្ទាល់ និងជាក់លាក់ដែលបានរំពឹងទុកដែរឬទេ [IAC/NIAC] ។

**វិធាន១៩,-**

ភាគីជម្លោះនីមួយៗ ត្រូវធ្វើកិច្ចការដែលអាចធ្វើបានដើម្បីលុបចោល ឬ ផ្អាកការវាយប្រហារប្រសិន បើវាជាក់ច្បាស់ថាគោលដៅមិនមែនជាគោលដៅយោធា ឬ ថាការវាយប្រហារអាចនឹងមានឡើង នឹងបង្ករការបាត់បង់ជីវិតជនស៊ីវិលដែលអាចកើតមានរបួសស្នាមដល់ជនស៊ីវិល ការខូចខាតដល់វត្ថុស៊ីវិល ឬ ការរួមបញ្ចូលការខូចខាតដែលអាចលើសពីប្រយោជន៍ទាហានដោយផ្ទាល់ និងជាក់លាក់ដែលត្រូវបានរំពឹងទុក [IAC/NIAC] ។

**វិធាន២០,-**

ភាគីជម្លោះនីមួយៗ ត្រូវផ្តល់ការព្រមានជាមុន អំពីការវាយប្រហារដែលអាចប៉ះពាល់ដល់ប្រជាជនស៊ីវិលលើកលែងតែស្ថានភាពមិនអនុញ្ញាត [IAC/NIAC] ។

**វិធាន២១,-**

នៅពេលជំរើសមួយ អាចកើតមានរវាងគោលដៅយោធាជាច្រើនសំរាប់ទទួលបានផលប្រយោជន៍យោធា ស្រដៀងគ្នា គោលដៅដែលនឹងត្រូវបានជ្រើសរើស ត្រូវតែជាការវាយប្រហារដែលផ្អែកលើការវាយប្រហារនេះអាចកើតមាននឹងបង្ករគ្រោះថ្នាក់តិចតួចដល់អាយុជីវិតជនស៊ីវិល និងដល់វត្ថុស៊ីវិល [IAC/arguably NIAC] ។

## ៦. ការប្រយ័ត្នប្រយែងទល់នឹងផលវិបាកនៃការវាយប្រហារ (Precaution against the Effects of Attacks)

**វិធាន២២,-**

ភាគីជម្លោះត្រូវប្រកាន់យកភាពប្រុងប្រយ័ត្ន ដែលអាចធ្វើបានទាំងអស់ ដើម្បីការពារប្រជាជនស៊ីវិល និងវត្ថុស៊ីវិល ក្រោមការគ្រប់គ្រងរបស់ពួកខ្លួនទល់នឹងផលវិបាកនៃការវាយប្រហារ [IAC/NIAC] ។

**វិធាន២៣,-**

ស្របតាមក៏រិតដែលអាចធ្វើបាន ភាគីជម្លោះនីមួយៗត្រូវជៀសវៀងការបោះទីតាំង/គោលដៅយោធាក្នុង ឬនៅក្បែរ

តំបន់ដែលមានប្រជាជនកកកុញ ។ [IAC/អាចនិយាយបានថា អនុវត្តចំពោះ NIAC] ។

**វិធាន២៤.-**

ស្របតាមក៏រិតដែលអាចធ្វើបានភាគីជំលោះនីមួយៗត្រូវដកចេញនូវប្រជាជន និងវត្ថុស៊ីវិលក្រោមការគ្រប់គ្រងរបស់ខ្លួនពីទីតាំងយោធា [IAC/ អាចនិយាយបានថា អនុវត្តចំពោះ NIAC] ។

## ជំពូកទី២. វត្ថុ និងមនុស្សដែលត្រូវការការពារជាពិសេស
**(Specifically Protected Persons and Objects)**

### ៧. វត្ថុ និងបុគ្គលិកសាសនា និងបុគ្គលិកពេទ្យ (Medicial and Religious Personnel and Objects)

**វិធាន២៥.-**

បុគ្គលិកពេទ្យ ដែលត្រូវបានតែងតាំងសំរាប់តែបំពេញកាតព្វកិច្ចពេទ្យត្រូវបានគោរព និងការពារនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ពួកគេបាត់បង់ការការពារ ប្រសិនបើពួកគេប្រព្រឹត្តអំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សត្រូវក្រៅពីតួនាទីផ្នែកមនុស្សធម៌របស់ពួកគេ [IAC/NIAC] ។

**វិធាន២៦.-**

ការដាក់ទណ្ឌកម្មលើបុគ្គល ចំពោះការបំពេញកាតព្វកិច្ចពេទ្យ ស្របតាមក្រមសីលធម៌ពេទ្យ ឬ ការបង្ខំអោយបុគ្គលិកណាម្នាក់ចូលរួមក្នុងសកម្មភាពពេទ្យដើម្បីធ្វើអំពើផ្ទុយក្រមសីលធម៌ពេទ្យត្រូវហាមឃាត់ [IAC/ NIAC] ។

**វិធាន២៧.-**

បុគ្គលិកសាសនាដែលត្រូវបានតែងតាំងសំរាប់ធ្វើតែកិច្ចការសាសនា ត្រូវបានគោរពនិងការពារនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ពួកគេបាត់បង់ការការពារ ប្រសិនបើពួកគេប្រព្រឹត្តក្រៅពីតួនាទីមនុស្សធម៌របស់ពួកគេដែលធ្វើអោយគ្រោះថ្នាក់ដល់សត្រូវ [IAC/NIAC] ។

**វិធាន២៨.-**

អង្គភាពពេទ្យ ដែលត្រូវបានតែងតាំងសំរាប់តែគោលដៅពេទ្យត្រូវតែគោរព និងការពារនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ពួកគេបាត់បង់ការការពារ ប្រសិនបើពួកគេកំពុងត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តអំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សត្រូវក្រៅពីតួនាទីមនុស្សធម៌របស់ពួកគេ ។ [IAC/NIAC] ។

**វិធាន២៩.-**

អ្នកដឹកជញ្ជូនផ្នែកពេទ្យ ដែលត្រូវបានតែងតាំងសំរាប់តែការដឹកនាំផ្នែកពេទ្យត្រូវតែគោរព និងការពារនៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ពួកគេបាត់បង់ការការពារប្រសិនពួកគេកំពុងត្រូវបានប្រើប្រាស់ក្រៅតួនាទី មនុស្សធម៌របស់ខ្លួនដើម្បីប្រព្រឹត្តអំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សត្រូវ [IAC/NIAC] ។

**វិធាន៣០.-**

ការវាយប្រហារប្រឆាំងនឹងវត្ថុ និងបុគ្គលិកពេទ្យ និងសាសនាដែលដាក់បង្ហាញនូវផ្លាកសញ្ញាដោយឡែកនៃសន្ធិសញ្ញាហ្សឺណែវស្របតាមច្បាប់អន្តរជាតិត្រូវបានហាមឃាត់ [IAC/NIAC] ។

### ៨. វត្ថុ និងបុគ្គលិកសង្គ្រោះមនុស្សធម៌ (Humanitarian Relief Personel and Objects)

**វិធាន៣១.-**

បុគ្គលិកសង្គ្រោះមនុស្សធម៌ត្រូវតែទទួលបានការគោរព និងការការពារ [IAC/NIAC] ។

**វិធាន៣២.-**

វត្ថុដែលត្រូវបានប្រើប្រាស់សំរាប់ដំណើរការសង្គ្រោះមនុស្សធម៌ត្រូវបានគោរព និងការពារ [IAC/ NIAC] ។

## ៩. បុគ្គលិក និងវត្ថុចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាព

**(Personnel and Objects Involved in a Peacekeeping Mission)**

**វិធាន៣៣.-**

ការធ្វើការវាយប្រហារប្រឆាំងនឹងបុគ្គលិក និងវត្ថុចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ឱ្យតែពួកគេទទួលបានការការពារផ្តល់ដល់ជនស៊ីវិល និងវត្ថុស៊ីវិលក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវបានហាមឃាត់ [IAC/NIAC] ។

## ១០. ក្រុមអ្នកកាសែត (Journalists)

**វិធាន៣៤.-**

អ្នកសារព័ត៌មានជាជនស៊ីវិលដែលចូលរួមក្នុងបេសកកម្មវិជ្ជាជីវៈនៅក្នុងតំបន់ជម្លោះប្រដាប់អាវុធ ត្រូវតែទទួលបានការគោរព និងការពារឱ្យតែពួកគេមិនចូលរួមដោយផ្ទាល់ក្នុងជម្លោះ [IAC/NIAC] ។

## ១១. តំបន់ដែលត្រូវបានការពារ (Protected Zones)

**វិធាន៣៥.-**

ការវាយប្រហារប្រឆាំងលើតំបន់បង្កើតឡើងដើម្បីផ្តល់ទីជម្រកដល់អ្នករងរបួសអ្នកមានជំងឺ និងជនស៊ីវិលរួចពីផលប៉ះពាល់នៃជម្លោះត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៣៦.-**

ការវាយប្រហារប្រឆាំងតំបន់លែងមានសកម្មភាពយោធា ដែលត្រូវបានឯកភាពដោយភាគីជម្លោះត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៣៧.-**

ការវាយប្រហារប្រឆាំងនឹងទីតាំងគ្មានការការពារត្រូវបានហាមឃាត់ [IAC/NIAC] ។

## ១២. ទ្រព្យសម្បត្តិវប្បធម៌ (Cultural Property)

**វិធាន៣៨.-**

ភាគីជម្លោះនីមួយៗ ត្រូវគោរពទ្រព្យសម្បត្តិវប្បធម៌ ៖

(ក) ការប្រយ័ត្នប្រយែងជាពិសេសត្រូវតែបានប្រកាន់យកក្នុងប្រតិបត្តិការយោធា ដើម្បីបញ្ចៀសការខូចខាតដល់

អាគារសំរាប់កិច្ចការសាសនាសិល្បៈ វិទ្យាសាស្ត្រការអប់រំ ឬ គោលបំណងមនុស្សធម៌ និងវិមានប្រវត្តិសាស្ត្រលើកលែងតែពួកគេជាគោលដៅយោធា ។

(ខ) ទ្រព្យសម្បត្តិសំខាន់សំរាប់មរតកវប្បធម៌នៃប្រជាជនគ្រប់រូបមិនត្រូវជាកម្មវត្ថុនៃការវាយប្រហារ ឡើយលុះត្រាទាមទារជាដាច់ខាតដោយភាពចាំបាច់ខាងផ្នែកយោធា [IAC/NIAC] ។

**វិធាន៣៩.-**

ការប្រើប្រាស់ទ្រព្យសម្បត្តិសារៈប្រយោជន៍ដល់មរតកវប្បធម៌នៃប្រជាជនគ្រប់រូប សំរាប់គោលបំណងដែលទំនងជានាំអោយមានការបំផ្លាញ ឬខូចខាតត្រូវបានហាមឃាត់លើកលែងតែមានការទាមទារជាចាំបាច់របស់យោធា [IAC/NIAC] ។

**វិធាន៤០.-**

ភាគីជម្លោះនីមួយៗ ត្រូវការពារព្រទ្យសម្បត្តិវប្បធម៌ៈ

(ក) គ្រប់ការរឹបអូស ឬ ការបំផ្លាញ ឬការធ្វើអោយខូចខាតធ្វើចំពោះស្ថាប័នប្រើប្រាស់សំរាប់សាសនា មនុស្សធម៌ការអប់រំសិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ និងស្នាដៃសិល្បៈ និងវិទ្យាសាស្ត្រត្រូវហាមឃាត់ ។

(ខ) អំពើលួចឬឆក់ប្លន់បែបណាក៏ដោយ ឬ ការរឹបអូសមិនសមស្រប និងទង្វើណាមួយជាការបំផ្លាញនូវទ្រព្យសម្បត្តិដែលមានសារៈសំខាន់ជាខ្លាំងដល់មរតកវប្បធម៌នៃប្រជាជនគ្រប់រូបត្រូវហាមឃាត់ [IAC/NIAC] ។

**វិធាន៤១.-**

ភាគីកាន់កាប់ត្រូវបង្ការការនាំចេញខុសច្បាប់នៃទ្រព្យសម្បត្តិវប្បធម៌ពីដែនដីដែលខ្លួនកាន់កាប់ ហើយត្រូវប្រគល់ត្រឡប់មកវិញនូវទ្រព្យសម្បត្តិនាំចេញខុសច្បាប់ ជូនដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ដែនដីដែលត្រូវបានកាន់កាប់ [IAC] ។

## ១៣. ស្នាដៃ និងទីតាំងមានសារធាតុគ្រោះថ្នាក់ (Works and Installation Containing Dangerous Forces)

**វិធាន៤២.-**

ការប្រុងប្រយ័ត្នជាពិសេសត្រូវតែប្រកាន់យកប្រសិនបើស្នាដៃ ឬមូលដ្ឋានមានសារធាតុគ្រោះថ្នាក់ ដូចជា ទំនប់ទឹកព្រែកជីក និងស្ថានីយបង្កើត (នុយក្លេអ៊ែរ) (Nuclear Electrical Generating station) និងទីតាំងផ្សេងទៀតតាំងនៅឯ ឬនៅកន្លែងដែលត្រូវបានវាយប្រហារដើម្បីបញ្ចៀសនូវការបញ្ចេញសារធាតុគ្រោះ ថ្នាក់ព្រមទាំងការបាត់បង់ធ្ងន់ធ្ងរកើតមានជាបន្ទាប់ក្នុងចំណោមប្រជាជនស៊ីវិល [IAC/NIAC] ។

## ១៤. បរិស្ថានធម្មជាតិ (The Natural Environment)

**វិធាន៤៣.-**

គោលការណ៍ទូទៅស្តីពីការប្រព្រឹត្តអរិភាព អនុវត្តចំពោះបរិស្ថានធម្មជាតិៈ

(ក) មិនបានផ្នែកណាមួយនៃបរិស្ថានធម្មជាតិអាចត្រូវបានវាយប្រហារលើកលែងតែវាជាគោលដៅយោធា ។

(ខ) ការបំផ្លាញផ្នែកណាមួយនៃបរិស្ថានធម្មជាតិត្រូវបានហាមឃាត់ លើកលែងតែវាត្រូវបានទាមទារ ដោយភាពចាំបាច់នៃផ្នែកយោធា ។

(គ) ការផ្តើមវាយប្រហារប្រឆាំងនឹងគោលដៅយោធាដែលអាចរំពឹងថា នឹងបង្ករឱ្យមានការខូចខាតកើតមានឡើងដល់បរិស្ថានដែលវាលើសហួសបើធៀបនឹងផលប្រយោជន៍ផ្នែកយោធាផ្ទាល់ និងជាក់លាក់ដែលត្រូវបានរំពឹងត្រូវបានហាមឃាត់

[IAC/NIAC] ។

**វិធាន៤៤.-**

វិធីសាស្ត្រ ឬមធ្យោបាយនៃចំបាំងត្រូវបានប្រើប្រាស់ ដោយពិចារណាអោយបានត្រឹមត្រូវដល់ការការពារ និងថែរក្សាបរិស្ថានធម្មជាតិ។ នៅក្នុងការធ្វើប្រតិបត្តិការយោធាការប្រុងប្រយ័ត្នទាំងអស់ដែលអាចធ្វើបាន ត្រូវតែបានប្រកាន់យកដើម្បីបញ្ចៀស ឬ កាត់បន្ថយជាអប្បបរមា នូវការខូចខាតដែលអាចកើតមានដល់បរិស្ថាន។ ភាពខ្វះខាតនៃភាពជាក់លាក់ផ្នែកវិទ្យាសាស្ត្រពាក់ព័ន្ធផលប៉ះពាល់ដល់បរិស្ថាននៃប្រតិបត្តិការយោធាមួយចំនួន មិនអាចធ្វើឱ្យភាគីជម្លោះរួចផុតពីការប្រកាន់យកការប្រុងប្រយ័ត្នឡើយ [IAC/ អាចនិយាយបានថាអនុវត្តចំពោះ NIAC] ។

**វិធាន៤៥.-**

ការប្រើប្រាស់វិធីសាស្ត្រឬ មធ្យោបាយធ្វើសឹកសង្គ្រាមដែលត្រូវបានគ្រោងឬ អាចកើតមានដែល បង្ករការខូចខាតធ្ងន់ធ្ងរ និងយូរអង្វែង និងជាទូទៅ ដល់បរិស្ថានធម្មជាតិត្រូវបានហាមឃាត់ ។ ការបំផ្លាញបរិស្ថាន ធម្មជាតិ មិនអាចត្រូវបានប្រើប្រាស់ដូចជាអាវុធទេ [IAC/ អាចនិយាយបានថាអនុវត្តចំពោះ NIAC] ។

## ជំពូកទី៣. វិធីជាក់លាក់នៃការធ្វើសឹកសង្គ្រាម

**(Specific Methods of Warfare)**

### ១៥. ការមិនផ្តល់របបអាហារ (Denial Quarter)

**វិធាន៤៦.-**

ការដាក់បញ្ជាថា មិនមានរបបអាហារ នឹងត្រូវបានផ្តល់ការគំរាមកំហែងគូសត្រូវជាមួយការបង្អត់អាហារ ឬ ការប្រព្រឹត្តអរិភាពផ្អែកលើមូលដ្ឋាននេះត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៤៧.-**

ការវាយប្រហារលើបុគ្គល ដែលត្រូវបានទទួលស្គាល់ថាលែងមានសមត្ថភាពប្រយុទ្ធ គឺត្រូវបានហាមឃាត់ ។ បុគ្គលដែលលែងមានសមត្ថភាពប្រយុទ្ធរួមមាន:

(ក) បុគ្គលណាមួយដែលស្ថិតនៅក្នុងអំណាចរបស់ដៃគូសត្រូវ ។

(ខ) បុគ្គលដែលមិនមានការការពារដោយសារការបាត់បង់ស្មារតី ដោយសារកប៉ាល់ខូចខាតរបួស ឬជំងឺ ។

(គ) បុគ្គលណាមួយដែលសំដែងឆន្ទៈយ៉ាងច្បាស់លាស់មានបំណងចុះចាញ់អោយតែគាត់ ឬ នាងដកខ្លួនពីអំពើអរិភាពណាមួយហើយមិនបានព្យាយាមគេចចេញ [IAC/NIAC] ។

**វិធាន៤៨.-**

ចាត់ទុកបុគ្គលលោតចេញពីយន្តហោះក្នុងពេលមានវិបត្តិ ជាកម្មវត្ថុនៃការវាយប្រហារក្នុងអំឡុងពេលធ្លាក់ចុះត្រូវបានហាមឃាត់ [IAC/NIAC] ។

### ១៦. ការបំផ្លាញ និងការរឹបអូសទ្រព្យសម្បត្តិ (Destruction and Seizure of Property)

**វិធាន៤៩.-**

ភាគីជម្លោះអាចរឹបអូសយកសំភារៈយោធាជារបស់គូសត្រូវជាទ្រព្យជ័យវណ្ណ [IAC] ។

**វិធាន៥០.-**

ការបំផ្លាញ ឬ រឹបអូសទ្រព្យសម្បត្តិរបស់សត្រូវត្រូវបានហាមឃាត់លើកលែងទាមទារដោយភាពចាំបាច់ដាច់ខាតខាងផ្នែកយោធា [IAC/NIAC] ។

**វិធាន៥១.-**

នៅក្នុងដែនដីដែលត្រូវបានកាន់កាប់:

(ក) ទ្រព្យចលនវត្ថុសាធារណៈ ដែលអាចប្រើប្រាស់សំរាប់ប្រតិបត្តិការយោធាអាចនឹងត្រូវបានរឹបអូស ។

(ខ) ទ្រព្យអចលនវត្ថុសាធារណៈត្រូវតែបានចាត់ចែងតាមគោលការណ៍ អ៊ូស៊ូហ្វ្រ៊ិក (usufruct) (ដែលមានន័យថាសិទ្ធិទទួលនូវផលចំណេញ ឬផលប្រយោជន៍ពីអ្វីមួយដែលជារបស់ផងអ្នកដទៃ) និង

(គ) ទ្រព្យឯកជននឹងត្រូវបានគោរពហើយមិនអាចត្រូវបានរឹបអូសលើកលែងករណីដែលការបំផ្លាញ ឬរឹបអូសនៃទ្រព្យសម្បត្តិនោះ ត្រូវបានទាមទារជាចាំបាច់ខាងផ្នែកយោធា [IAC] ។

**វិធាន៥២.-**

អំពើឆក់ប្លន់ត្រូវហាមឃាត់ [IAC/NIAC] ។

## ១៧. ការបង្អត់អាហារ និងការទទួលបានជំនួយសង្គ្រោះមនុស្សធម៌

**(Starvation and Access to Humanitarian Relief)**

**វិធាន៥៣.-**

ការប្រើប្រាស់ការបង្អត់អាហារលើប្រជាជនស៊ីវិលសំរាប់វិធីសាស្ត្រធ្វើសឹកសង្គ្រាមត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៥៤.-**

ការវាយប្រហារ ការបំផ្លិចបំផ្លាញការដកចេញ ឬ ការធ្វើអោយឥតប្រយោជន៍នៃវត្ថុចាំបាច់សំរាប់ការរស់រានមានជីវិតនៃប្រជាជនស៊ីវិលត្រូវហាមឃាត់ [IAC/NIAC] ។

**វិធាន៥៥.-**

ភាគីជម្លោះត្រូវអនុញ្ញាត និងសម្របសម្រួលការឆ្លងកាត់ឱ្យបានឆាប់រហ័ស និងគ្មានការបង្អាក់នូវជំនួយមនុស្សធម៌សំរាប់ប្រជាជនស៊ីវិលដែលត្រូវការដែលមិនលំអៀង ហើយត្រូវបានប្រព្រឹត្តដោយគ្មានការបែងចែកដោយស្ថិតនៅក្រោមសិទ្ធិនៃការគ្រប់គ្រង [IAC/NIAC] ។

**វិធាន៥៦.-**

ភាគីជម្លោះត្រូវធានាថា ផ្តល់សេរីភាពក្នុងការដើរហើរនៃបុគ្គលិកសង្គ្រោះមនុស្សធម៌ដែលត្រូវអនុញ្ញាត ចាំបាច់ក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ លើកលែងមានភាពចាំបាច់ផ្នែកយោធាតែប៉ុណ្ណោះ ដែលសេរីភាពដើរហើរអាចត្រូវបានបិទហាមជាបណ្តោះអាសន្ន [IAC/NIAC] ។

## ១៨. ការបំភាន់ **(Deception)**

**វិធាន៥៧.-**

ល្បិចកលសង្គ្រាម មិនត្រូវបានហាមឃាត់ដរាបណាល្បិចទាំងនោះមិនរំលោភវិធានច្បាប់មនុស្សធម៌អន្តរជាតិ [IAC/NIAC] ។

**វិធាន៥៨.-**

ការប្រើប្រាស់មិនសមស្របនូវទង់ពណ៌សត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៥៩.-**

ការប្រើប្រាស់មិនសមស្របនូវផ្លាកសញ្ញាដោយឡែកនៃអនុសញ្ញាក្រុងហ្សឺណែវត្រូវបានហាមឃាត់ [IAC/ NIAC] ។

**វិធាន៦០.-**

ការប្រើប្រាស់ទង់របស់អង្គការសហប្រជាជាតិ និងឯកសណ្ឋានត្រូវបានហាមឃាត់លើកលែងត្រូវបានអនុញ្ញាតដោយអង្គការនេះ [IAC/NIAC] ។

**វិធាន៦១.-**

ការប្រើប្រាស់មិនសមស្របនូវទង់ដទៃទៀតដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៦២.-**

ការប្រើប្រាស់មិនសមស្របនូវទង់ ឬ ផ្លាកសញ្ញាយោធាឯកសណ្ឋាននៃភាគីសត្រូវត្រូវហាមឃាត់ [IAC/អាចនិយាយបានថាអនុវត្តចំពោះ NIAC] ។

**វិធាន៦៣.-**

ការប្រើប្រាស់ទង់ ឬ ផ្លាកទាហានឯកសណ្ឋាននៃជនអព្យាក្រិត្យ ឬ របស់រដ្ឋដទៃដែលមិនមែនជាភាគីជម្លោះត្រូវហាមឃាត់ [IAC អាចនិយាយបានថា អនុវត្តចំពោះ NIAC] ។

**វិធាន៦៤.-**

ការចុះកិច្ចព្រមព្រៀងដើម្បីផ្អាកការវាយប្រហារជាមួយចេតនា ដើម្បីវាយប្រហារដោយការពញ្ញាក់សត្រូវដែលផ្អែកលើកិច្ចព្រមព្រៀងនោះត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៦៥.-**

ការសំលាប់ការធ្វើឱ្យមានរបួស ឬ ការចាប់សត្រូវដោយប្រើប្រាស់ការបំភាន់ត្រូវបានហាមឃាត់ [IAC/NIAC] ។

## ១៩. ទំនាក់ទំនងជាមួយសត្រូវ (Communication with the Enemy)

**វិធាន៦៦.-**

មេបញ្ជាការអាចធ្វើទំនាក់ទំនងមិនមែនជាអរិភាព (Non-Hostile Contact) តាមរយៈមធ្យោបាយទំនាក់ទំនងណាមួយ ។ ទំនាក់ទំនងនោះត្រូវតែផ្អែកលើភាពសុទ្ធចិត្ត [IAC/NIAC] ។

**វិធាន៦៧.-**

សមាជិកសភា គឺជាបុគ្គលមិនអាចត្រូវបំពារបំពានបានឡើយ [IAC/NIAC] ។

**វិធាន៦៨.-**

មេបញ្ជាការអាចប្រកាន់យកការប្រុងប្រយ័ត្ន ដើម្បីបង្ការវត្តមាននៃសមាជិកសភាពីគ្រោះថ្នាក់ [IAC/ NIAC] ។

**វិធាន៦៩.-**

សមាជិកសភាដែលប្រើប្រាស់តំណែងដែលមានបុព្វសិទ្ធិរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើផ្ទុយច្បាប់អន្តរជាតិ និងធ្វើឱ្យខូច

ខាតដល់សត្រូវ នឹងត្រូវបាត់បង់ភាពដែលមិនអាចបំពារបំពានរបស់ខ្លួន [IAC/NIAC] ។

## ជំពូកទី៩. សព្វាវុធ
**(Weapons)**

### ២០. គោលការណ៍ទូទៅនៃការប្រើប្រាស់សព្វាវុធ (General Principles on the Use of Weapons)

**វិធាន៧០.-**

ការប្រើប្រាស់មធ្យោបាយ និងវិធីសាស្ត្រធ្វើសង្គ្រាមដែលមានចរិតលក្ខណៈបង្ករបួសជាបន្ថែម ឬ ការឈឺចាប់ដែលមិនចាំបាច់ត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៧១.-**

ការប្រើប្រាស់សព្វាវុធដែលតាមលក្ខណៈប្រភេទរបស់វាបង្ករគ្រោះថ្នាក់មិនរើសអើងត្រូវបានហាមឃាត់ [IAC/NIAC] ។

### ២១. ជាតិពុល (Poison)

**វិធាន៧២.-**

ការប្រើប្រាស់ជាតិពុល ឬអាវុធជាតិពុលត្រូវបានហាមឃាត់ [IAC/NIAC] ។

### ២២. អាវុធជីវសាស្ត្រ (Biological Weapons)

**វិធាន៧៣.-**

ការប្រើប្រាស់អាវុធជីវសាស្ត្រត្រូវបានហាមឃាត់ [IAC/NIAC] ។

### ២៣. អាវុធជាតិគីមី (Chemical Weapons)

**វិធាន៧៤.-**

ការប្រើប្រាស់អាវុធជាតិគីមីត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៧៥.-**

ការប្រើប្រាស់សំភារៈគ្រប់គ្រងកុបកម្មជាវិធីសាស្ត្រសង្គ្រាមត្រូវហាមឃាត់ [IAC/NIAC] ។

**វិធាន៧៦.-**

ការប្រើប្រាស់ថ្នាំបំផ្លាញរុក្ខជាតិ ជាវិធីសាស្ត្រសង្គ្រាមត្រូវបានហាមឃាត់ប្រសិនបើពួកគេ:

(ក) មានលក្ខណៈ/ប្រភេទជាអាវុធគីមី ដែលត្រូវបានហាមឃាត់

(ខ) មានប្រភេទជាអាវុធជីវសាស្ត្រ ដែលត្រូវបានហាមឃាត់

(គ) ធ្វើឡើងដើម្បីបំផ្លាញការលូតលាស់រុក្ខជាតិ (Vegetation) ដែលមិនមែនជាគោលដៅយោធា

(ឃ) ដែលនាំឱ្យមានការបាត់បង់កើតមានឡើង ដល់ជីវិតជនស៊ីវិល របួសស្នាមដល់ជនស៊ីវិល ការខូចខាតដល់វត្ថុស៊ីវិល ឬខូចខាតរួមបញ្ចូលគ្នា ដែលអាចកើតមានលើសពីប្រយោជន៍យោធាជាក់លាក់ និងផ្ទាល់ដែលត្រូវបានរំពឹងទុក ឬ

(ង) ដែលអាចបង្ករការខូចខាតធ្ងន់ធ្ងរ យូរអង្វែង និងទូទៅដល់បរិស្ថានធម្មជាតិ [IAC/NIAC] ។

## ២៤. ក្បាលគ្រាប់កាំភ្លើងបំបែករូបរាង (Expanding Bullets)

### វិធាន៧៧.-

ការប្រើប្រាស់ ក្បាលគ្រាប់ដែលយកមកធ្វើការកែច្នៃ ដើម្បីឱ្យផ្ទុះបែកធំឬក៏ងាយស្រួលចូលជ្រៅនៅក្នុងរាងកាយមនុស្ស ត្រូវបានហាមឃាត់ [IAC/NIAC] ។

## ២៥. ក្បាលគ្រាប់កាំភ្លើងដែលអាចផ្ទុះ (Exploding Bullets)

### វិធាន៧៨.-

ការប្រើប្រាស់ប្រឆាំងមនុស្សនូវក្បាលគ្រាប់កាំភ្លើង ដែលអាចផ្ទុះនៅក្នុងរូបរាងកាយមនុស្សត្រូវបានហាមឃាត់ [IAC/NIAC] ។

## ២៦. សព្វាវុធបង្ករគ្រោះថ្នាក់ជាចំបងដោយសារសមាសភាគមិនអាចមើលឃើញ (Weapons Primarily Injuring by Non-detectable Fragments)

### វិធាន៧៩.-

ការប្រើប្រាស់អាវុធដែលផលប៉ះពាល់ជាចំបងរបស់វា គឺការបង្ករឱ្យមានរបួសដោយធាតុផ្សំរបស់វា ដែលមិនអាចរកឃើញដោយ X-Ray នៅក្នុងរូបរាងកាយរបស់មនុស្សត្រូវបានហាមឃាត់ [IAC/NIAC] ។

## ២៧. អន្ទាក់ជារូបភាពមនុស្ស (Booby-Traps)

### វិធាន៨០.-

ការប្រើប្រាស់អន្ទាក់ជារូបភាពមនុស្សដែលភ្ជាប់ ឬ មានជាមួយនូវវត្ថុ ឬ បុគ្គលដែលទទួលបានការការពារជាពិសេសក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ឬជាមួយវត្ថុដែលទំនងជាទាញចំណាប់អារម្មណ៍ជនស៊ីវិលត្រូវបានហាមឃាត់ [IAC/NIAC] ។

## ២៨. មីនកប់ក្នុងដី (Landmines)

### វិធាន៨១.-

នៅពេលមីនកប់ក្នុងដីត្រូវបានប្រើប្រាស់ ការប្រុងប្រយ័ត្នជាពិសេសត្រូវតែប្រកាន់យកដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់មិនរើសមុខរបស់វា [IAC/NIAC] ។

### វិធាន៨២.-

ភាគីជម្លោះណាមួយដែលប្រើប្រាស់មីនកប់ក្នុងដី ត្រូវកត់ត្រាកន្លែងដាក់ទៅតាមលទ្ធភាពដែលអាចធ្វើបាន [IAC អាច

និយាយបានថាទទួលស្គាល់ក្នុង NIAC] ។

**វិធាន៨៣.-**

នៅពេលបញ្ចប់ជម្លោះជាក់ស្តែងភាគីជម្លោះណាមួយ ដែលបានប្រើប្រាស់មីនកប់ក្នុងដីត្រូវដក ឬផ្សេងពីនេះធ្វើឱ្យមីននោះ លែងមានគ្រោះថ្នាក់ដល់ជនស៊ីវិល ឬសម្របសម្រួលការដកចេញ [IAC/NIAC] ។

### ២៩. អាវុធងាយនឹងផ្ទុះ (Incendiary Weapons)

**វិធាន៨៤.-**

ប្រសិនបើអាវុធដែលងាយនឹងផ្ទុះត្រូវបានប្រើប្រាស់ការប្រុងប្រយ័ត្នជាពិសេសត្រូវបានប្រកាន់យក ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមា នូវការបាត់បង់ដែលកើតមានលើជីវិតជនស៊ីវិលរបួសស្នាមដល់ជនស៊ីវិល និងការខូចខាតដល់វត្ថុស៊ីវិល [IAC/NIAC] ។

**វិធាន៨៥.-**

ការប្រើប្រាស់ប្រឆាំងមនុស្សនូវអាវុធដែលនឹងអាចផ្ទុះ ត្រូវតែហាមឃាត់លើកលែងតែវាមិនអាចធ្វើទៅរួចនូវការប្រើប្រាស់អាវុធដែលមានគ្រោះថ្នាក់តិចតួចដើម្បីធ្វើអោយបុគ្គលលែងមានសមត្ថភាពប្រយុទ្ធ [IAC/ NIAC] ។

### ៣០. អាវុធធ្វើអោយមានចំណាំងខ្វាក់ភ្នែក (Blinding Laser Weapon)

**វិធាន៨៦.-**

ការប្រើប្រាស់អាវុធ ឡាសេរ ដែលត្រូវបានបង្កើតឡើងជាពិសេសសំរាប់តែតួនាទីវាយប្រហារតែប៉ុណ្ណោះ ឬតួនាទីមួយក្នុងចំណោមតួនាទីវាយប្រហារ ដើម្បីបង្កនូវការពិការភ្នែកជាអចិន្ត្រៃយ៍ដល់ខ្សែចក្ខុដែលមិនអាចធ្វើអោយប្រសើរឡើងវិញបានត្រូវបានហាមឃាត់ [IAC/NIAC] ។

## ជំពូក៥. ការប្រព្រឹត្តលើជនស៊ីវិល និងអ្នកប្រយុទ្ធដែលលែងមានសមត្ថភាពប្រយុទ្ធ

**(Treatment of Civilians and Persons Hors de Combat)**

### ៣១. ការធានាជាមូលដ្ឋាន (Fundamental Guarantees)

**វិធាន៨៧.-**

ជនស៊ីវិល និងបុគ្គលដែលលែងមានសមត្ថភាពប្រយុទ្ធត្រូវតែប្រព្រឹត្តក្នុងលក្ខណៈមនុស្សធម៌ [IAC/ NIAC] ។

**វិធាន៨៨.-**

ការបែងចែកដាច់ដោយឡែកទៅក្នុងការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិដោយផ្អែកតាមពូជសាសន៍ពណ៌ ភេទ ភាសា សាសនា ឬជំនឿយោបល់នយោបាយដើមកំណើតសង្គម ឬ ជនជាតិទ្រព្យសម្បត្តិកំណើត ឬ ឋានៈដទៃទៀត ឬ ផ្អែកលើលក្ខណៈវិនិច្ឆ័យស្រដៀងគ្នានេះ ដទៃទៀតត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៨៩.-**

ការសំលាប់ត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩០,-**

ទារុណកម្មការប្រព្រឹត្តសាហាវយង់ឃ្នង ឬ អមនុស្សធម៌ និងកំរោលលើសេចក្តីថ្លៃថ្នូររបស់បុគ្គលជាពិសេសប្រព្រឹត្តអមនុស្សធម៌ និងអំពើបន្ទាបបន្ថោក ត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩១,-**

ទណ្ឌកម្មវាយដំត្រូវហាមឃាត់ [IAC/NIAC] ។

**វិធាន៩២,-**

ការកាត់រូបរាងកាយ ការពិសោធន៍វិទ្យាសាស្ត្រ ឬ ពេទ្យ ឬ នីតិវិធីពេទ្យដទៃទៀតមិនចាំបាច់តាមស្ថានភាពសុខភាពរបស់បុគ្គលពាក់ព័ន្ធ ហើយមិនស្របតាមបទដ្ឋានពេទ្យដែលត្រូវបានទទួលស្គាល់ជាទូទៅត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩៣,-**

ការរំលោភសេពសន្ថវៈ និងទំរង់ដទៃទៀតនៃហិង្សាផ្លូវភេទត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩៤,-**

ទាសភាព និងជំនួញទាសករនៅក្នុងគ្រប់ទំរង់ទាំងអស់ត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩៥,-**

ការងារដោយបង្ខំព្រមទាំងបំពារបំពាន ឬមិនទទួលបានកំរៃទូទាត់ត្រូវហាមឃាត់ [IAC/NIAC] ។

**វិធាន៩៦,-**

ការចាប់ធ្វើជាចំណាប់ខ្មាំងត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩៧,-**

ការប្រើប្រាស់មនុស្សជារបាំងត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩៨,-**

ការបាត់ខ្លួនដោយបង្ខំត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន៩៩,-**

ការដកហូតនូវសេរីភាពដោយបំពារបំពានត្រូវហាមឃាត់ [IAC/NIAC] ។

**វិធាន១០០,-**

មិនមានបុគ្គលណាមួយត្រូវបានដាក់ទោស ឬ កាត់អោយជាប់ទោសលើកលែងតែអនុលោមតាមការវិនិច្ឆ័យសេចក្តីដោយយុត្តិធម៌ ដែលផ្តល់នូវការធានាផ្នែកយុត្តិធម៌មិនចាំបាច់ទាំងអស់ [IAC/NIAC] ។

**វិធាន១០១,-**

គ្មានជនណាម្នាក់ត្រូវបានចោទប្រកាន់ឬផ្តន្ទាទោស ពីបទឧក្រិដ្ឋដោយយោលទៅលើអំពើណាមួយ ដែលមិនមានចែងក្នុងច្បាប់បទឧក្រិដ្ឋ ក្រោមច្បាប់ជាតិឬច្បាប់អន្តរជាតិក្នុងពេលដែលគេបានប្រព្រឹត្ត ឬក៏ទទួលរងនូវទណ្ឌកម្មធ្ងន់ធ្ងរជាងអ្វីដែលមានចែងក្នុងច្បាប់ក្នុងពេលដែលគេបានប្រព្រឹត្ត [IAC/NIAC] ។

**វិធាន១០២,-**

មិនមានបុគ្គលណាមួយត្រូវកាត់អោយជាប់ទោសចំពោះបទល្មើសណាមួយ លើកលែងផ្អែកលើមូលដ្ឋានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល [IAC/NIAC] ។

**វិធាន១០៣,-**

ទណ្ឌកម្មរួមត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន១០៤.-**

ការប្រតិបត្តិផ្នែកសាសនា និងជំនឿរបស់ប្រជាជនស៊ីវិល និងបុគ្គលដែលទំលាក់អាវុធត្រូវតែបានគោរព [IAC/NIAC] ។

**វិធាន១០៥.-**

ជីវិតគ្រួសារត្រូវបានគោរពទៅតាមលទ្ធផលដែលអាចធ្វើបាន [IAC/NIAC] ។

## ៣២. អ្នកប្រយុទ្ធ និងឋានៈជាឈ្លើយសឹកសង្គ្រាម (Combatants and Prisoner-of-War Status)

**វិធាន១០៦.-**

អ្នកប្រយុទ្ធត្រូវបែងចែក ខ្លួនពីប្រជាជនស៊ីវិល ខណៈដែលពួកគេបានចូលរួមក្នុងការវាយប្រហារ ឬ ក្នុងប្រតិបត្តិការយោធាត្រៀមវាយប្រហារ។ ប្រសិនបើពួកគេខកខានពុំបានធ្វើដូចនេះពួកគេនឹងមិនមានសិទ្ធិទទួលឋានៈជាឈ្លើយសឹកសង្គ្រាមឡើយ [IAC] ។

**វិធាន១០៧.-**

អ្នកប្រយុទ្ធដែលត្រូវបានគេចាប់ខ្លួនបាន ខណៈដែលចូលរួមក្នុងអំពើចារកម្មមិនមានសិទ្ធិទទួលឋានៈជាឈ្លើយសឹកសង្គ្រាមឡើយ។ ពួកគេអាចមិនត្រូវបានកាត់អោយជាប់ទោស ឬដាក់ទោសដោយគ្មានការវិនិច្ឆ័យជាមុនបាននោះទេ [IAC] ។

**វិធាន១០៨-**

ទាហានស៊ីឈ្នួល (ដូចដែលមានចែងក្នុងពិធីសារបន្ថែមទី ១) មិនមានសិទ្ធនឹងទទួលបានឋានៈជាអ្នកច្បាំង ឬក៏ឋានៈជាឈ្លើយសឹកឡើយ។ ពួកនឹងមិនត្រូវបានផ្តន្ទាទោសឬកំណាត់ទោសដោយមិនបានកាត់ទោសជាមុននោះឡើយ។

## ៣៣. អ្នករងរបួស អ្នកជំងឺ និងជនរងគ្រោះនៃការលិចលង់កប៉ាល់ (The Wounded, Sick and Shipwrecked)

**វិធាន១០៩.-**

នៅពេលណាដែលកាលៈទេសៈអំណោយផល ហើយជាពិសេសក្រោយពីមានការព្រមព្រៀងភាគីជម្លោះនីមួយៗ ដោយគ្មានការពន្យាពេលត្រូវប្រកាន់យកវិធានការណ៍ដែលមានទាំងអស់ដើម្បីស្រាវជ្រាវប្រមូលជម្លៀសអ្នករងរបួសអ្នកជំងឺ និងជនរងគ្រោះដោយសារកប៉ាល់លិច ដោយគ្មានការបែងចែក [IAC/NIAC] ។

**វិធាន១១០.-**

អ្នករបួស អ្នកជំងឺ និងជនរងគ្រោះដោយសារកប៉ាល់លិចត្រូវទទួលបានទៅតាមកំរិតជាក់ស្តែង និង ជាមួយការពន្យាដ៏តិចតួចនូវការថែរក្សាសុខភាព និងការយកចិត្តទុកដាក់តម្រូវដោយស្ថានភាពរបស់ពួកគេ។ មិនមានការបែងចែកត្រូវបានធ្វើឡើងក្នុងចំណោមពួកគេដោយផ្អែកលើមូលដ្ឋានណាមួយក្រៅពីមូលដ្ឋានសុខភាពបានទេ [IAC/NIAC] ។

**វិធាន១១១.-**

ភាគីជម្លោះនីមួយៗ ត្រូវប្រកាន់យកនូវវិធានការណ៍ដែលមានទាំងអស់ ដើម្បីការពារអ្នករបួសអ្នកឈឺ និងជនរងគ្រោះដោយសារកប៉ាល់លិចប្រឆាំងទល់នឹងអំពើប្រព្រឹត្តមិនគប្បី និងការឆក់ប្លន់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេ [IAC/NIAC] ។

## ៣៤. សាកសព (The Dead)

**វិធាន១១២.-**

នៅពេលណាដែលកាលៈទេសៈអំណោយផល ហើយជាពិសេសក្រោយពីមានការវាយប្រហារមួយរយៈដោយគ្មានពន្យាពេលត្រូវប្រកាន់យកវិធានការណ៍ដែលមានទាំងអស់ដើម្បីស្វែងរកប្រមូល និងជម្លៀសអ្នកស្លាប់ដោយគ្មានការបែងចែក [IAC/NIAC] ។

**វិធាន១១៣.-**

ភាគីជម្លោះនីមួយៗ ត្រូវប្រកាន់យកវិធានការណ៍ដែលមានទាំងអស់ ដើម្បីបង្ការសាកសពពីការពុកផុយ ។ ការកាត់សាកសពត្រូវបានហាមឃាត់ [IAC/NIAC] ។

**វិធាន១១៤.-**

ភាគីជម្លោះត្រូវតែខិតខំសម្របសម្រួលការបញ្ជូនត្រឡប់នូវសាកសពនៅសល់ តាមសំណើរបស់ភាគីដែលជាម្ចាស់របស់សាកសព ឬតាមសំណើរបស់សាច់ញាតិរបស់សាកសព ។ ពួកគេត្រូវបញ្ជូនត្រឡប់នូវសំភារៈផ្ទាល់ខ្លួនដល់អ្នកស្នើសុំ [IAC] ។

**វិធាន១១៥.-**

សាកសពត្រូវបានគេចាត់ចែងបញ្ចុះក្នុងលក្ខណៈគោរព ដោយផ្នូររបស់ពួកគេត្រូវបានគោរព និងថែរក្សាឱ្យបានសមស្រប ។ [IAC/NIAC] ។

**វិធាន១១៦.-**

ដើម្បីកំណត់អត្តសញ្ញាណនៃសាកសពភាគីជម្លោះនីមួយៗ ត្រូវកត់ត្រាព័ត៌មានដែលមានទាំងអស់មុនពេលកប់ហើយធ្វើកំណត់សំគាល់លើទីតាំងនៃផ្នូរ [IAC/NIAC] ។

## ៣៥. មនុស្សបាត់ខ្លួន (Missing Persons)

**វិធាន១១៧.-**

ភាគីជម្លោះនីមួយៗ ត្រូវប្រកាន់យកនូវវិធានការណ៍ដែលអាចធ្វើបានទាំងអស់ ដើម្បីពន្យល់អំពីមនុស្សដែលត្រូវបានរាយការណ៍ថាបាត់ខ្លួនដោយសារជម្លោះប្រដាប់អាវុធ និងត្រូវផ្តល់ដល់សមាជិកគ្រួសារនូវព័ត៌មានដែលមានស្តីពីជោគវាសនារបស់អ្នកបាត់ខ្លួន [IAC/NIAC] ។

## ៣៦. មនុស្សដែលត្រូវបានគេដកហូតនូវសេរីភាព (Persons Deprived of Their Liberty)

**វិធាន១១៨.-**

បុគ្គលដែលត្រូវបានដកហូតនូវសេរីភាពរបស់ពួកគេ ត្រូវបានផ្តល់នូវអាហារ ទឹក សំលៀកបំពាក់ជំរកគ្រប់គ្រាន់ និងទទួលបានការថែរក្សាផ្នែកសុខភាពសមរម្យ [IAC/NIAC] ។

**វិធាន១១៩.-**

ស្ត្រីដែលត្រូវបានដកហូតនូវសិទ្ធសេរីភាព ត្រូវបានដាក់នៅក្នុងជំរុំដោយឡែកពីជំរុំរបស់បុរសលើកលែងតែគ្រួសារត្រូវតែដាក់ឱ្យរស់នៅជួបជុំគ្នា ហើយត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ដោយស្ត្រី [IAC /NIAC] ។

**វិធាន១២០.-**

កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព ត្រូវបានដាក់នៅក្នុងជំរុំដោយឡែកពីមនុស្សពេញវ័យលើកលែងជាទីកន្លែង

ដែលគ្រួសារត្រូវបានផ្តល់ជំរក ជាក្រុមគ្រួសារ [IAC/NIAC] ។

**វិធាន១២១.-**

បុគ្គលដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាព ត្រូវតែបានឃុំខ្លួននៅក្នុងកន្លែងដែលដាច់ពីកន្លែងប្រយុទ្ធ ហើយដែលធានានូវសុខភាព និងអនាម័យដល់ពួកគេ [IAC/NIAC] ។

**វិធាន១២២.-**

ការឆក់ប្លន់សំភារៈរបស់បុគ្គលដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពត្រូវបានហាមឃាត់ [IAC /NIAC] ។

**វិធាន១២៣.-**

ព័ត៌មានលំអិតរបស់បុគ្គលដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពត្រូវបានកត់ត្រា [IAC/NIAC] ។

**វិធាន១២៤.-**

(ក) ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ICRC ត្រូវតែបានផ្តល់នូវការចូលទៅជួបជាទៀងទាត់ជាមួយបុគ្គលទាំងអស់ដែលត្រូវបានគេដកហូតនូវសិទ្ធិសេរីភាពដើម្បីបញ្ជាក់អំពីស្ថានភាពការឃុំខ្លួនរបស់ពួកគេ និង ដើម្បីស្តារឡើងវិញនូវទំនាក់ទំនងរវាងពួកគេ និងគ្រួសាររបស់ពួកគេ [IAC] ។

(ខ) នៅក្នុងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ICRC អាចផ្តល់សេវាកម្មរបស់ខ្លួនដល់ភាគីជំលោះ ដើម្បីសាកសួរសុខទុក្ខដល់បុគ្គលទាំងអស់ដែលត្រូវបានគេដកហូតនូវសិទ្ធិសេរីភាព ដោយសារហេតុផលទាក់ទងជាមួយជំលោះ ដើម្បីផ្ទៀងផ្ទាត់នូវស្ថានភាពនៃការឃុំខ្លួនរបស់ពួកគេ និងដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងអ្នកទាំងនោះ និងគ្រួសាររបស់ពួកគេ [NIAC] ។

**វិធាន១២៥.-**

បុគ្គលដែលត្រូវបានដកនូវសិទ្ធិសេរីភាព ត្រូវបានអនុញ្ញាតឱ្យទាក់ទងជាមួយគ្រួសាររបស់ពួកគេដោយស្ថិតនៅក្រោមលក្ខខណ្ឌសមស្របទាក់ទងនឹងភាពចាំបាច់នៃការឃ្លាំមើលដោយអាជ្ញាធរ [IAC/NIAC] ។

**វិធាន១២៦.-**

អ្នកជាប់ឃុំជាជនស៊ីវិល និងបុគ្គលដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពទាក់ទងនឹងជំលោះប្រដាប់អាវុធមិនមែនអន្តរជាតិ ត្រូវបានអនុញ្ញាតអោយទទួលនូវអ្នកមកសួរសុខទុក្ខជាពិសេសញាតិខ្សែជិតទៅតាមកម្រិតជាក់ស្តែងដែលមាន [NIAC] ។

**វិធាន១២៧.-**

ការអនុវត្ត ឬសកម្មភាពសាសនាផ្ទាល់ខ្លួនរបស់បុគ្គលដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពត្រូវបានគោរព [IAC/NIAC] ។

**វិធាន១២៨.-**

(ក) ឈ្លើយសឹកសង្គ្រាមត្រូវបានដោះលែង និងធ្វើមាតុភូមិនិវត្តន៍ ដោយគ្មានបង្អែរបង្អង់ក្រោយពីបញ្ឈប់នូវជំលោះជាក់ស្តែង [IAC] ។

(ខ) អ្នកស្ថិតនៅក្នុងកន្លែងឃុំឃាំងជាជនស៊ីវិល ត្រូវបានដោះលែងភ្លាមៗ នៅខណៈដែលមូលហេតុដែលតំរូវឱ្យមានការឃុំខ្លួនលែងមាន និងយ៉ាងឆាប់ៗតាមដែលអាចធ្វើទៅបានក្រោយពីបញ្ចប់នូវជម្លោះជាក់ស្តែង [IAC] ។

(គ) បុគ្គលដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ត្រូវបានដោះលែងអោយបានឆាប់ៗ ខណៈដែលមូលហេតុសំរាប់ការដកហូតនូវសិទ្ធិសេរីភាពរបស់ពួកគេលែងមិន [NIAC] ។

បុគ្គលដែលនិយាយយោងដល់ខាងលើ អាចត្រូវបានគេបន្តដកហូតនូវសិទ្ធិសេរីភាព ប្រសិនបើដំណើរការក្តីព្រហ្មទណ្ឌនៅមានដំណើរការប្រឆាំងពួកគេ ឬ ប្រសិនបើពួកគេកំពុងទទួលទោសដែលត្រូវបានដាក់ដោយស្របច្បាប់ ។

## ៣៧. ការប្តូរទីកន្លែង និងបុគ្គលដែលត្រូវបានផ្លាស់ប្តូរទីកន្លែង (Displacement and Displanced Persons)

**វិធាន១២៩.-**

(ក) ភាគីជម្លោះប្រដាប់អាវុធអន្តរជាតិមិនអាចបញ្ជូន ឬផ្ទេរដោយបង្ខំទាំងស្រុង ឬដោយផ្នែកនូវប្រជាជនស៊ីវិលរបស់ដែនដីដែលត្រូវបានកាន់កាប់ លើកលែងតែសន្តិសុខនៃជនស៊ីវិលពាក់ព័ន្ធ ឬ មានហេតុផលយោធាចាំបាច់តំរូវដូចនេះ [IAC] ។

(ខ) ភាគីជំលោះប្រដាប់អាវុធមិនមែនអន្តរជាតិ មិនអាចបញ្ជាការផ្លាស់ទីលំនៅនៃប្រជាជនស៊ីវិលទាំងស្រុង ឬដោយផ្នែកដោយសារហេតុផលពាក់ព័ន្ធជាមួយជំលោះ លុះត្រាតែសន្តិសុខរបស់ជនស៊ីវិលពាក់ព័ន្ធ ឬ មូលហេតុយោធាចាំបាច់តំរូវដូច្នេះ [NIAC] ។

**វិធាន១៣០.-**

រដ្ឋមិនអាចដេញ ឬផ្ទេរប្រជាជនរបស់ខ្លួនសូម្បីតែមួយចំនួនទៅក្នុងដែនដីដែលខ្លួនកាន់កាប់ឡើយ [IAC] ។

**វិធាន១៣១.-**

បើមានការផ្លាស់ប្តូរទីលំនៅ វិធានការដែលអាចធ្វើបានទាំងអស់ត្រូវបានប្រកាន់យក ដើម្បីឱ្យជនស៊ីវិលពាក់ព័ន្ធត្រូវបានទទួលក្រោមលក្ខខណ្ឌគាប់ចិត្តនៃជំរកអនាម័យសុខភាពសុវត្ថិភាព និងអាហារហើយសមាជិកនៃគ្រួសារតែមួយមិនត្រូវបានដាក់នៅដាច់ដោយឡែកពីគ្នាឡើយ [IAC/NIAC] ។

**វិធាន១៣២.-**

បុគ្គលដែលត្រូវបានផ្លាស់ទីលំនៅ មានសិទ្ធិក្នុងការវិលត្រឡប់មកវិញដោយស្ម័គ្រចិត្តដោយសុវត្ថិភាពមកផ្ទះរបស់គេ ឬទីកន្លែងរស់នៅជាធម្មតាឆាប់ៗ ខណៈពេលដែលហេតុផលសំរាប់ការប្តូរទីលំនៅលែងមាន [IAC/NIAC] ។

**វិធាន១៣៣.-**

សិទ្ធិលើទ្រព្យសម្បត្តិរបស់បុគ្គលដែលត្រូវបានប្តូរទីលំនៅត្រូវបានគោរព [IAC/NIAC] ។

## ៣៨. បុគ្គលដទៃផ្សេងទៀតដែលទទួលបានការការពារជាពិសេស (Other Persons Afforded Sepcific Protection)

**វិធាន១៣៤.-**

ការការពារជាពិសេសសុខភាព និងជំនួយចាំបាច់សំរាប់ស្ត្រីរងការប៉ះពាល់ដោយសារជំលោះត្រូវតែបានគោរព [IAC/NIAC] ។

**វិធាន១៣៥.-**

កុមារដែលរងការប៉ះពាល់ដោយសារជំលោះប្រដាប់អាវុធមានសិទ្ធិទទួលបានការគោរព និង ការការពារជាពិសេស [IAC/NIAC] ។

**វិធាន១៣៦.-**

កុមារមិនត្រូវបានគេជ្រើសរើសអោយចូលក្នុងកងកំលាំងប្រដាប់អាវុធ ឬ ក្រុមប្រដាប់អាវុធ [IAC /NIAC] ។

**វិធាន១៣៧.-**

កុមារមិនត្រូវបានគេអនុញ្ញាតឱ្យចូលរួមក្នុងជម្លោះ [IAC/NIAC] ។

**វិធាន១៣៨.-**

មនុស្សចាស់ជនពិការ និងកុមារតូចៗ ទទួលរងការប៉ះពាល់ដោយសារជម្លោះប្រដាប់អាវុធមានសិទ្ធិទទួលបានការការពារ និងការគោរពជាពិសេស [IAC/NIAC] ។

## ជំពូកទី៦. ការប្រតិបត្តិ
**(Implementation)**

### ៣៩. ការគោរពតាមច្បាប់មនុស្សធម៌អន្តរជាតិ (Compliance with International Humanitarian Law)

**វិធាន១៣៩.-**

ភាគីជំលោះនីមួយៗត្រូវគោរព និងធានាអោយប្រាកដនូវការគោរពច្បាប់មនុស្សធម៌អន្តរជាតិដោយកងកំលាំងប្រដាប់អាវុធរបស់ខ្លួន និងបុគ្គលដទៃទៀត ឬ ក្រុមមនុស្សដែលជាក់ស្តែងធ្វើការងារតាមការណែនាំរបស់ខ្លួន ឬ ក្រោមការគ្រប់គ្រង ឬ ចង្អុលបង្ហាញរបស់ខ្លួន [IAC/NIAC] ។

**វិធាន១៤០.-**

កាតព្វកិច្ចគោរព និងធានានូវការគោរពច្បាប់មនុស្សធម៌អន្តរជាតិ មិនផ្អែកទៅលើទង្វើទៅវិញទៅមកឡើយ [IAC/NIAC] ។

**វិធាន១៤១.-**

រដ្ឋនីមួយៗ ត្រូវរៀបចំអោយមានទីប្រឹក្សាច្បាប់នៅពេលចាំបាច់ ដើម្បីផ្តល់យោបល់ដល់មេបញ្ជាការក្នុងកំរិតសមស្រប អំពីការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ [IAC/NIAC] ។

**វិធាន១៤២.-**

រដ្ឋ និងភាគីជំលោះត្រូវផ្តល់ការណែនាំក្នុងច្បាប់មនុស្សធម៌អន្តរជាតិដល់កងកំលាំងប្រដាប់អាវុធរបស់ខ្លួន [IAC/NIAC] ។

**វិធាន១៤៣.-**

ដ្ឋត្រូវលើកទឹកចិត្តដល់ការបង្រៀនច្បាប់មនុស្សធម៌អន្តរជាតិដល់ប្រជាជនស៊ីវិល [IAC/NIAC] ។

### ៤០. ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ (Enforcement of International Humanitarian Law)

**វិធាន១៤៤.-**

រដ្ឋមិនត្រូវលើកទឹកចិត្តដល់ការរំលោភច្បាប់មនុស្សធម៌អន្តរជាតិដោយភាគីជម្លោះណាមួយ ។ រដ្ឋត្រូវដាក់សំពាធតាមកំរិតដែលអាចធ្វើបាន ដើម្បីបញ្ឈប់ការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ [IAC/NIAC] ។

**វិធាន១៤៥.-**

មិនមានហាមឃាត់ដោយច្បាប់អន្តរជាតិការធ្វើអំពើតប (Reprisals) ត្រូវតែស្ថិតនៅក្រោមលក្ខខណ្ឌតឹងរឹង [IAC] ។

**វិធាន១៤៦.-**

ការធ្វើអំពើតបវិញប្រឆាំងបុគ្គលការពារដោយសន្ធិសញ្ញាហ្សឺណែវត្រូវបានហាមឃាត់ [IAC] ។

**វិធាន១៤៧.-**

ការធ្វើអំពើតបវិញ ប្រឆាំងវត្ថុត្រូវបានការពារដោយសន្ធិសញ្ញាហ្សឺណែវ និងសន្ធិសញ្ញា Hague ស្តីពីការការពារសម្បត្តិ

វប្បធម៌ត្រូវបានហាមឃាត់ [IAC] ។

**វិធាន១៤៨.-**

ភាគីជំលោះប្រដាប់អាវុធមិនមែនអន្តរជាតិ មិនមានសិទ្ធិធ្វើអំពើតបតវិញទេ។ វិធានការណ៍ប្រឆាំងតបវិញដទៃទៀត ប្រឆាំងបុគ្គលដែលមិន ឬ លែងចូលរួមដោយផ្ទាល់ក្នុងជម្លោះត្រូវបានហាមឃាត់ [NIAC] ។

## ៤១. ការទទួលខុសត្រូវ និង សំណង (Responsibility and Reparation)

**វិធាន១៤៩.-**

រដ្ឋត្រូវទទួលខុសត្រូវចំពោះការរំលោភច្បាប់មនុស្សធម៌អន្តរជាតិដែលកើតឡើងដោយសារខ្លួន រួមមាន ៖

(ក) ការរំលោភប្រព្រឹត្តិដោយស្ថាប័នរបស់ខ្លួន រាប់បញ្ចូលកងកំលាំងប្រដាប់អាវុធរបស់ខ្លួន

(ខ) ការរំលោភប្រព្រឹត្តិដោយមនុស្ស ឬ អង្គភាពដែលខ្លួនផ្តល់អំណាច ដើម្បីប្រតិបត្តិនៃអំណាចរដ្ឋាភិបាល

(គ) ការរំលោភប្រព្រឹត្តដោយមនុស្ស ឬ ក្រុមដែលជាក់ស្តែងដើរតួនាទី ផ្អែកតាមការណែនាំ ឬ ក្រោមការចង្អុលបង្ហាញ ឬ គ្រប់គ្រងរបស់ខ្លួន និង

(ឃ) ការរំលោភប្រព្រឹត្តដោយបុគ្គលឯកជន ឬ ក្រុមមនុស្សដែលខ្លួនដឹងហើយទទួលយកអំពើរបស់បុគ្គល ឬ ក្រុមនោះ [IAC/NIAC] ។

**វិធាន១៥០.-**

រដ្ឋទទួលខុសត្រូវចំពោះការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវបានទាមទារអោយផ្តល់សំណងពេញលេញចំពោះការបាត់បង់ ឬ របួសស្នាមដែលមាន [IAC/NIAC] ។

## ៤២. ការទទួលខុសត្រូវជាបុគ្គល (Individual Responsibility)

**វិធាន១៥១.-**

បុគ្គលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋកម្មសង្គ្រាមដែលពួកគេប្រព្រឹត្ត [IAC/ NIAC] ។

**វិធាន១៥២.-**

មេបញ្ជាការ និងចៅហ្វាយដទៃទៀតត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តឡើង តាមបញ្ជារបស់ពួកគេ [IAC/NIAC] ។

**វិធាន១៥៣.-**

មេបញ្ជាការ និងចៅហ្វាយនាយដទៃទៀត ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋកម្មសង្គ្រាមប្រព្រឹត្តឡើងដោយកូនចៅរបស់ខ្លួន ប្រសិនបើពួកគេដឹង ឬ មានហេតុផលដឹងថាកូនចៅរបស់ខ្លួននឹងប្រព្រឹត្ត ឬកំពុងប្រព្រឹត្តបទឧក្រិដ្ឋហើយមិនបានប្រកាន់យកវិធានការណ៍សមស្របនិងចាំបាច់ក្នុងអំណាចរបស់ខ្លួនដើម្បីបង្ការការប្រព្រឹត្តរបស់ពួកគេ ឬ ប្រសិនបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តមិនបានដាក់ទោសទណ្ឌលើបុគ្គលដែលទទួលខុសត្រូវ [IAC/NIAC] ។

**វិធាន១៥៤.-**

រាល់អ្នកប្រយុទ្ធទាំងអស់ មានកាតព្វកិច្ចមិនគោរពបញ្ជាទូវបទបញ្ជាដែលមើលឃើញច្បាស់ក្រឡែតថាខុសច្បាប់ [IAC/NIAC] ។

**វិធាន១៥៥.-**

ការគោរពបញ្ជារបស់ថ្នាក់លើ មិនមែនជាមូលដ្ឋានអោយកូនចៅរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឡើយ ប្រសិនបើកូនចៅដឹងថា អំពើដែលត្រូវបានបញ្ជាមិនស្របច្បាប់ ឬ គួរបានដឹងថាដោយសារលក្ខណៈខុសច្បាប់ច្បាស់ក្រឡែតនៃអំពើដែលត្រូវបានបញ្ជា [IAC/NIAC] ។

## ៤៣. បទឧក្រិដ្ឋកម្មសង្គ្រាម (War Crimes)

**វិធាន១៥៦.-**

ការរំលោភធ្ងន់ធ្ងរ នៃច្បាប់មនុស្សធម៌អន្តរជាតិបង្កើតបានជាបទឧក្រិដ្ឋកម្មសង្គ្រាម [IAC/NIAC] ។

**វិធាន១៥៧.-**

រដ្ឋមានសិទ្ធិប្រើប្រាស់យុត្តាធិការសាកល ក្នុងតុលាការជាតិរបស់ខ្លួនលើបទឧក្រិដ្ឋកម្មសង្គ្រាម [IAC /NIAC] ។

**វិធាន១៥៨.-**

រដ្ឋត្រូវស៊ើបអង្កេតបទឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយជនជាតិ ឬ កងកំលាំងប្រដាប់អាវុធរបស់ខ្លួន ឬ ប្រព្រឹត្តលើដែនដីរបស់ខ្លួន ហើយប្រសិនបើសមស្រប កាត់ទោសជនសង្ស័យ ។ រដ្ឋត្រូវស៊ើបអង្កេតផងដែរនូវបទឧក្រិដ្ឋកម្មសង្គ្រាមដែលខ្លួនមានយុត្តាធិការ ហើយប្រសិនបើសមស្របកាត់ទោសជនសង្ស័យ [IAC/NIAC] ។

**វិធាន១៥៩.-**

នៅចុងបញ្ចប់នៃជម្លោះ អាជ្ញាធរកាន់កាប់អំណាចត្រូវតែខំផ្តល់នូវការលើកលែងកំហុសអោយបានទូលាយតាមដែលអាចធ្វើបាន ដល់បុគ្គលដែលបានចូលរួមក្នុងជំលោះប្រដាប់អាវុធមិនមែនអន្តរជាតិ ឬ ជនទាំងឡាយដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពដោយសារហេតុផលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ លើកលែងចំពោះបុគ្គលជាប់សង្ស័យ ឬជនត្រូវចោទ ឬ មានទោសក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម [NIAC] ។

**វិធាន១៦០.-**

អាជ្ញាយុកាលនៃបទល្មើសមិនអាចអនុវត្តចំពោះបទឧក្រិដ្ឋសង្គ្រាម [IAC/NIAC] ។

**វិធាន១៦១.-**

រដ្ឋត្រូវប្រកាន់យកកិច្ចខិតខំទាំងអស់ដើម្បីសហការណ៍ ទៅតាមកំរិតដែលអាចធ្វើបាន ជាមួយរដ្ឋដទៃទៀតដើម្បីសម្របសម្រួលការស៊ើបអង្កេត លើឧក្រិដ្ឋកម្មសង្គ្រាម និងការកាត់ទោសជនសង្ស័យ [IAC/ NIAC] ។

# INTERNATIONAL REVIEW of the Red Cross

The Review is printed in English and is published four times a year, in March, June, September and December.

Annual selections of articles are also published on a regional level in Arabic, Chinese, French, Russian and Spanish.

The articles published in the Review are available free of charge on-line at www.icrc.org/eng/review


## Submission of manuscripts

The International Review of the Red Cross invites submissions of manuscripts on subjects relating to international humanitarian law, policy and action. Most issues focus on particular topics, decided by the Editorial Board, which can be consulted under the heading Future Themes on the website of the Review. Submissions related to these themes are particularly welcome.

Articles may be submitted in Arabic, Chinese, English, French, Russian and Spanish. Selected articles are translated into English if necessary.

Submissions must not have been published, submitted or accepted elsewhere. Articles are subjected to a peer-review process; the final decision on publication is taken by the Editor-in-Chief. The Review reserves the right to edit articles. Notification of acceptance, rejection or the need for revision will be given within four weeks of receipt of the manuscript. Manuscripts will not be returned to the authors.

Manuscripts may be sent by e-mail to:
review.gva@icrc.org

**Manuscript requirements**
Articles should be 5,000 to 10,000 words in length. Shorter contributions can be published under the section Notes and comments.

For further information, please consult the Information for contributors and Guidelines for referencing on the website of the Review: www.icrc.org/eng/review.

## Subscriptions

The print run is limited. The Review is distributed to selected institutions and organizations. Further distribution is subject to availability.

Requests for subscriptions can be made to the following address:
International Committee of the Red Cross (ICRC)
Production, Multimedia and Distribution
19, Avenue de la Paix
CH - 1202 Geneva, Switzerland
f +41 22 730 27 68
e-mail: shop.gva@icrc.org
www.icrc.org/eng/shop


## ©icrc

Authorization to reprint or republish any text published in the Review must be obtained from the Editor-in-Chief. Requests should be addressed to the Editorial Team.


## Editorial Team


Editor-in-Chief: Toni Pfanner
Editorial assistant: Robin Geiss
Publication assistant: Marianne Pereda



International Review of the Red Cross
19, Avenue de la Paix
CH - 1202 Geneva, Switzerland
t +41 22 734 60 01
f +41 22 733 20 57
e-mail: review.gva@icrc.org

Volume 87 Number 857 March 2005

# INTERNATIONAL REVIEW of the Red Cross



0860/303T 04/2010 1,000

ICRC

**គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (icrc)**
ផ្ទះលេខ ១៨ ផ្លូវលេខ ៥០០ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន ទីក្រុងភ្នំពេញ
ទូរស័ព្ទ : +៨៥៥ (២៣) ៧២៦៦៩០
ទូរសារ : +៨៥៥ (២៣) ៩៩៧៧៨០
អ៊ីមែល : ppo_phnompenhoffice@icrc.org
**www.icrc.org**